# ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃពិធីបុណ្យរំឭកខួបអនុស្សាវរីយ៍ លើកទី ៦៣ ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា

## (២៨.៦.១៩៥១-២៨.៦.២០១៤)



សម្តេចអគ្គមហាពញាចក្រី
**ហេង សំរិន**
ប្រធានរដ្ឋសភា
ប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា



សម្តេចអគ្គមហាធម្មពោធិសាល
**ជា ស៊ីម**
ប្រធានព្រឹទ្ធសភា
ប្រធានគណបក្សប្រជាជនកម្ពុជា



សម្តេចអគ្គមហាសេនាបតីតេជោ
**ហ៊ុន សែន**
នាយករដ្ឋមន្ត្រី
អនុប្រធានគណបក្សប្រជាជនកម្ពុជា

សូមសម្តែងគារវភក្តី និងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតជូន **សម្តេចទាំងបី** អគ្គមគ្គុទ្ទេសក៏នៃប្រជាជនកម្ពុជា ដែលបានលះបង់អស់កម្លាំងកាយ កម្លាំងចិត្ត និងបញ្ញាញាណ ក្នុងការបម្រើប្រទេសជាតិ និងប្រជាជន ដើម្បីឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី សន្តិភាព ការបង្រួបបង្រួមជាតិ សេរីភាព ប្រជាធិបតេយ្យ និងវឌ្ឍនភាពសង្គម ។

សូមគោរពជូនពរ **សម្តេចទាំងបី** សូមបានប្រកបដោយសុខភាពបរិបូរ កាយពលមាំមួន បញ្ញាញាណភ្លឺថ្លា និងជន្មាយុយឺនយូរ ដើម្បីដឹកនាំមាតុភូមិកម្ពុជា និងគណបក្សប្រជាជនកម្ពុជា ឆ្ពោះទៅរកជោគជ័យធំៗថ្មីទៀត ។

**គោរពជូនដោយក្តីកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ**

**ទស្សនាវដ្តីប្រជាជន**



លោក តាក ស៊ុនអ៊ី

# អារម្ភកថា

## សូមគោរពសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តអ្នកអាន ជាទីគោរព !

ក្នុងឱកាសដែលសមាជិក សមាជិកាគណបក្សប្រជាជនកម្ពុជា និងប្រជាជនទូទាំងប្រទេសកំពុងសប្បាយរីករាយចូលរួមអបអរសាទរខួបអនុស្សាវរីយ៍លើកទី ៦៣ ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា (២៨ មិថុនា ១៩៥១-២៨ មិថុនា ២០១៤) **ទស្សនាវដ្តីប្រជាជន** ក៏បានចូលរួមនៅក្នុងថ្ងៃបុណ្យដ៏ឱឡារិកនេះប្រកបដោយមោទនភាពជាមួយនឹងការគម្រប់ខួប ១៣ ឆ្នាំឈានចូលឆ្នាំទី ១៤ នៃការចេញផ្សាយរបស់ខ្លួនផងដែរ (មិថុនា ២០០១-មិថុនា ២០១៤)។

រយៈពេល ១៣ ឆ្នាំនៃការចេញផ្សាយ **ទស្សនាវដ្តីប្រជាជន** បានខិតខំរួមចំណែកក្នុងការផ្សព្វផ្សាយ និង អប់រំនូវកម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយ សេចក្តីសម្រេចផ្សេងៗ សកម្មភាព និងអនុសាសន៍សំខាន់ៗរបស់ថ្នាក់ដឹកនាំនៃគណបក្សប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាល ព្រមទាំងអត្ថបទដែលទាក់ទងនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ អប់រំ សុខាភិបាល សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងការបរទេស សំដៅបង្កើនការយល់ដឹង និងការចូលរួមរបស់សមាជិកគណបក្ស និងប្រជាជនទូទៅ ក្នុងបុព្វហេតុកសាង និងការពារមាតុភូមិ។ **ទស្សនាវដ្តីប្រជាជន** បានរួមចំណែកផ្តល់នូវការវិភាគទស្សនៈ និងមតិផ្សេងៗជូនសាធារណជនឱ្យកាន់តែមានមូលដ្ឋានសម្រាប់ធ្វើការពិចារណា វាយតម្លៃប្រកបដោយ សុភវិនិច្ឆ័យចំពោះការដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល និងចំពោះសកម្មភាពប្រទូសរ៉ាយប្រជាភិថុត មួលបង្កាច់ការពិត ដែលអ្នកនយោបាយប្រឆាំង និងមជ្ឈដ្ឋានអគតិមួយចំនួនតែងតែបានប្រព្រឹត្ត។

ជាមួយគ្នានេះ **ទស្សនាវដ្តីប្រជាជន** ក៏បានធ្វើការផ្សព្វផ្សាយអប់រំអំពីដំណើរការប្រជាធិបតេយ្យនីយកម្មនៅកម្ពុជា ជាពិសេសដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៥ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាណត្តិទី ៣ ដែលបានប្រព្រឹត្តទៅដោយជោគជ័យ ប្រកបដោយលក្ខណៈសេរីត្រឹមត្រូវ និងយុត្តិធម៌ ព្រមទាំងព្រឹត្តិការណ៍នានាដែលបានកើតមានក្រោយការបោះឆ្នោតទាំងពីរនេះ។

តាមរយៈទំព័ររបស់ខ្លួន **ទស្សនាវដ្តីប្រជាជន** បានបង្ហាញជូនសាធារណជនអំពីនិរន្តរភាពរបស់រដ្ឋ និងប្រក្រតីភាពនៃជីវភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាជនកម្ពុជា ដែលឆ្លុះបញ្ចាំងឱ្យឃើញច្បាស់ថា កម្ពុជាកំពុងមានសន្តិភាពពេញលេញ មានស្ថិរភាព មានសាមគ្គីភាព និងមានការអភិវឌ្ឍដ៏ឆាប់រហ័ស ផ្ទុយស្រឡះពីការឃោសនាអកុសលរបស់ពួកប្រឆាំង និងបណ្តាមជ្ឈដ្ឋានអគតិ។

លទ្ធផលការងារដែល**ទស្សនាវដ្តីប្រជាជន** សម្រេចបានរយៈពេល ១៣ ឆ្នាំ កន្លងទៅនេះ គឺពិតជាមិនអាចកាត់ផ្តាច់បានពីការគាំទ្រទាំងខាងស្មារតី និងសម្ភារៈ ពីសំណាក់ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តអ្នកអានពីគ្រប់ទិសទីបានឡើយ ។ ការឧបត្ថម្ភគាំទ្រទាំងនេះ បានផ្តល់ជាទុនដ៏ថ្លៃថ្លា និងជាការលើកទឹកចិត្តយ៉ាងខ្លាំងដល់**ទស្សនាវដ្តីប្រជាជន** ឱ្យខិតខំបង្កើនឥតឈប់ឈរនូវគុណភាពនៃការចេញផ្សាយរបស់ខ្លួនទាំងរូបភាព និងខ្លឹមសារ ។

យើងខ្ញុំទាំងអស់គ្នា ជាបុគ្គលិកនៃ**ទស្សនាវដ្តីប្រជាជន** សូមសម្តែងនូវការគោរព និងដឹងគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះការជួយឧបត្ថម្ភគាំទ្រដ៏ថ្លៃថ្លានេះ និងមានសេចក្តីសង្ឃឹមជឿជាក់ថា ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រិយមិត្តអ្នកអានទាំងអស់នឹងជួយឧបត្ថម្ភគាំទ្រដល់**ទស្សនាវដ្តីប្រជាជន** ជាបន្តទៀត។

ឆ្នាំ២០១៤និងឆ្នាំខាងមុខទៀត ជាមួយនឹងស្មារតីសុទិដ្ឋិនិយមដ៏រឹងមាំចំពោះស្ថិរភាព និងការរីកចម្រើនរបស់ជាតិ **ទស្សនាវដ្តីប្រជាជន** នឹងប្រឹងប្រែងបន្តអនុវត្តនូវភារកិច្ចរបស់ខ្លួនឱ្យទទួលបានលទ្ធផលកាន់តែប្រសើរឡើងថែមទៀត ដោយប្រកាន់ខ្ជាប់នូវអត្តសញ្ញាណរបស់ខ្លួនជាទស្សនាវដ្តីបម្រើប្រយោជន៍ជាតិ បម្រើប្រយោជន៍ប្រជាជន និងគោរពក្រមសីលធម៌វិជ្ជាជីវៈ ។

សូមគោរពជូនពរសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តអ្នកអានទាំងអស់ សូមបានប្រកបពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។/

*ដោយសេចក្តីគោរព ពីទស្សនាវដ្តីប្រជាជន*

**និទានរឿងកថា EDITORIAL**

# ពង្រឹងតួនាទីដឹកនាំរបស់គណបក្ស ផ្សារភ្ជាប់ជាមួយប្រជាជន ឆ្ពោះទៅរកជោគជ័យថ្មីៗទៀត

# TStrengthening CPP's Leadership Role, Bonding with People for Further Successes

គណបក្សប្រជាជនកម្ពុជា ជាគណបក្សនយោបាយដែលចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គមកម្ពុជា និងមានប្រវត្តិយូរអង្វែងផ្សារភ្ជាប់ជាមួយប្រវត្តិសាស្ត្ររបស់កម្ពុជាជាច្រើនដំណាក់កាលក្នុងរយៈពេលជាង ៦ ទសវត្សកន្លងមកនេះ ដែលមានសភាពបត់បែន និងស្មុគស្មាញក្រៃលែង ។

គណបក្សប្រជាជនកម្ពុជាដែលមានឈ្មោះដើមថា បក្សប្រជាជនបដិវត្តន៍ខ្មែរ បានបដិសន្ធិនៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ១៩៥១ ដោយមានប្រភពពីចលនាតស៊ូរបស់ប្រជាជាតិខ្មែរ ដើម្បីដណ្តើមឯករាជ្យពីពួកអាណានិគមនិយម ដែលបានចូលឈ្លានពានត្រួតត្រាកម្ពុជាតាំងពីដើមពាក់កណ្តាលទីពីរនៃសតវត្សទី ១៩ មក ។ ចាប់តាំងពីថ្ងៃបដិសន្ធិរហូតមកដល់បច្ចុប្បន្ន គណបក្សប្រជាជនកម្ពុជាបានប្រកាន់ខ្ជាប់ឥតប្រែប្រួលនូវសារជាតិរបស់ខ្លួន គឺជាគណបក្សរបស់ប្រជាជន ដែលធ្វើអ្វីៗគ្រប់យ៉ាងដើម្បីប្រទេសជាតិ និងប្រជាជន ។ រយៈពេលជិត ៣៦ ឆ្នាំកន្លង ទៅនេះ គណបក្សប្រជាជនកម្ពុជា គឺជាកម្លាំងនយោបាយឈានមុខដែលបានដឹកនាំប្រជាជនធ្វើការតស៊ូប្រយុទ្ធផ្តួលរំលំរបបប្រល័យពូជសាសន៍ រហូតទទួលបានជ័យជម្នះជាប្រវត្តិសាស្ត្រនាថ្ងៃ ៧ មករា ឆ្នាំ ១៩៧៩ ដែលបានសង្គ្រោះជាតិឱ្យរស់ឡើងវិញទាន់ពេលវេលា បានដណ្តើមជូនប្រជាជនវិញនូវសិទ្ធិ សេរីភាព និងប្រជាធិបតេយ្យ ហើយបើកឡើងនូវទំព័រថ្មីនៃប្រវត្តិសាស្ត្រកសាងមាតុភូមិរបស់ប្រជាជាតិខ្មែរឡើងវិញ ។ លើមូលដ្ឋានជ័យជម្នះ ៧ មករា គណបក្សប្រជាជនកម្ពុជាបានបន្តដឹកនាំប្រទេស ការពារការរស់ឡើងវិញរបស់ប្រជាជន ស្តារ និងកសាងមាតុភូមិពីគំនរផេះផង់ បង្កើតបានសមិទ្ធផលធំៗយ៉ាងច្រើនជាបន្តបន្ទាប់ ធ្វើឱ្យទឹកដីកម្ពុជាបានប្រែក្លាយពីទឹកដីមួយដែលត្រូវបំផ្លាញខ្ទេចខ្ទីដោយសង្គ្រាម និងរបបប្រល័យពូជសាសន៍ មកជាទឹកដីមួយប្រកបដោយសន្តិភាព ស្ថិរភាព និងកំពុងមានការអភិវឌ្ឍលើគ្រប់វិស័យ ។ បច្ចុប្បន្នកម្ពុជាត្រូវបានវាយតម្លៃថាជាប្រទេសទី ១១ លើពិភពលោក ដែលបានសម្រេចកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយ ជាប្រទេសទី ៥ ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ដែលអាចសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្ស និងស្ថិតក្នុងចំណាត់ថ្នាក់ទី ១ នៅអាស៊ី ប៉ាស៊ីហ្វិកដែលសម្រេចបាននូវវឌ្ឍនភាពល្អប្រសើរក្នុងការកែលម្អសូចនាករផ្នែកសង្គមកិច្ច ជាពិសេសការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង ១% ក្នុង ១ ឆ្នាំ ។

ឆ្នាំ ២០១៣ កន្លងទៅនេះកម្ពុជាសម្រេចបាននូវសមិទ្ធផលជាច្រើនទៀតគួរឱ្យមោទនភាពក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម ។ ជាក់ស្តែង សេដ្ឋកិច្ចមានកំណើន ៧,៤% ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចត្រូវបានធានាជីវភាពប្រជាជនក៏ត្រូវបានកែលម្អថែមទៀត ។ ផលស្រូវវស្សាប្រាំង និងវស្សាសម្រេចបានជាង ៩ លាន ៣ សែនតោន ដែលអាចឱ្យយើងនៅសល់ស្រូវជាង ៤ លាន ៧ សែនតោន សម្រាប់បម្រើគោលដៅនាំចេញ ។ ផលិតកម្មក្នុងវិស័យវាយនភ័ណ្ឌ និងស្បែកជើងមានតម្លៃនាំចេញរហូតដល់ជាង ៥ ពាន់លានដុល្លារអាមេរិក និងមានកម្មករនិយោជិតប្រមាណជាង ៦២

The Cambodian People's Party has deeply rooted in the Cambodian society and has a long-lasting history bonding, in numerous zigzagging and complicate stages, with the Cambodian history in the last six decades.

The Cambodian People's Party, originally the Khmer Revolutionary Party, established on 28 June 1951 by numerous Khmer national resistant movements who fought for independence from the colonialism whose invasion and occupation started in the second half of the 19th century. From its inception to the present, the Cambodian People's Party adheres steadfastly to its nature of doing everything possible for the nation and people. Over the past 36 years, the Cambodian People's Party serves as the leading political force in the struggle to bring down the regime of genocide and to score victory on 7 January 1979, thus saving and reviving the country in a timely manner, while obtaining rights, freedom and democracy to the people. The victory also ushered in a new page in the history of the national reconstruction of Cambodia.

With the spirit of 7 January victory, the Cambodian People's Party has continued to lead the country, defended the people's survival, restored and reconstructed the motherland from ashes, while creating numerous achievements one after the other. The country has transformed from the land of destruction by war and genocide to the land of peace, stability and constant development in all fields. As of the present, Cambodia has been recognized as the the 11th country in the world that achieved a higher economic growth during the last 10 years and the fifth country among developing nations to have achieved the millennium development goal. It stands in the first rank countries in Asia Pacific that achieved good progress in improving the country's socio-economic indicator, especially the poverty reduction at the rate of 1% per annum.

In 2013, Cambodia realized with pride numerous achievements in its endeavor for socio-economic development that scored a 7.4% growth, stable macro-economy and improvement of the living condition of the people. The country put out 9.3 million tons of dry and rainy season rice, with a surplus of 4.7 million metric tons for export. As products from the garment and shoemaking sector achieved an export value over 5 billion USD, over 620,000 workers and employees received total wages of over one billion USD per annum. Over two million people also have benefitted indirectly from this sector. It is worth noting the promising development in the fields of construction, property and tourism. Cambodia has received over 4.2 million foreign arrivals, a notice of 17% increase that generated 2,547 million USD

ម៉ឺននាក់ ដែលទទួលបានប្រាក់ឈ្នួលសរុបប្រមាណជាង ១ ពាន់លានដុល្លារអាមេរិកក្នុង១ឆ្នាំ ។ប្រជាជនប្រមាណជាង២លាននាក់ផ្សេងទៀតក៏ទទួលបានប្រយោជន៍ដោយប្រយោលពីវិស័យនេះផងដែរ ។ វិស័យសំណង់ និងអចលនទ្រព្យ និងវិស័យទេសចរណ៍មានការរីកចម្រើនយ៉ាងខ្លាំង ។ ភ្ញៀវអន្តរជាតិមកទស្សនាកម្ពុជាមានជាង៤លាន២សែននាក់ កើនឡើង ១៧% ហើយទទួលបានចំណូល ២៥៤៧ លានដុល្លារអាមេរិក មានកំណើនប្រមាណ ១៥% បើធៀបឆ្នាំ ២០១២ ។ មកទល់បច្ចុប្បន្ន ផ្លូវជាតិ និងផ្លូវខេត្តមានប្រវែងសរុបជាង ១២ ២៣៩ គីឡូម៉ែត្រ បើគិតទាំងផ្លូវជនបទយើងមានបណ្តាញផ្លូវថ្នល់សរុបប្រវែង៤៨៨៤២គ.ម ។ស្ពានឆ្លងកាត់ទន្លេធំ និងដៃសមុទ្រមានចំនួន ១៤ កន្លែង និងកំពុងសាងសង់ចំនួនចំនួន ៥ កន្លែងទៀត គឺស្ពានមេគង្គទី ៣ (អ្នកលឿង) ស្ពានមេគង្គទី៤ (ខេត្តស្ទឹងត្រែង) ស្ពានជ្រោយចង្វាទី ២ (រាជធានីភ្នំពេញ) ស្ពានទន្លេបាសាក់ទី ៣ (ក្រុងតាខ្មៅ ខេត្តកណ្តាល) និងស្ពានទន្លេបាសាក់ទី ៤ (ស្រុកកោះធំ ខេត្តកណ្តាល) ។ បណ្តាញធារាសាស្ត្រ និងប្រព័ន្ធស្រោចស្រពទាំងតូច មធ្យម និងធំ ត្រូវបានកសាងនៅគ្រប់ទិសទី ធ្វើឱ្យភាពម្ចាស់ការលើបញ្ហាទឹកបានកើនឡើងជារៀងរាល់ឆ្នាំ ។ ដោយឡែកក្នុងឆ្នាំ ២០១៤ នេះ កម្ពុជារំពឹងថានឹងសម្រេចបានកំណើនសេដ្ឋកិច្ចជាង ៧% បន្តទៀត ។លើមូលដ្ឋានសមិទ្ធផលទាំងនេះ កម្ពុជាកំពុងបន្តដំណើរទៅមុខទៀតប្រកបដោយក្តីសង្ឃឹម ។

ជោគជ័យ និងសមិទ្ធផលរបស់ប្រជាជនទាំងអស់នេះ មិនបានធ្វើឱ្យគណបក្សប្រឆាំង និងបណ្តាមជ្ឈដ្ឋានអគតិសប្បាយរីករាយឡើយ ។ ផ្ទុយទៅវិញ ពួកគេបានរកគ្រប់វិធីដើម្បីបដិសេធអត្ថន័យដ៏វិសេសវិសាលនៃជោគជ័យទាំងអស់នោះ មួលបង្កាច់នូវរាល់ការពិតជាប្រវត្តិសាស្ត្រក្នុងរយៈពេលជាង៣៥ឆ្នាំមកនេះហើយបង្កើតឱ្យមានបញ្ហាស្មុគស្មាញនានាមិនចេះចប់ ជាពិសេសបន្ទាប់ពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៥ កន្លងទៅ សំដៅដកការទុកចិត្តរបស់ប្រជាជនមកលើគណបក្សប្រជាជនកម្ពុជានិងឈានទៅផ្តួលរំលំគណបក្សប្រជាជនកម្ពុជាដែលរួមទាំងការប៉ុនប៉ងផ្តួលរំលំតាមរយៈ"អំណាចប្រជាជន"ទៀតផង ។ មហិច្ឆតាដណ្តើមយកអំណាចនេះមិនមែនទើបតែកើតមានក្នុងពេលបច្ចុប្បន្នទេ គឺវាកើតឡើងតាំងពីពេលដែលគណបក្សប្រជាជនកម្ពុជាចាប់ផ្តើមដឹកនាំប្រទេសមកម្ល៉េះ ប៉ុន្តែពួកគេតែងតែបរាជ័យជារៀងដរាប ពីព្រោះសច្ចធម៌នៅខាងគណបក្សប្រជាជនកម្ពុជា ប្រជាជនភាគច្រើនលើសលប់គាំទ្រគណបក្សប្រជាជនកម្ពុជា ។

ជាការពិត ទន្ទឹមនឹងគុណសម្បត្តិដ៏ធំធេងក្នុងការដឹកនាំប្រទេស គណបក្សប្រជាជនកម្ពុជាក៏មានចំណុចខ្វះខាតដោយអន្លើផងដែរ ធ្វើឱ្យការឆ្លើយតបទៅនឹងសំណូមពររបស់ប្រជាជន ក៏ពុំទាន់បានពេញលេញនៅឡើយទេ អាស្រ័យដោយមូលហេតុសត្យានុម័តផង និងមូលហេតុអត្តនោម័តផង ។ ប្រការនេះទាមទារឱ្យគណបក្សត្រូវខិតខំលើកកម្ពស់ឥតឈប់ឈរនូវសមត្ថភាពដឹកនាំ ទាំងលើការងារគណបក្ស ទាំងលើការងាររដ្ឋ សំដៅធានាប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្តគោលនយោបាយលើគ្រប់វិស័យ និងការពង្រឹងជួរមន្ត្រីគណបក្សឱ្យសម្រួចឆន្ទៈស្នេហាជាតិ ស្រឡាញ់ប្រជាជនឥតថមថយ ទោះស្ថិតក្នុងស្ថានភាព និងកាលៈទេសៈណាក្តី ។

income or 15% higher compared to the year 2012.

As of present, the national and provincial roads altogether have come to 12,239 Kilometers. To include also the rural roads, we now have 48,842 Kilometers. We have fourteen bridges across rivers and tributary to the sea and there are five more bridges under construction – The Mekong 3 (at Neak Loeung), The Mekong 4 (at Stoeng Treng), the Jroy Jangva Bridge 2 (in Phnom Penh), the Bassac 3 (at Takhmao, Kandal) and the Bssac 4 (at Koh Thom ditrict, Kandal province). We have improved our water management every year though building small, medium and large hydraulic and irrigation system everywhere in the country. Particularly, in 2014, Cambodia expects to achieve another growth of over 7%. Based on these achievements, Cambodia is making its advancement to a hopeful future.

These successes and achievements fail to please the opposition party and ill will circles. They have on the contrary sought every means to deny the meaning of these achievements, twisted the historical truth of the more than 35 years, while created endless complication, especially after the fifth legislative term of the National Assembly's elections. They aim to take people's trust away from the Cambodian People's Party and henceforth seek to topple it through people's power. Their ambition for power is not a creation in the present circumstance but one since when the Cambodian People's Party started its leadership of the country. Nevertheless, they always failed because the truth stands with the Cambodian People's Party, whom the majority of the Cambodian people support.

It is true that while acclaiming the great achievements in its leadership, the Cambodian People's Party also acknowledges subjective and objective shortcomings in its response to the people's demand. This has commanded the Party to enhance steadfastly its leadership capability in both Party and governmental works aimed at guaranteeing high efficiency in the implementation of policies in all fields and assuring the Party's officials' efforts to endure and embolden the Party's will of patriotism and love of the people, no matter in what circumstance they may find themselves. The shortcomings, especially those caused by negative actions of a small number of officials, who failed to adhere to the party's ideal, while infringing upon rights and interests of the state and people, have become strong points for the opposition, who, through their slanderous propaganda, exaggerated further among people to ignite conflict and discontent towards the Cambodian People's Party.

It is in its effort to scrap those shortcomings the Cambodian People's Party has revealed strong determination in continuing to implement more effectively wide-ranging and deep-rooted reforms in numerous fields to guarantee good governance, ensure justice, social equity and sustainable development.

Now is a new stage when the Party has to face up

ចំណុចខ្វះខាតផ្សេងៗរបស់គណបក្ស ជាពិសេសចំណុចខ្វះខាតដែលបណ្តាលមកពីភាពអសកម្មរបស់មន្ត្រីមួយចំនួនតូច ដែលមិនបានប្រកាន់ខ្ជាប់នូវឧត្តមគតិបក្ស ប្រព្រឹត្តខុសឆ្គងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់រដ្ឋ និងប្រជាជន ត្រូវបានពួកប្រឆាំងយកទៅប្រើប្រាស់ជាចំណុចខ្លាំងរបស់ខ្លួន តាមរយៈការឃោសនាមួលបង្កាច់ ពង្រីកបញ្ហាក្នុងប្រជាជន ហើយពូនផ្តុំដុតបញ្ឆេះជាទំនាស់ និងការមិនពេញចិត្តចំពោះគណបក្សប្រជាជនកម្ពុជា ។ ក្នុងទិសដៅពុះពារលប់បំបាត់នូវចំណុចខ្វះខាតទាំងនោះ គណបក្សប្រជាជនកម្ពុជាបានបង្ហាញការប្តេជ្ញាដ៏មុតមាំ ក្នុងការបន្តអនុវត្តកំណែទម្រង់ដ៏ទូលំទូលាយ និងស៊ីជម្រៅក្នុងវិស័យជាច្រើនឱ្យកាន់តែបានលឿន កាន់តែមានប្រសិទ្ធភាពថែមទៀត ដើម្បីធានានូវអភិបាលកិច្ចល្អ ធានាយុត្តិធម៌ សមធម៌សង្គម និងការអភិវឌ្ឍប្រកបដោយចីរភាព ។

បច្ចុប្បន្ននេះ គឺជាដំណាក់កាលថ្មីមួយទៀតនៃការតស៊ូរបស់គណបក្សអាស្រ័យដោយមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃសភាពការណ៍ពិភពលោក ការផ្លាស់ប្តូរនៅក្នុងទំនាក់ទំនងអន្តរជាតិ ការរីកចម្រើននៃសេដ្ឋកិច្ចសង្គម និងការជះឥទ្ធិពលយ៉ាងខ្លាំងនៃបច្ចេកវិទ្យាដែលធ្វើឱ្យប្រជាជនមានការប្រែប្រួលថ្មីទាំងឥរិយាបថ របៀបរស់នៅ និងការគិតគូរថ្មី ។ ព្រមជាមួយនោះ គណបក្សប្រឆាំងក៏កំពុងខិតខំរកវិធីថ្មីៗថែមទៀត ដើម្បីប្រឹងប្រែង ពង្រីកតួនាទីរបស់ខ្លួននៅក្នុងសង្គម ជាមួយនឹងការជួយជ្រោមជ្រែងពីសំណាក់មជ្ឈដ្ឋានអគតិមួយចំនួនពីខាងក្រៅ ។ ប្រការទាំងនេះ ទាមទារឱ្យគណបក្សត្រូវប្រកាន់យកនូវគោលការណ៍ គោលនយោបាយនានា និងសកម្មភាពដ៏មោះមុតបំផុត ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលថ្មីនេះ ។ ក្នុងបរិការណ៍នេះ គណបក្សប្រជាជនកម្ពុជា ត្រូវបន្តបំពេញបេសកកម្មដ៏ឧត្តុង្គឧត្តមជាប្រវត្តិសាស្ត្ររបស់ខ្លួនជាមួយនឹងការប្តេជ្ញាចិត្តខ្ពស់ជាងពេលណាៗទាំងអស់ ដើម្បីសម្រេចជោគជ័យក្នុងការអនុវត្តកម្មវិធីនយោបាយរបស់ខ្លួន ធានាបានការការពារសមិទ្ធផលជាតិ ការពាររដ្ឋធម្មនុញ្ញ ការពារជាតិ សាសនា ព្រះមហាក្សត្រ និងលើកកម្ពស់ឥតឈប់ឈរនូវជីវភាពរស់នៅរបស់ប្រជាជនកម្ពុជានៅទូទាំងប្រទេស ។

ក្នុងស្មារតីនេះ គណបក្សគ្រប់ថ្នាក់ មន្ត្រីសមាជិក សមាជិកាគណបក្សគ្រប់រូប គប្បីចងចាំទុកជាគតិដ៏មានតម្លៃនូវសុន្ទរកថារបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ក្នុងឱកាសរំឭកខួបលើកទី ៦៣ ថ្ងៃ បង្កើតគណបក្សប្រជាជនកម្ពុជាដែលបានថ្លែងថា : **បច្ចុប្បន្នប្រជាជាតិយើងកំពុងឈានទៅមុខប្រកបដោយថាមពលនិងក្តីសង្ឃឹម ឆ្ពោះទៅរកអនាគតមួយដ៏ភ្លឺស្វាងជាអនាគតដែលស្ថិតនៅក្នុងដៃរបស់យើងទាំងអស់គ្នា ។សន្តិភាព ប្រជាធិបតេយ្យ និងអភិវឌ្ឍន៍ ឥឡូវនេះមិនមែនគ្រាន់តែជាបំណងប្រាថ្នានោះទេ តែជាការពិតដែលកំពុងតែកើតមានឡើង ហើយជាមាគ៌ាដ៏ត្រឹមត្រូវដែលនឹងនាំយើងឱ្យដើរទៅមុខបន្តទៀត ។រយៈពេល ១៥០ ឆ្នាំមកនេះ យើងមានពេលតិចណាស់ដែលជាឱកាសពេញលេញសម្រាប់អភិវឌ្ឍប្រទេសជាតិ ក្រៅពីនោះ គឺជាពេលវេលាដែលត្រូវរងទុក្ខវេទនា និងការអាម៉ាស់ដោយការបាត់បង់ឥស្សរភាព ជាពេលវេលានៃសង្គ្រាមបំផ្លិចបំផ្លាញ និងជាពេលវេលានៃសោកនាដកម្មដែលពុំអាចនឹងពណ៌នាបាន ។ ដូច្នេះ យើងមិនអាចឱ្យបាត់បង់ឱកាសតទៅទៀតទេ យើងត្រូវចេះក្តាប់ឱកាសសម្រាប់អភិវឌ្ឍខ្លួនឯង ។ បើមិនដូច្នោះទេ យើងនឹងត្រូវជាប់ក្នុងខ្នោះឃ្នាងច្រវាក់នៃអស្ថិរភាព ការបែកបាក់ និងភាពក្រីក្រ ដែលមិនអាចនឹងមានថ្ងៃរំដោះខ្លួនឱ្យរួចបានឡើយ នេះជាហេតុផលសំខាន់បំផុត ។ គណបក្សប្រជាជនកម្ពុជា សូមអំពាវនាវដល់ជនរួមជាតិទាំងមូល ដល់គ្រប់គណបក្ស និងមជ្ឈដ្ឋានទាំងឡាយក្នុងសង្គម ទោះមាននិន្នាការនយោបាយផ្សេងៗគ្នាក្តី សូមចៀសវាងនូវអំពើណាដែលនាំទៅរកការបែកបាក់ ហើយសូមធ្វើសកម្មភាពរួមគ្នាក្រោមដំបូលរដ្ឋធម្មនុញ្ញតែមួយ ដើម្បីប្រទេសជាតិយើងទាំងអស់គ្នា ។/**

ទស្សនាវដ្តីប្រជាជន

with rapid changes in the world development, in foreign relations, socio-economic advancement as well as immeasurable impacts of technology that prompt a new way of life and thinking attitude of the people. At the same time, the opposition party has sought every means to expand its role in the society with help rendered from ill will circles from outside. These complications require the Party to adhere to principles, policies and determined actions aimed at responding to new changes. In this context, the Cambodian People's Party must continue its supremely historic mission with higher determination than ever to realize successes in the implementation of its political platform, to guarantee the protection of national achievements, defense of the Constitution, nation, religion and King, while raising high and steadfast living condition of the people in the whole country.

In this spirit, the Party of all levels, every officials and members should keep in mind invaluable thought given in the speech of Samdech Akka Moha Thomma Pothisdal Chea Sim, on occasion of the 63rd anniversary of the foundation of the Cambodian People's Party. The thought goes: "presently, our nation is making its energetic and hopeful advancement toward a bright future, one that is going to be in our hands. Peace, democracy and development are not only the aspiration but also the truth in the making. It will serve as a correct path to continue our advancement. Over the past 150 years, we had so little opportunity for national development. The rest of the time was for suffering and shamefulness from losing dignity and destructive war to indescribable tragedy. We cannot lose opportunity no more. We must hold on to this chance for development by ourselves. Anything different to that would have us placed in instability, division and poverty that no one would know when we could liberate ourselves. This is the main reason. The Cambodian People's Party appeals to all compatriots and all political parties and circles, despites their different political tendency, to refrain themselves from actions that may lead to division and to join action under the Constitution for the sake of our nation"./.

*THE PRACHEACHUN MAGAZINE*



*គណៈអធិបតីនៃអង្គមីទ្ទិញ*

# សុន្ទរកថា
# សម្តេចអគ្គមហាពញាចក្រី ហេង សំរិន
# ប្រធានរដ្ឋសភា ប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា ថ្លែងក្នុងពិធី
# មីទ្ទិញរំឭកខួបអនុស្សាវរីយ៍លើកទី ៦៣ ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា
# (២៨.០៦.១៩៥១-២៨.០៦.២០១៤)

*សូមក្រាបថ្វាយបង្គំសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះរាជាគណៈ និងព្រះថេរានុថេរៈគ្រប់ ព្រះអង្គ ជាទីសក្ការៈ*
*សម្តេច ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ*
*សមាជិក សមាជិកាគណបក្សប្រជាជនកម្ពុជា និងជនរួមជាតិទាំងអស់ជាទីគោរពស្នេហា !*

ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៤ នេះ ជាទិវាគម្រប់ ៦៣ ឆ្នាំ នៃការបង្កើតគណបក្សប្រជាជនកម្ពុជា ដែលនៅគ្រាដំបូងមានឈ្មោះថា "បក្សប្រជាជនបដិវត្តន៍ខ្មែរ" ដើម្បីដឹកនាំការតស៊ូរំដោះជាតិពីពួកអាណានិគមនិយមដណ្តើមឯករាជ្យ ជូនមាតុភូមិ។ ចាប់តាំងពីពេលបដិសន្ធិមក គណបក្សប្រជាជនកម្ពុជាបានរក្សាខ្ជាប់ឥតប្រែប្រួលនូវឧត្តមគតិរបស់ខ្លួន គឺរួមសុខ រួមទុក្ខជាមួយប្រជាជន ពុះពារធ្វើពលិកម្មឥតរួញរា ដើម្បីប្រជាជាតិកម្ពុជា ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ អព្យាក្រឹត និងវឌ្ឍនភាពសង្គម។

យើងប្រារព្ធពិធីនេះឡើង ក្នុងស្មារតីគោរព និងដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះយុទ្ធជន យុទ្ធនារី និងអ្នកស្នេហាជាតិខ្មែរនៅគ្រប់ជំនាន់ ដែលបានតស៊ូប្រយុទ្ធយ៉ាងប្តូរផ្តាច់ ហ៊ានលះបង់នូវសាច់ឈាម និងអាយុជីវិតប្រកបដោយវីរភាពដ៏ខ្ពង់ខ្ពស់ ដើម្បីបុព្វហេតុជាតិ និងប្រជាជន។ ខួបអនុស្សាវរីយ៍នេះក៏បានប្រព្រឹត្តឡើងក្នុងសភាពការណ៍ដែលប្រជាជនកម្ពុជាសម្រេចបានសមិទ្ធផលថ្មីៗថែមទៀតលើគ្រប់វិស័យក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម រយៈពេល៦ខែដើមឆ្នាំ ២០១៤ នេះ ទោះបីជានៅមានបញ្ហាលំបាកស្មុគស្មាញខ្លះក្តី។

នៅក្នុងឱកាសដ៏វិសេសវិសាលនេះ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមសម្តែងគារវភក្តីភាព និងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថសីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលកំពុងគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់នៃប្រជារាស្ត្រខ្មែរគ្រប់ៗរូប។ សូមថ្វាយព្រះពរ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** និង **សម្តេចព្រះវររាជមាតាជាតិជាទីសក្ការៈ** សូមមានព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា និងព្រះជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំនាវាកម្ពុជាឆ្ពោះទៅកាន់ត្រើយវឌ្ឍនភាពដ៏រុងរឿងសុខក្សេមក្សាន្ត។

នៅក្នុងឱកាសនេះដែរ ក្នុងនាមសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ថ្នាក់ដឹកនាំនៃគណបក្សប្រជាជនកម្ពុជា និងខ្លួនខ្ញុំផ្ទាល់ សូមសម្តែងការគោរព និងសេចក្តីនឹករឭកដ៏កក់ក្តៅបំផុតជូនជនរួមជាតិទាំងអស់នៅគ្រប់ទិសទី ជាកសិករ កម្មករ និយោ-




*សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ថ្លែងសុន្ទរកថាទៅកាន់អង្គមីទិញ*

ជិត អាជីវករ ព្រះសង្ឃ បព្វជិតនៃគ្រប់សាសនា គ្រប់ជនជាតិ មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលកំពុងចូលរួមអនុវត្តយ៉ាងសកម្មនូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីបន្តកសាងការពារមាតុភូមិ និងលើកស្ទួយជីវភាពរស់នៅឱ្យបានកាន់តែប្រសើរឡើង ។

*អង្គមីទិញ ជនរួមជាតិជាទីគោរពស្នេហា !*

រយៈពេល ៦៣ ឆ្នាំ កន្លងទៅនេះ គណបក្សប្រជាជនកម្ពុជាបានឆ្លងកាត់ដំណាក់កាលជាប្រវត្តិសាស្ត្រជាច្រើន ប្រកបដោយមោទនភាព ដោយបានរក្សាខ្ជាប់នូវសារជាតិ និងប្រពៃណីដ៏ថ្លៃថ្លារបស់ខ្លួន ។ គណបក្សបានដឹកនាំចលនាបដិវត្តន៍រំដោះជាតិដ៏ខ្លាំងក្លា ដែលបានរួមវិភាគទានយ៉ាងធំធេងនៅក្នុងការតស៊ូរបស់ប្រជាជាតិខ្មែរទាំងមូល ដើម្បីដណ្តើមឯករាជ្យពីពួកអាណានិគមនិយមរហូតទទួលបានជ័យជម្នះដ៏ល្បីរន្ទឺនៅឆ្នាំ ១៩៥៣ ។

ពេលប្រទេសជាតិត្រូវធ្លាក់ទៅក្នុងគ្រោះមហន្តរាយប្រល័យពូជសាសន៍ ដែលរបបកម្ពុជាប្រជាធិបតេយ្យរបស់ពួកប៉ុល ពត បានបង្កឡើងចាប់ពីថ្ងៃ ១៧ ខែមេសា ឆ្នាំ ១៩៧៥ មកនោះ គណបក្សប្រជាជនកម្ពុជា គឺជាកម្លាំងនយោបាយឈានមុខតែមួយគត់ដែលបានក្រោកឈរឡើងប្រមូលកម្លាំងប្រជាជាតិពីគ្រប់ទិសទីរួមសាមគ្គីនៅក្រោមទង់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានិងបានអំពាវនាវរកការជួយឧបត្ថម្ភគាំទ្រពីសំណាក់ប្រជាជនស្នេហាសន្តិភាព និងយុត្តិធម៌នៅលើពិភពលោក ដើម្បីប្រយុទ្ធផ្តួលរំលំរបបដ៏យង់ឃ្នងនេះ រហូតទទួលបានមហាជ័យជម្នះជាប្រវត្តិសាស្ត្រនាថ្ងៃ ៧ មករា ឆ្នាំ ១៩៧៩ ។ ជ័យជម្នះ ៧ មករា បានសង្គ្រោះជាតិឱ្យរស់ឡើងវិញទាន់ពេលវេលា បានដណ្តើមមកជូនប្រជាជនវិញនូវសិទ្ធិ សេរីភាព និងប្រជាធិបតេយ្យដែលត្រូវបាត់បង់ទាំងស្រុងនៅក្នុងរបបប៉ុល ពត ហើយបានបើកឡើងនូវទំព័រថ្មីនៃប្រវត្តិសាស្ត្រកសាងមាតុភូមិរបស់ប្រជាជាតិខ្មែរឡើងវិញ ។

រយៈពេលជិត ៣៦ ឆ្នាំបន្ទាប់ពីថ្ងៃជ័យជម្នះ ៧ មករា ជាមួយនឹងការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ប្រជាជនកម្ពុជាបានពុះពារឆ្លងកាត់ដំណាក់កាលនានាយ៉ាងលំបាកលំបិនជាទីបំផុត ប្រកបដោយជោគជ័យ និងកិត្តិយស បង្កើតបានសមិទ្ធផលធំៗជាប្រវត្តិសាស្ត្រយ៉ាងច្រើន ធ្វើឱ្យកម្ពុជាបានប្រែក្លាយពីទឹកដីមួយដែលត្រូវបំផ្លាញស្ទើរគ្មានសល់អ្វីដោយសារសង្គ្រាម និងរបបប្រល័យពូជសាសន៍ មកជាទឹកដីមួយប្រកបដោយសន្តិភាព ស្ថិរភាព និងកំពុងមានការអភិវឌ្ឍលើគ្រប់វិស័យដូចបច្ចុប្បន្ននេះ ។ ប្រជាជនកម្ពុជាគ្រប់រូប ទាំងអ្នកដែលបានឆ្លងកាត់របបប៉ុល ពត ទាំងស្រទាប់យុវជនដែលបានកើតក្រោយថ្ងៃ ៧ មករា សុទ្ធតែបានទទួលប្រយោជន៍ពីមនុញ្ញផលដ៏ធំធេងនេះ ។ ពិតប្រាកដណាស់ថា ភាពសុខសាន្ត វឌ្ឍនភាព និងសេចក្តីសង្ឃឹមដែលយើងមាននៅពេលនេះ គឺជាលទ្ធផលដ៏វិសេសវិសាលនៃកម្លាំងសាមគ្គីរបស់ប្រជាជនយើង ដែលបានពុះពារប្តូរផ្តាច់ជម្នះរាល់ឧបសគ្គ ឈានឆ្ពោះទៅមុខមិនរាថយលើមាគ៌ាមួយដ៏ត្រឹមត្រូវ ។យើងទាំងអស់គ្នាប្តេជ្ញាការពារពង្រឹងពង្រីកសមិទ្ធផលទាំងនេះជារៀងដរាបហើយប្រឹងប្រែងបង្កើតសមិទ្ធផលថ្មីៗទៀត ដើម្បីកសាងអនាគតដ៏រុងរឿងរបស់មាតុភូមិយើង ។

ព្រឹត្តិការណ៍នយោបាយជាប្រវត្តិសាស្ត្រនាពេលថ្មីៗនេះ ដែលមានអត្ថន័យយ៉ាងសំខាន់ចំពោះដំណើរជាតិយើង គឺការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៥ នៃរដ្ឋសភា កាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កាលពីថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០១៤ ដែលបានប្រព្រឹត្តទៅដោយជោគជ័យ ស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់របស់កម្ពុជា នៅក្នុងបរិយាកាសសន្តិភាព និងមានលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ និងគ្មានអំពើហិង្សា ។ តាមរយៈជោគជ័យនៃការបោះឆ្នោតទាំងពីរនេះបានបង្ហាញថា ប្រជាធិបតេយ្យនៅកម្ពុជាកាន់តែត្រូវបានពង្រឹងពង្រីកឱ្យកាន់តែរឹងមាំទូលំទូលាយឡើងទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅក្នុងបរិបទនៃកម្ពុជា ។ សម្រាប់គណបក្សប្រជាជនកម្ពុជា ជ័យជម្នះក្នុងការបោះឆ្នោតទាំងពីរនេះបានបញ្ជាក់យ៉ាងច្បាស់ថា ប្រជាជននៅតែត្រូវការតួនាទីដឹកនាំរបស់គណបក្សតទៅមុខទៀត ទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងមូលដ្ឋាន ។ ឆ្លងតាមជ័យជម្នះនេះ បានបង្កលក្ខណៈអនុគ្រោះដល់គណបក្សដើម្បីបន្តអនុវត្តកម្មវិធី នយោបាយរបស់ខ្លួនឱ្យបានជោគជ័យ ។ ទន្ទឹមនេះ លទ្ធផលនៃការបោះឆ្នោតក៏បានបំបាក់នូវអំនួតរបស់អ្នកដឹកនាំគណបក្សខ្លះ ដែលតែងតែប្រើប្រាស់នយោបាយប្រជាភិថុតមួលបង្កាច់ការពិត និងបង្កបញ្ហាស្មុគស្មាញមិនចេះចប់ ដើម្បីវាយប្រហារមកលើគណបក្សប្រជាជនកម្ពុជា ។

*អង្គមីទិញ ជនរួមជាតិជាទីគោរពស្នេហា*

ពីការបោះឆ្នោតជាតិនីតិកាលទី ៥ មកដល់ពេលនេះ មានរយៈពេល ១១ ខែហើយ ។ ក្នុងរយៈពេលនេះ គណបក្សប្រជាជនកម្ពុជាដែលបានទទួលអាណត្តិស្របច្បាប់ពីប្រជាជនឱ្យដឹកនាំប្រទេសសម្រាប់ ៥ ឆ្នាំបន្តទៀត បានបំពេញនូវតួនាទី និងភារកិច្ចរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋជាម្ចាស់ឆ្នោត សម្រេចបានលទ្ធផលល្អជាបន្តបន្ទាប់លើគ្រប់វិស័យ ទោះបីជាគណបក្សសង្គ្រោះជាតិដែលមានអាសនៈក្នុងរដ្ឋសភាដែរ នោះបានធ្វើពហិការកិច្ចប្រជុំរដ្ឋសភារហូតមកក្តី ។ នៅក្នុងសកម្មភាពដែលផ្ទុយពីឆន្ទៈម្ចាស់ឆ្នោត គណបក្សនេះបានបដិសេធ មិនទទួលយកលទ្ធផលនៃការបោះឆ្នោត មួលបង្កាច់ភាពស្របច្បាប់របស់រដ្ឋសភា និងរាជរដ្ឋាភិបាលនីតិកាលទី ៥ ហើយជំរុញសកម្មភាពបាតុកម្មនៅតាមដងផ្លូវយ៉ាងអនាធិបតេយ្យ ប៉ុនប៉ងផ្លាស់ប្តូរសភាពការណ៍កម្ពុជាទៅតាមឆន្ទៈរបស់ខ្លួនដែលផ្ទុយពីរដ្ឋធម្មនុញ្ញ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ ។ គេមានគោលបំណងធ្វើឱ្យសង្គមកម្ពុជាត្រូវច្របូកច្របល់ រដ្ឋគ្មានប្រសិទ្ធភាព ទំនាក់ទំនងអន្តរជាតិចុះខ្សោយ សេដ្ឋកិច្ចដើរថយក្រោយ ហើយជីវភាពប្រជាជនកាន់តែលំបាកទៅ ដើម្បីរុញច្រានឱ្យគណបក្សប្រជាជនកម្ពុជាធ្លាក់ទៅក្នុងវិបត្តិនៃការដឹកនាំ ដោយត្រូវប្រជាជនខ្វះជំនឿលើការដឹកនាំតទៅទៀត ។ សកម្មភាពរបស់គេពិតជាបានបង្កការលំបាកដល់រាជរដ្ឋាភិបាលនៅដើមអាណត្តិនេះដែលកំពុងតែប្រឹងប្រែងរក្សាស្ថិរភាព និងកសាងជាតិលើគ្រប់វិស័យ ។ ប៉ុន្តែទង្វើ ប្រទូសរ៉ាយទាំងនេះមិនអាចបញ្ឈប់ដំណើរឈានទៅមុខរបស់ជាតិបានឡើយ ព្រោះថានិរន្តរភាពរបស់រដ្ឋ និងប្រក្រតីភាពនៃជីវភាពសង្គមសេដ្ឋកិច្ចរបស់ប្រជាជនត្រូវបានធានាយ៉ាងរឹងមាំ ។ ដូច្នេះ កម្ពុជាគ្មានភាពជាប់គាំងខាងនយោបាយឡើយ កម្ពុជាបានឈានចូលឆ្នាំ ២០១៤ ជាមួយនឹងលទ្ធផលដ៏ល្អនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមឆ្នាំ ២០១៣ ព្រមទាំងភាពអនុគ្រោះនៃទំនាក់ទំនងជាមួយបណ្តាប្រទេស និងដៃគូអភិវឌ្ឍន៍នានា ។ ផលិតផលក្នុងស្រុក សរុបរបស់កម្ពុជាឆ្នាំ ២០១៣ មានកំណើន ៧,៤% ហើយនៅឆ្នាំ ២០១៤នេះ យើងសង្ឃឹមថានឹងសម្រេចបានកំណើនជាង ៧% បន្តទៀត ។

ជាក់ស្តែង ក្នុងរយៈពេល៥ខែដើមឆ្នាំនេះ សេដ្ឋកិច្ចកម្ពុជាមានភាពល្អប្រសើរគួរឱ្យសោមនស្សរីករាយ ។ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចត្រូវបានធានា វិស័យហិរញ្ញវត្ថុមានស្ថិរភាពល្អ វិស័យផលិតកម្ម សេវាកម្ម អចលនទ្រព្យ ទេសចរណ៍ ពាណិជ្ជកម្ម វិស័យការងារ និងវិស័យផ្សេងៗទៀតកំពុងរីកចម្រើនតាមទិសដៅដ៏ល្អ ។ រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី បានចាត់វិធានការដ៏មុឺងម៉ាត់ ធានាជូនប្រជាជននូវស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដោយផ្អែកលើមូលដ្ឋានច្បាប់ និងការចូលរួមរបស់ប្រជាជនដែលបានបង្កលក្ខណៈអនុគ្រោះដល់ដំណើរការអភិវឌ្ឍន៍ និងកែលម្អជីវភាពរស់នៅរបស់ប្រជាជន ។

គណបក្សប្រជាជនកម្ពុជាគាំទ្រយ៉ាងពេញទំហឹងចំពោះការខិតខំរបស់រាជរដ្ឋាភិបាលនីតិកាលទី ៥ ក្នុងការជំរុញអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ ឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីសម្រេចនូវគោលដៅជាយុទ្ធសាស្ត្រទាំង ៤ គឺការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំប្រមាណ ៧% ប្រកបដោយចីរភាព , ការបង្កើតការងារឱ្យបានកាន់តែច្រើនជូនប្រជាជន ជាពិសេសសម្រាប់ស្រទាប់យុវជន , ការសម្រេចគោលដៅកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង ១% ក្នុង ១ ឆ្នាំ ក៏ដូចជាគោលដៅផ្សេងៗទៀតដែលត្រូវបានកំណត់ក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា ព្រមទាំងការពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

ដើម្បីធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ការលើកកម្ពស់ជីវភាពប្រជាជន និងការពង្រឹងយុត្តិធម៌សង្គម គណបក្សប្រជាជនកម្ពុជាប្តេជ្ញាបន្តអនុវត្តយ៉ាងដាច់ខាតនូវរាល់ទិសដៅកែទម្រង់នានាដែលបានកំណត់ក្នុងកម្មវិធីនយោបាយរបស់ខ្លួនឱ្យកាន់តែបានលឿន និងកាន់តែមានប្រសិទ្ធភាពថែមទៀត ដោយចាត់ទុកថា នេះជាការងារដែលមានអត្ថន័យសំខាន់បំផុតសម្រាប់គណបក្ស ។ ក្នុងស្មារតីនេះដែរ គណបក្សប្រជាជនកម្ពុជាគាំទ្រការប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការជំរុញដំណើរការកែទម្រង់ប្រព័ន្ធប្រាក់បៀវត្សប្រកបដោយសង្គតិភាព និងសមធម៌ សំដៅបង្កើនបៀវត្សរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធឱ្យបានកាន់តែប្រសើរឡើងជាលំដាប់ និងការជំរុញសកម្មភាពរបស់ក្រុមប្រឹក្សាការងារ ដើម្បីបន្តពិភាក្សារកដំណោះស្រាយដំឡើងប្រាក់ឈ្នួលអប្បបរមារបស់កម្មករ និយោជិតនៅតាមរោងចក្រ សហគ្រាសឱ្យទទួលបានលទ្ធផលល្អ ។ គណបក្សជំរុញការដោះស្រាយរបស់រាជរដ្ឋាភិបាល ក្នុងការផ្តល់ដីសម្បទានសង្គមកិច្ចជូនប្រជាជនដែលគ្មានដីពិតប្រាកដ ហើយត្រូវការដីដើម្បីសង់លំនៅស្ថាន និងបង្កបង្កើនផល ។ ជាមួយគ្នានេះ គណបក្សសូមអំពាវនាវដល់ប្រជាជននៅតាមតំបន់នានា សូមកុំធ្វើការទន្ទ្រានកាន់កាប់ដីគ្រប់ប្រភេទដោយខុសច្បាប់ដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម និរន្តរភាពនៃធនធានធម្មជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់យើង ។

គណបក្សប្រជាជនកម្ពុជាសូមវាយតម្លៃខ្ពស់ចំពោះការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល បណ្តាស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរគ្រប់ថ្នាក់ ក្នុងការទទួល និងជូនដំណើរប្រជាពលករយើងដែលវិលត្រឡប់ពីប្រទេសថៃមកវិញឱ្យបានទៅដល់លំនៅស្ថានដោយសុវត្ថិភាព ។ ទន្ទឹមនេះ គណបក្សសូមអំពាវនាវដល់ប្រជាពលករយើងសូមស្វែងរកការងារតាមសេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១៤ ស្តីពីការផ្តល់សេវាការងារ និងបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈជូនពលករខ្មែរ ហើយចៀសវាងការធ្វើចំណាកស្រុកខុសច្បាប់ទៅក្រៅប្រទេស ដែលមិនធានាដល់សុវត្ថិភាព ផលប្រយោជន៍ និងកិត្តិយសរបស់បងប្អូនឡើយ ។

គណបក្សប្រជាជនកម្ពុជា ជំរុញការលើកស្ទួយឥតឈប់ឈរនូវប្រជាធិបតេយ្យ និងសិទ្ធិមនុស្សក្នុងក្របខណ្ឌច្បាប់ ដែលផ្តល់ប្រយោជន៍ពិតប្រាកដដល់ប្រជាជនគ្រប់ស្រទាប់ ដល់គ្រប់កម្លាំងនយោបាយ និងដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកម្ពុជា ។ ទន្ទឹមនេះ យើងប្រឆាំងនឹងរាល់សកម្មភាពរបស់គណបក្ស ឬមជ្ឈដ្ឋានណាដែលប្រើផ្លាកប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ដើម្បីបម្រើតែផលប្រយោជន៍នយោបាយរបស់ខ្លួននោះ ។ គួរកត់សម្គាល់ថា

បច្ចុប្បន្នមានអ្នកដឹកនាំគណបក្សនយោបាយខ្លះ និងមជ្ឈដ្ឋានមួយចំនួន បាននិងកំពុងនិយាយអំពីប្រធានបទប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងប្រធានបទផ្សេងៗទៀតយ៉ាងពិរោះ ហាក់ដូចជាគេជាអ្នកគិតគូរណាស់ដល់ផលប្រយោជន៍របស់ជាតិ និងប្រជាជនកម្ពុជា តែធាតុពិតគេកំពុងតែភូតកុហកប្រជាជនឱ្យយល់ខុសអំពីការពិត បង្កជាបញ្ហាប្រឈមយ៉ាងច្រើនដល់រាជរដ្ឋាភិបាល និងអាជ្ញាធរនៅកន្លែងជាច្រើន ក្នុងគោលបំណងផ្តួលរំលំគណបក្សប្រជាជនកម្ពុជា ដែលរួមទាំងការប៉ុនប៉ងផ្តួលរំលំតាមរយៈរបស់ដែលហៅថា អំណាចប្រជាជន ទៀតផង។ នៅក្នុងបរិការណ៍នេះដែរ គណបក្សប្រជាជនកម្ពុជាសូមបញ្ជាក់នូវជំហររបស់ខ្លួនក្នុងការស្វាគមន៍ចំពោះការលើកទឹកចិត្តពីខាងក្រៅដល់ដំណើរការប្រជាធិបតេយ្យនីយកម្មនៅកម្ពុជា ក៏ដូចជាការដោះស្រាយបញ្ហាផ្ទៃក្នុងរបស់កម្ពុជា ប៉ុន្តែយើងមិនអាចទទួលយកនូវការលូកដៃជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជាបានឡើយ។ កម្ពុជាធ្លាប់ទទួលរងគ្រោះ និងបាត់បង់ធំធេងណាស់ដោយសារការជ្រៀតជ្រែកពីខាងក្រៅដែលជាមេរៀនដ៏ឈឺចាប់បំផុត ហេតុនេះយើងមិនទុកឱ្យប្រវត្តិសាស្ត្រដដែលអាចកើតមានជាថ្មីទៀតនៅលើមាតុភូមិយើងទេ។

គណបក្សប្រជាជនកម្ពុជា បន្តពង្រីកកិច្ចសហប្រតិបត្តិការយ៉ាងស្មោះសរជាមួយគ្រប់កម្លាំងនយោបាយ និងគ្រប់មជ្ឈដ្ឋានស្នេហាជាតិក្នុងសង្គម ដើម្បីពង្រឹងបរិយាកាសស្រុះស្រួលក្នុងសង្គមជាតិ ហើយប្រមូលរាល់ទស្សនៈ មតិ និងសកម្មភាពល្អៗពីគ្រប់ប្រភពដែលមានលក្ខណៈពហុភាព ពូនផ្តុំទៅជាចលនារួមនៃសង្គមក្នុងការកសាង និងការពារមាតុភូមិ។ យើងមានជំនឿថា គ្រប់គណបក្សនយោបាយ និងមជ្ឈដ្ឋាននានាក្នុងសង្គម ពិតជាយល់ច្បាស់អំពីសេចក្តីត្រូវការរបស់ប្រជាជន ខិតខំបង្កើនកិច្ចសហការ និងការយោគយល់គ្នា ហើយបន្តធ្វើអ្វីៗដែលជាគុណប្រយោជន៍ដល់ការថែរក្សាពូនជ្រំនូវសន្តិភាព ប្រជាធិបតេយ្យ និងជំរុញការអភិវឌ្ឍប្រទេសជាតិ។ នៅក្នុងចំណុចនេះដែរ គណបក្សប្រជាជនកម្ពុជាសូមទូលថ្វាយពិតពុទ្ធដីកា និងជម្រាបជូនជនរួមជាតិព្រមទាំងសហគមន៍អន្តរជាតិឱ្យបានជ្រាបថា ដើម្បីដោះស្រាយបញ្ហានយោបាយក្រោយពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៥ គណបក្សបានខិតខំជំរុញការចរចានៅគ្រប់កម្រិតជាមួយគណបក្សសង្គ្រោះជាតិប្រកបដោយភាពស្មោះត្រង់ និងមានសុឆន្ទៈពិតប្រាកដ។ ប៉ុន្តែរហូតមកដល់ពេលនេះ បញ្ហានៅតែពុំទាន់ត្រូវបានដោះស្រាយចប់នៅឡើយ អាស្រ័យដោយគណបក្សសង្គ្រោះជាតិគ្រាន់តែបានប្រើប្រាស់ដំណើរការចរចានេះដើម្បីរកចំណេញខាងសាធារណមតិប៉ុណ្ណោះ តែពុំមានឆន្ទៈដោះស្រាយបញ្ហាឡើយ។ ទោះបីជាដូច្នេះក្តី ក៏គណបក្សប្រជាជនកម្ពុជានៅតែបើកទ្វារចំហសម្រាប់ការចរចាឱ្យឈានទៅមុខទៀត ដោយឈរលើមូលដ្ឋានបន្តពីការជួបពិភាក្សារវាងសម្តេចតេជោ **ហ៊ុន សែន** និងឯកឧត្តម សម រង្ស៊ី កាលពីថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១៤ កន្លងទៅ។ ដំណោះស្រាយដែលនឹងអាចទទួលបាន គឺត្រូវតែផ្អែកលើមូលដ្ឋានរដ្ឋធម្មនុញ្ញ លទ្ធផលនៃការបោះឆ្នោត ហើយមិននាំប្រទេសជាតិទៅរកភាពជាប់គាំងខាងនយោបាយជាថ្មីទៀតនាពេលអនាគត ដូចដែលធ្លាប់បានកើតមានរួចមកហើយនោះទេ។

*អង្គមីទ្ទិញ ជនរួមជាតិជាទីគោរពស្នេហា*

បច្ចុប្បន្ន ប្រជាជាតិយើងកំពុងឈានទៅមុខប្រកបដោយថាមពល និងក្តីសង្ឃឹម ឆ្ពោះទៅរកអនាគតមួយដ៏ភ្លឺស្វាង ជាអនាគតដែលស្ថិតនៅក្នុងដៃរបស់យើងទាំងអស់គ្នា។ សន្តិភាព ប្រជាធិបតេយ្យ និងអភិវឌ្ឍន៍ឥឡូវនេះមិនមែនគ្រាន់តែជាបំណងប្រាថ្នានោះទេ តែជាការពិតដែលកំពុងតែកើតមានឡើង ហើយជាមាគ៌ាដ៏ត្រឹមត្រូវដែល នឹងនាំយើងឱ្យដើរទៅមុខបន្តទៀត។ រយៈពេល ១៥០ ឆ្នាំមកនេះ យើងមានពេលតិចណាស់ដែលជាឱកាសពេញលេញសម្រាប់អភិវឌ្ឍប្រទេសជាតិ ក្រៅពីនោះគឺជាពេលវេលាដែលត្រូវរងទុក្ខវេទនា និងការអាម៉ាស់ដោយការបាត់បង់ឥស្សរភាព ជាពេលវេលានៃសង្គ្រាមបំផ្លិចបំផ្លាញ និងជាពេលវេលានៃសោកនាដកម្មដែលពុំអាចនឹងពណ៌នាបាន។ ដូច្នេះ យើងមិនអាចឱ្យបាត់បង់ឱកាសតទៅទៀតទេ យើងត្រូវចេះក្តាប់ឱកាសសម្រាប់អភិវឌ្ឍខ្លួនឯង។ បើមិនដូច្នោះទេ យើងនឹងត្រូវជាប់ក្នុងខ្នោះឃ្នាងច្រវាក់នៃអស្ថិរភាព ការបែកបាក់ និងភាពក្រីក្រ ដែលមិនអាចនឹងមានថ្ងៃរំដោះខ្លួនឱ្យរួចបានឡើយ នេះជាហេតុផលសំខាន់បំផុត។ គណបក្សប្រជាជនកម្ពុជា សូមអំពាវនាវដល់ជនរួមជាតិទាំងមូល ដល់គ្រប់គណបក្ស និងមជ្ឈដ្ឋានទាំងឡាយក្នុងសង្គមទោះមាននិន្នាការនយោបាយផ្សេងៗគ្នាក្តីសូមចៀសវាងនូវអំពើណាដែលនាំទៅរកការបែកបាក់ហើយសូមធ្វើសកម្មភាពរួមគ្នាក្រោមដំបូលរដ្ឋធម្មនុញ្ញតែមួយ ដើម្បីប្រទេសជាតិយើងទាំងអស់គ្នា ។

***គណបក្សប្រជាជនកម្ពុជា ប្រសូតពីប្រជាជន គណបក្សស្រឡាញ់មាតុភូមិ និងប្រជាជន លើសអ្វីទាំងអស់***។ មិនថាពេលនេះ ឬតទៅមុខទៀតទេ គណបក្សនៅតែផ្សារភ្ជាប់ រួមសុខ រួមទុក្ខជាមួយប្រជាជនជានិច្ច។ ក្នុងស្មារតីនេះ ខ្ញុំសូមអំពាវនាវដល់គណៈកម្មាធិការគណបក្សនៅគ្រប់ថ្នាក់ គ្រប់ផ្នែក និងមន្ត្រីគណបក្សគ្រប់រូប សូមរក្សាខ្ជាប់នូវឧត្តមគតិស្នេហាជាតិ និងស្រឡាញ់ប្រជាជន ពង្រឹងសាមគ្គីភាព ខិតខំធ្វើតែអំពើល្អ ហើយជៀសវាងដាច់ខាតរាល់ទង្វើ មិនត្រឹមត្រូវដែលបំពានលើគោលការណ៍គណបក្ស និងច្បាប់រដ្ឋ ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍ប្រជាជន។ នេះមិនមែនគ្រាន់តែជាតម្រូវការទេ តែជាកាតព្វកិច្ច និងជាកត្តាកំណត់នៃជ័យជម្នះរបស់គណបក្សយើង។

ក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំសូមសម្តែងការគោរព និងការដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះជនរួមជាតិនៅគ្រប់ទិសទីដែលមានការជឿជាក់លើការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជាហើយសូមសន្យាជាឱឡារិកថាគណបក្សនឹងបន្តពុះពារអនុវត្តឱ្យបានជោគជ័យនូវកម្មវិធីនយោបាយរបស់ខ្លួនឆ្លើយតបទៅនឹងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជន ។

ជាទីបញ្ចប់ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមថ្វាយ ប្រគេនពរ និងប្រសិទ្ធពរជូន សម្តេច ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ សមាជិក សមាជិកានៃអង្គមីទ្ទិញ និងជនរួមជាតិទាំងអស់ សូមបានប្រកបពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

*សូមអរព្រះគុណ សូមអរគុណ*

# កម្ពុជា និងបង់ក្លាដែសបាននិងកំពុងអភិវឌ្ឍភាពជាដៃគូដ៏រឹងមាំ និងមានផលប្រយោជន៍ទៅវិញទៅមក



*លោកជំទាវ **ហ្សេក ហាស៊ីណា** ទទួលស្វាគមន៍យ៉ាងកក់ក្តៅចំពោះសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន***



*លោកជំទាវ **ហ្សេក ហាស៊ីណា** និងសម្តេចតេជោ **ហ៊ុន សែន** ក្នុងកិច្ចសវនាការ*

ចាប់ពីថ្ងៃទី ១៦-១៨ ខែមិថុនា ឆ្នាំ ២០១៤ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទៅបំពេញទស្សនកិច្ចនៅសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស ។ នេះជាលើកទី១នៃដំណើរបំពេញទស្សនកិច្ចផ្លូវការរបស់សម្តេចតេជោនៅបង់ក្លាដែស បន្ទាប់ពីប្រទេសទាំងពីរបានភ្ជាប់ទំនាក់ទំនងការទូតជាមួយគ្នាកាលពីថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ១៩៩៣ ។ គួរបញ្ជាក់ថា កាលពីខែមករា ឆ្នាំ ២០០១ លោកជំទាវ **ហ្សេក ហាស៊ីណា** នាយករដ្ឋមន្ត្រីបង់ក្លាដែសបានដឹកនាំគណៈប្រតិភូជាន់ខ្ពស់អញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការរយៈពេល៣ថ្ងៃនៅកម្ពុជា ។

ក្នុងពេលបំពេញទស្សនកិច្ចនៅបង់ក្លាដែស សម្តេចតេជោ **ហ៊ុន សែន** បានជួបធ្វើការចរចាផ្លូវការជាមួយ លោកជំទាវ **ហ្សេក ហាស៊ីណា** នាថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០១៤ ដោយបានពិភាក្សាគ្នាយ៉ាងស៊ីជម្រៅលើបញ្ហាជាច្រើនក្នុងក្របខណ្ឌទ្វេភាគី ពហុភាគី និងបញ្ហាតំបន់ដែលជាផលប្រយោជន៍ទៅវិញទៅមកក្នុងបរិយាកាសមិត្តភាព និងយោគយល់គ្នា ហើយក៏បានបញ្ជាក់សាជាថ្មីអំពីការប្តេជ្ញាចិត្តឱ្យស៊ីជម្រៅ និងពង្រឹងថែមទៀតនូវទំនាក់ទំនងទ្វេភាគីដែលមានឫសគល់នៃការតភ្ជាប់ប្រវត្តិសាស្រ្ត សាសនា និងវប្បធម៌រួមរវាងប្រទេសទាំងពីរ ។ លោកជំទាវ **ហ្សេក ហាស៊ីណា** បានអបអរសាទរសម្តេចតេជោ **ហ៊ុន សែន** ចំពោះជ័យជម្នះរបស់គណបក្សប្រជាជនកម្ពុជាក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៥ នៃរដ្ឋសភាកាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣ និងការតែងតាំងសម្តេចតេជោសាជាថ្មីជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

សម្តេចតេជោ **ហ៊ុន សែន** ក៏បានអបអរសាទរលោកជំទាវ **ហ្សេក ហាស៊ីណា** ចំពោះជ័យជំនះរបស់គណបក្សសម្ព័ន្ធអាវ៉ាមីបង់ក្លាដែស ក្នុងការបោះឆ្នោតរដ្ឋសភាលើកទី ១០ កាលពីថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០១៤ និងការតែងតាំងលោកជំទាវសាជាថ្មីជានាយករដ្ឋមន្ត្រីបង់ក្លាដែស ។

លោកជំទាវ **ហ្សេក ហាស៊ីណា** បានចាត់ទុកទស្សនៈកិច្ចរបស់សម្តេចតេជោថាបានផ្តល់សន្ទុះមួយថ្មីទៀត ចំពោះទំនាក់ទំនងទ្វេភាគីដ៏ល្អប្រសើរដែលមានស្រាប់ និងបានអបអរសាទរចំពោះសមិទ្ធផលរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម ក្រោមការដឹកនាំរបស់សម្តេចតេជោ និងបានកត់សម្គាល់ដោយក្តីរីករាយចំពោះតួនាទីដឹកនាំ និងការរួមចំណែកដ៏សំខាន់របស់កម្ពុជាក្នុងអាស៊ាន ។ លោកជំទាវ **ហ្សេក ហាស៊ីណា** ក៏បានថ្លែងអំណរគុណសម្តេចតេជោ **ហ៊ុន សែន** ចំពោះការគាំទ្របេក្ខភាពរបស់បង់ក្លាដែសដែលជាសមាជិកកិច្ចប្រជុំអាស៊ី-អឺរ៉ុប(ASEM)ផងដែរ ។ សម្តេចតេជោ **ហ៊ុន សែន** បានស្វាគមន៍នូវកិច្ចសហប្រតិបត្តិការ និងការចូលរួមយ៉ាងជិតស្និទ្ធរបស់បង់ក្លាដែស ជាមួយរដ្ឋជាសមាជិកអាស៊ាន និងបានទទួលស្គាល់ចំពោះការយកចិត្តទុកដាក់យ៉ាងខ្លាំងរបស់បង់ក្លាដែសក្នុងការបង្កើនទំនាក់ទំនងដល់កម្រិតភាពជាដៃគូសន្ទនារបស់អាស៊ាន និងបានទទួលដឹងឮនូវសំណើរបស់បង់ក្លាដែស ដែលស្នើសុំចូលរួមក្នុងកិច្ចសហប្រតិបត្តិការ មេគង្គ-គង្គា ហើយនឹងពិចារណាដោយភាពអនុគ្រោះ ។ សម្តេចតេជោក៏បាន អបអរសាទរចំពោះជោគជ័យដ៏ធំធេងក្នុងវិស័យសេដ្ឋកិច្ច និងសង្គមរបស់បង់ក្លាដែស ហើយបានកោតសរសើរចំពោះការដឹកនាំរបស់លោកជំទាវនាយករដ្ឋមន្ត្រីប្រកបដោយចក្ខុវិស័យ និងថាមពល ឆ្ពោះទៅកាន់ការអភិវឌ្ឍជាតិ លើកកម្ពស់សន្តិភាព ស្ថិរភាព និងការរីកចម្រើននៅថ្នាក់តំបន់ និងសកលលោក ។

ថ្នាក់ដឹកនាំទាំងពីរបានកត់សម្គាល់ដោយក្តីពេញចិត្តថាកម្ពុជា និងបង់ក្លាដែស បាននិងកំពុងអភិវឌ្ឍភាពជាដៃគូដ៏រឹងមាំនិងមានផលប្រយោជន៍ទៅវិញទៅមកក្នុងកម្រិតទ្វេភាគី ពហុភាគី និងតំបន់ ព្រមទាំងកំពុងធ្វើការជាមួយគ្នាយ៉ាងជិតស្និទ្ធ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការតំបន់ឱ្យកាន់តែខ្លាំងក្លា ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម សន្តិភាព និងស្ថិរភាពក្នុងតំបន់ ។ មេដឹកនាំទាំងពីរបានទទួលស្គាល់ពីសារៈសំខាន់ និងផលប្រយោជន៍នៃការពិគ្រោះយោបល់ទៀងទាត់ទ្វេភាគីដើម្បីពិនិត្យឡើងវិញ និងស្វែងរកវិធីក្នុងការពង្រីក និងធ្វើឱ្យស៊ីជម្រៅនូវទំនាក់ទំនងទ្វេភាគីរវាងប្រទេសទាំងពីរ ។ឯកភាពបង្កើតគណៈកម្មការចម្រុះដើម្បីកំណត់វិស័យថ្មីៗ សម្រាប់កិច្ចសហប្រតិបត្តិការ ព្រមទាំងសម្របសម្រួល និងធ្វើឱ្យស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការដែលមានស្រាប់លើវិស័យនានា ។ឯកភាពបង្កើតក្រុមប្រឹក្សាពាណិជ្ជកម្មចម្រុះដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនៃប្រទេសទាំងពីរ យោងតាមស្មារតីមាត្រាទី ៧ នៃ



*សម្តេចតេជោ **ហ៊ុន សែន** ចូលរួមក្នុងពិធីជប់លៀងដែលរៀបចំដោយ សហព័ន្ធសភាពាណិជ្ជកម្ម និងឧស្សាហកម្មបង់ក្លាដែស*

កិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ។ សម្តេចតេជោ **ហ៊ុន សែន** បានស្វាគមន៍ចំពោះគោលបំណងរបស់បង់ក្លាដែស ក្នុងការរៀបចំពិព័រណ៍បង់ក្លាដែសនៅកម្ពុជានា ឆ្នាំ ២០១៥ ខាងមុខ ។ នាយករដ្ឋមន្ត្រីទាំងពីរបានបញ្ជាក់អំពីការចាំបាច់ពង្រឹងទំនាក់ទំនងរវាងសហគមន៍ធុរកិច្ចនៃប្រទេសទាំងពីរ ដោយលើកទឹកចិត្តវិស័យឯកជនឱ្យរៀបចំកិច្ចសម្របសម្រួលរវាងសភាពាណិជ្ជកម្មនៃប្រទេសទាំងពីរ ដើម្បីប្រើប្រាស់សក្តានុពលពាណិជ្ជកម្មទ្វេភាគី ហើយក៏បានសង្កត់ធ្ងន់ផងដែរទៅលើការធ្វើវិនិយោគទៅវិញទៅមក ។ ឯកភាពក្នុងការធ្វើឱ្យស៊ីជម្រៅនូវទំនាក់ទំនងផ្នែកវប្បធម៌ អប់រំ រវាងប្រទេសទាំងពីរតាមរយៈកម្មវិធីផ្លាស់ប្តូរវប្បធម៌និងអប់រំដើម្បីធ្វើឱ្យប្រជាជននៃ ប្រទេសទាំងពីរកាន់តែយល់គ្នាថែមទៀត ។លើកទឹកចិត្តឱ្យមានទំនាក់ទំនងកម្រិតខ្ពស់ ដើម្បីធ្វើឱ្យការយល់គ្នាទៅវិញទៅមក និងមិត្តភាព រវាងប្រជាជននៃប្រទេសទាំងពីរកាន់តែប្រសើរឡើង ជាពិសេសមន្ត្រីនយោបាយជាន់ខ្ពស់របស់រដ្ឋាភិបាល ក៏ដូចជារវាងបញ្ញវន្ត អ្នកសារព័ត៌មាន យុវជន កីឡាករ និងមន្ត្រីជំនាញវប្បធម៌ ។ល។

ភាគីទាំងពីរបានសម្តែងការពេញចិត្តចំពោះកម្រិតនៃកិច្ចសហប្រតិបត្តិការដែលមានស្រាប់រវាងប្រទេសទាំងពីរនៅលើវេទិកាអន្តរជាតិនានា និងឯកភាពគ្នាក្នុងការជំរុញកិច្ចសហប្រតិបត្តិការឱ្យបានជិតស្និទ្ធលើបញ្ហាជាផលប្រយោជន៍ទៅវិញទៅមក នៅក្នុងក្របខណ្ឌអង្គការសហប្រជាជាតិ ចលនាមិនចូលបក្សសម្ព័ន្ធ អង្គការពាណិជ្ជកម្មពិភពលោក និងវេទិកាអន្តរជាតិដទៃទៀត ។ សម្តេចតេជោ **ហ៊ុន សែន** និងលោកជំទាវ **ហ្សេក ហាស៊ីណា** បាន ឯកភាពគ្នាថាដំណើរការបច្ចុប្បន្ននៃសកលភាវូបនីយកម្មកំពុងតែពង្រីកគម្លាតរវាងអ្នកមាននិងអ្នកក្រនៅលើពិភពលោកដូច្នេះហើយបានឯកភាពគ្នាថា ត្រូវតែមានវិធានការបន្ទាន់មួយដើម្បីកាត់បន្ថយគម្លាតនៃការអភិវឌ្ឍន៍នេះ ហើយក៏បានគាំទ្រចំពោះការអំពាវនាវទៅកាន់បណ្តាប្រទេសអភិវឌ្ឍន៍ឱ្យផ្តល់នូវការលើកលែងពន្ធ និងកំណត់កូតាចំពោះការនាំចូលផលិតផលនិងសេវាកម្មពីបណ្តាប្រទេសមានការអភិវឌ្ឍតិចតួច ដើម្បីធានាឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព ។

ក្នុងឱកាសទស្សនកិច្ចនេះនាយករដ្ឋមន្ត្រីទាំងពីរបានស្វាគមន៍និងធ្វើជាសាក្សីក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនិងអនុស្សរណៈដូចខាងក្រោម :

១-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស ស្តីពីការបង្កើតគណៈកម្មការចម្រុះសម្រាប់ជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី ។

២-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស ស្តីពីការជំរុញនិងការការពារវិនិយោគ ។

៣-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស ស្តីពីកិច្ចសហប្រតិបត្តិការវប្បធម៌ ។

៤-អនុស្សរណៈនៃការយោគយល់រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស ស្តីពីកិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកទេសក្នុងវិស័យកសិកម្ម ។

ដោយឡែកនៅថ្ងៃទី ១៦ ខែមិថុនា សហព័ន្ធសភាពាណិជ្ជកម្ម និងឧស្សាហកម្មបង់ក្លាដែសបានរៀបចំពិធីជប់លៀងជូនសម្តេចតេជោ **ហ៊ុន សែន** និងសមាជិកគណៈប្រតិភូ ដែលក្នុងឱកាសនោះសម្តេចតេជោបានថ្លែងថា កម្ពុជា-បង់ក្លាដែសត្រូវតែក្លាយជាដៃគូដ៏ល្អក្នុងបញ្ហាពាណិជ្ជកម្ម វិនិយោគ និងវិស័យដទៃទៀត ដែលយើងត្រូវធ្វើការជាមួយគ្នាក្នុងភាពជាដៃគូជិតស្និទ្ធបំផុត និងសង្ឃឹមថា សេដ្ឋកិច្ចរបស់ប្រទេសទាំងពីរនឹងមានកំណើនខ្ពស់ក្នុងពេលអនាគតដ៏ខ្លី ។ សម្តេចតេជោថ្លែងទៀតថា យើងពិតជាមានតម្រូវការចាំបាច់ក្នុងការធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នា បំពេញឱ្យគ្នាទៅវិញទៅមក និងរួមគ្នាដើម្បីធ្វើកិច្ចការនៅក្នុងវេទិកាពហុភាគីពាក់ព័ន្ធ ជាមួយនឹងការលើកកម្ពស់ការធ្វើដំណើរឆ្ពោះទៅមុខជាមួយបណ្តាប្រទេសដែលមានកម្រិតអភិវឌ្ឍន៍តិចតួច ។ បន្ទាប់ពីដំណើរទស្សនកិច្ចរបស់សម្តេចមកកាន់បង់ក្លាដែសនាពេលនេះ បណ្តាស្ថាប័នដែលមានការពាក់ព័ន្ធដែលក្នុងនោះមានវិស័យឯកជនដែរ ត្រូវសម្លឹងរកមើលលទ្ធភាពទាំងអស់ដែលអាចធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នាបាន ។ ក្នុងពេលនោះ ដែរឯកឧត្តមប្រធានសហព័ន្ធសភាពាណិជ្ជកម្ម និងឧស្សាហកម្ម និងឯកឧត្តមរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មបង់ក្លាដែសបានថ្លែងអំពីភ័ព្វវាសនាដ៏ខ្ពង់ខ្ពស់ដែលបានជួបសន្ទនាដោយផ្ទាល់ជាមួយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ដែលជាអ្នកដឹកនាំនយោបាយ និងសេដ្ឋកិច្ចដ៏ឆ្នើមបំផុតរបស់ប្រទេសកម្ពុជា ហើយបានបញ្ជាក់យ៉ាងច្បាស់ថា ប្រទេសយើងទាំងពីរ កម្ពុជា-បង់ក្លាដែស មានសក្តានុពលខ្លាំងណាស់ក្នុងការធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នាលើគ្រប់វិស័យទាំងអស់ ពិសេសទំនាក់ទំនងពាណិជ្ជកម្ម ទេសចរណ៍ និងការផ្លាស់ប្តូរវប្បធម៌ទៅវិញ ទៅមក ។

ក្នុងឱកាសបំពេញទស្សនកិច្ចនោះដែរសម្តេចតេជោ **ហ៊ុន សែន** និងគណៈប្រតិភូ បានអញ្ជើញទៅទស្សនាតំបន់ពាណិជ្ជកម្ម និងឧស្សាហកម្មក្នុងទីក្រុងដាកា អញ្ជើញទស្សនា និងដាក់កម្រងផ្កានៅវិមានយុទ្ធជនពលីក្នុងទីក្រុងដាកា ។ សម្តេចបានចុះហត្ថលេខាលើសៀវភៅក្រាំងមាសដើម្បីទុកជាអនុស្សាវរីយ៍ជាប្រវត្តិសាស្ត្រនៅក្នុងវិមានយុទ្ធជនពលី ។សម្តេចតេជោក៏បានអញ្ជើញទៅទស្សនាវត្តបុរាណមានឈ្មោះថា ឧហារមាញិកា ដែលទីអារាមនេះមានអាយុកាលដ៏យូរលង់ណាស់មកហើយ ។ បច្ចុប្បន្នទីអារាមនេះមានព្រះសង្ឃគង់ប្រថាប់សិក្សារៀនសូត្រជាង ៦៧០ អង្គ ដែលសុទ្ធសឹងជាព្រះសង្ឃក្រីក្រ រួមទាំងកុមារកំព្រាក្រីក្រជាច្រើននាក់ផងដែរ ។ សម្តេចតេជោ **ហ៊ុន សែន** បានប្រគេននូវបច្ច័យចំនួន ១ ម៉ឺនដុល្លារអាមេរិកដល់ព្រះគ្រូចៅអធិការដើម្បីទុកកសាងសមិទ្ធផលនានាក្នុងទីអារាមជាទីគោរពសក្ការៈនោះ ។/

# សម្ដេចតេជោបញ្ជាក់អំពីជំហរក្នុងការចរចា ការពង្រឹងនិរន្តរភាពរបស់រដ្ឋ និងជីវភាពសេដ្ឋកិច្ច សង្គម

## • ប្រែក្លាយការលំបាកពីការវិលត្រឡប់របស់ពលករយើងទៅជាកាលានុវត្តភាពថ្មី

➲ ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៤ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** បានអញ្ជើញជួបសំណេះសំណាលជាមួយយោធិនពិការនៅមណ្ឌលជនពិការ ៣១៧ តាកែនកោះស្លា ស្ថិតនៅភូមិតេជោអភិវឌ្ឍន៍ ឃុំតេជោអភិវឌ្ឍន៍ ស្រុកឈូក ខេត្តកំពត។ ការអញ្ជើញទៅទីនោះបន្ទាប់ពីមានការផ្សព្វផ្សាយនូវព័ត៌មានចចាមអារាមដ៏អាក្រក់ទាក់ទងដល់សុខភាពរបស់សម្ដេចតេជោ។ ពីទីនោះដែរ សម្ដេចបានផ្ញើសារនយោបាយមួយចំនួនទៅកាន់មេបក្សប្រឆាំងនៅកម្ពុជា និងជនបរទេសខ្លះដែលតែងតែមានគំនិតអគតិចំពោះរាជរដ្ឋាភិបាលកម្ពុជា។

សម្ដេចបានមានប្រសាសន៍ថា "ព្រឹកមិញនេះព័ត៌មាននៅអូស្ត្រាលីថាខ្ញុំបានស្លាប់បាត់ទៅហើយ ហើយម្សិលម៉្ងៃ និងម្សិលមិញគេថា ខ្ញុំបានដាច់សរសៃឈាមខួរក្បាល។ តែព្រឹកមិញនេះ ដំបូងមានទូរស័ព្ទមកតែលើកមិនទាន់ គេ SMS មកថាខ្ញុំស្លាប់បាត់ទៅហើយ ។ នៅក្នុងកាសែតឌឺយែមបូឌាដេលីមេបក្សមួយនោះបាននិយាយ។ ខ្ញុំទទួលព័ត៌មានមកអីចឹង។ ខ្ញុំសូមផ្ដាំទៅវិញថា គិតធ្វើម៉េចថែទាំសុខភាពខ្លួនឯងឱ្យបានល្អទៅ។ កុំទៅលោតពីលើទូកឱ្យគ្រេចជើងអី ។ ក្នុងឋានៈជាមនុស្សគួរតែមានការចេះដឹងកុំទៅបន់ឱ្យគេស្លាប់ បន់ឱ្យគេរស់ទៅ។

សម្ដេចបានបន្តថាគេកំពុងត្រូវការ **ហ៊ុនសែន** ដើម្បីគ្រប់គ្រងសភាពការណ៍ ព្រោះអ្នកមានលទ្ធភាពបញ្ជាកម្លាំងសរុបបានគឺមានតែម្នាក់ហ្នឹង។ រដ្ឋមន្ត្រីការពារជាតិមិនអាចបញ្ជាលើកម្លាំងប៉ូលិស ឬរដ្ឋបាលស៊ីវិលបាន។ រដ្ឋមន្ត្រីមហាផ្ទៃក៏មិនអាចបញ្ជាលើកម្លាំងទាហានបានដែរ។ ដូច្នេះសូមផ្ដាំបើមានករណីអីចឹងមែនគួរតែ ត្រៀមខ្លួនឱ្យស្រួល ក្រែងលោវាមានរឿងជាយថាហេតុអ្វីកើតឡើងហើយគ្រោះថ្នាក់ដល់ខ្លួនឯង។ សភាពការណ៍នៅកម្ពុជាត្រូវការបុគ្គលដែលអាចគ្រប់គ្រងសភាពការណ៍បាន សូម្បីជនបរទេសក៏នៅមានល្បួចខ្សិបខ្សៀវគ្នាថា ពេលនេះអត់ **ហ៊ុន សែន** មិនទាន់បានទេ ។ ដូចនេះសូមកុំភាន់ច្រឡំ ហើយសូមកុំបន់ឱ្យ **ហ៊ុន សែន** ស្លាប់ ។សម្ដេចបានបញ្ជាក់ថា ត្រូវមើលរដ្ឋធម្មនុញ្ញឱ្យច្បាស់បើតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ គណៈរដ្ឋមន្ត្រីមួយត្រូវរៀបចំឡើងវិញ មិនមែននាយករដ្ឋមន្ត្រី **ហ៊ុន សែន** ស្លាប់ទៅអាចមានឧបនាយករដ្ឋមន្ត្រីមកធ្វើជានាយករដ្ឋមន្ត្រីស្ដីទីបានឡើយ។ ដូច្នេះមានអ្នកណាគ្រប់គ្រងសភាពការណ៍......។

សម្ដេចបានបន្ថែមថា "ខ្ញុំផ្ដាំត្រឡប់ទៅវិញទៅកុំបន់ឱ្យខ្ញុំងាប់ ហើយម្យ៉ាងទៀតពូជរបស់ខ្ញុំនេះអត់មានពូជក្បត់ជាតិ។ អីចឹងកុំរំពឹងចាំឱ្យ **ហ៊ុន សែន** ស្លាប់នោះគឺមិនងាយទេ។ធ្វើនយោបាយអីក៏យ៉ាប់ម្លេះ? ចាញ់ឆ្នោតឡាំប៉ាមិនព្រមទទួលស្គាល់លទ្ធផលបោះឆ្នោតម្ដងណាទេ។ ធ្វើអីគេមិនកើតបន់ឱ្យគេងាប់"។

ពាក់ព័ន្ធនឹងទង្វើរបស់គណបក្សប្រឆាំងដែលបង្កភាពស្មុគស្មាញមិនចេះចប់តាំងពីក្រោយការបោះឆ្នោតមកនោះ សម្ដេចបានបញ្ជាក់ថា "អស់លោកឱ្យល្មមកុំចង់សាក។ បណ្ដោយលោកឯងប៉ុន្នានរយៈមកហើយ។ លោកល្មមបានហើយ។ បើលោកចង់ដឹង តម្រូវការតែ ៤៨ ម៉ោងទេគ្រប់គ្រាន់ និយាយឱ្យលោកឯងច្បាស់"។ អីក៏ខូចម្លេះ ចរចាៗ ចរចាត្រូវគ្នាហើយទាត់ចោលលទ្ធផលចរចា ដូរអ្នកចរចា ។ កុំលេងចរចារួចហើយបោះបង់ចោលលទ្ធផលចរចា រួចដូរតួអង្គចរចា រួចប្ដូរប្រធានបទ។ អត់លេងជាមួយទេ ។ កិច្ចព្រមព្រៀងទីក្រុងប៉ារីសដែលគេបង្កើតមកគេបង្កើតមួយតង់ៗរហូតដល់មានកិច្ចព្រមព្រៀងចុងក្រោយ ។ គេអត់មានបោះបង់ចោលមួយគន្លាក់ណាទេ ។ឥឡូវខ្ញុំប្រាប់លោកឯងឱ្យច្បាស់ លោកឯងមានសិទ្ធិធ្វើបាតុកម្ម ខាងនេះក៏មានសិទ្ធិធ្វើបាតុកម្ម។ និយាយឱ្យច្បាស់កុំឱ្យស្អឹឡើងគំរាមធ្វើបាតុកម្ម ។ ព្រោះមានសិទ្ធិដូចគ្នាទេ។



*សម្ដេចតេជោ **ហ៊ុន សែន** និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ក្នុងឱកាសអញ្ជើញជួបសំណេះសំណាលជាមួយយោធិនពិការនៅមណ្ឌលជនពិការ ៣១៧ តាកែនកោះស្លា ស្ថិតនៅភូមិតេជោអភិវឌ្ឍន៍ ឃុំតេជោអភិវឌ្ឍន៍ ស្រុកឈូក ខេត្តកំពត*

ដោយឡែកទាក់ទងដល់កាចរចានោះដែរ សម្ដេចតេជោបានមានប្រសាសន៍ថា "ពាក្យថាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាស្ថាប័នធម្មនុញ្ញ។ សម្ដេចមិនដែលឮទេ។ បើមានចែងក្នុងរដ្ឋធម្មនុញ្ញសម្ដេចឮតែនេះ មិនដែលមានទេ។ តែទោះជាយ៉ាងនេះក្ដីក៏សម្ដេចបានបញ្ជាក់ថា ឥឡូវគណបក្សប្រជាជនកម្ពុជាឯកភាព ហើយឱ្យដាក់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទៅក្នុងជំពូកទី ១៥ នៃរដ្ឋធម្មនុញ្ញ ដោយបន្ថែមមួយជំពូកទៀត ហើយធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ។ ជំពូកទី ១៥ ចែងពីតួនាទីភារកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងរបៀបជ្រើសតាំង។ លោកឯងចង់បានអាហ្នឹងគឺដាក់ចូល វាអត់លំបាកទេ ប៉ុន្តែលោកឯងកុំជ្រុលទាញទៅរកការញែកអំណាចក្រុមប្រឹក្សាធម្មនុញ្ញ ឬប៉ះពាល់ដល់កន្លែងផ្សេងគឺមិនបានទេ" ។ សម្ដេចបានរំឭកថា សម្ដេចបានទូលព្រះមហាក្សត្រដោយត្រង់ថាសភាពការណ៍នៅកម្ពុជាមាន ៣ យ៉ាង ។ប៉ុន្តែខ្ញុំប្រាប់ ២ ចំណុចឱ្យលោកឯងដឹង។ ទី ១.លោកឯងចូលរួមគឺល្អ។ ទី២. លោកឯងមិនចូល ខ្ញុំនៅតែធ្វើអីចឹងរហូតដល់ឆ្នាំ ២០១៨។ តែបោះឆ្នោតឡើងវិញវាគ្មានអ្នកណាធ្វើតាមលោកឯងទេ។ ប្រទេសជិតខាងយើងយោធាកាន់អំណាច ចាប់អ្នកចេញពីការបោះឆ្នោតម៉េចក៏គេធ្វើបាន។ នៅអេ-




*សម្តេចតេជោ **ហ៊ុន សែន** ក្នុងឱកាសអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងទិវាអន្តរជាតិប្រយុទ្ធ ប្រឆាំងគ្រឿងញៀននៅកោះពេជ្រ*

ហ្ស៊ីបគេចាប់ប្រធានាធិបតីចេញពីការបោះឆ្នោត ហើយគេឡើងធ្វើប្រធានាធិបតីខ្លួនឯង ។ឯយើងនេះចេញពីការបោះឆ្នោត ឈ្នះឆ្នោត ឆ្លងកាត់រដ្ឋសភា ព្រះមហាក្សត្របានតែងតាំង ម៉េចដោះស្រាយបញ្ហាមិនបាន? ។ លោកឯងចង់នៅខាងក្រៅនៅទៅ ព្រោះនៅស្រុកខ្មែរពុំមានច្បាប់ឱ្យសែង លោកឯងចូលរដ្ឋសភាទេ ។ លោកឯងនៅខាងក្រៅនៅទៅ តែកុំមកបន្ទោសគេ ហើយបបួលគេឱ្យបោះឆ្នោតឡើងវិញ ។

សម្តេចបន្តថា សម្តេចបានប្រាប់ហើយតាំងពីថ្ងៃចរចាដំបូងនៅថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០១៣ថា សម្តេចពុំមានសិទ្ធិជជែកជាមួយអស់លោកជាមេដឹកនាំគណបក្សប្រឆាំងទេរឿងបោះឆ្នោត ព្រោះក្រុមប្រឹក្សាធម្មនុញ្ញបានកាត់ក្តីបិទផ្លូវតវ៉ាហើយ ។ បើសម្តេចជជែករឿងហ្នឹងគឺមានទោស ។ អស់លោកបបួលបោះឆ្នោតឡើងវិញ តើអ្នកណាបោះ? មានច្បាប់ពីណាសម្រាប់បោះឆ្នោតឡើងវិញ ។ បើអស់លោកចង់ធ្វើប្រជាមតិអស់លោកត្រូវចូលសភាដែរ ដើម្បីពិភាក្សាគ្នាថាតើ ធ្វើច្បាប់ប្រជាមតិ ឬមិនធ្វើ? ។

សម្តេចបានបន្តថា ម្នាក់នោះខាងផ្លូវច្បាប់មិនទាន់រួចខ្លួនទេ ។ នេះមិនមែនជាការគំរាមទេ តែការពិតគឺវាអ៊ីចឹង ។ ឯកសារមានចងក្រងគ្រប់ ។ ពេលមានការចាំបាច់អស់លោកអត់ស្កុះរួចទេ ។ គ្មានការចាំបាច់ទៅសុំពីរដ្ឋសភាលើកអភ័យឯកសិទ្ធិនោះដែរ បើមានដីកាតុលាការគឺត្រូវតែអនុវត្ត ។និយាយអ៊ីចឹងមិនមែនមានន័យថា រៀបចំចរចា តែគំរាមចាប់ខ្លួននោះទេ ។ គេមិនចាប់ គេទុកឱ្យខ្លួនមកចរចាតែយូរទៅព្រហើនទៅៗ ។

សម្តេចបានសង្កត់ធ្ងន់ថា សម្តេចការពាររដ្ឋធម្មនុញ្ញ ការពារជាតិ សាសនា ព្រះមហាក្សត្រ ។ បោះឆ្នោតមួយឆ្នាំហើយកុំបន្តឃោសនាតទៅទៀត ។ ចាំដល់ឆ្នាំ ២០១៨ ចាំឃោសនា ។ សូមកុំឃើញនៅប្រទេសអេហ្ស៊ីបគេធ្វើបាន ទុយណេស៊ី លីប៊ីគេធ្វើបានហើយចង់ធ្វើតាម ។ប៉ុន្តែទីនេះគឺកម្ពុជា ។ កុំថានៅបាងកកគេធ្វើបាន នៅកម្ពុជាក៏ចង់ធ្វើដែរ ។ មួយជាប្រទេសថៃ មួយជាកម្ពុជា ។ មួយជា **យីង ឡាក់** មួយជា **ហ៊ុន សែន** ។ គឺខុសគ្នា ។ សម្តេចបញ្ជាក់ថា "ខ្ញុំសូមប្រាប់ឱ្យច្បាស់ប្រដៅឱ្យចំហើយអស់លោកបរទេសសូមនៅឱ្យស្ងៀម ។ កិច្ចការផ្ទៃក្នុងកម្ពុជាទុកឱ្យកម្ពុជាដោះស្រាយ ។ លើកទឹកចិត្តទទួលបាន ប៉ុន្តែជ្រៀតជ្រែកមិនអាចទទួលយកបានទេ" ។

នៅទីនោះសម្តេចក៏បានគូសបញ្ជាក់ជាលើកដំបូងផងដែរ ទាក់ទងទៅនឹងទូរទស្សន៍ដែលគណបក្សប្រឆាំងតែងតែនិយាយ និងទាមទារចង់បានដោយមានប្រសាសន៍ថា គណបក្សប្រឆាំងចង់បង្កើតទូរទស្សន៍ យើងបានឱ្យគេសរសេរជាលិខិតមកដោយឱ្យក្រុមហ៊ុនមួយសរសេរជាលិខិតសុំបង្កើតទូរទស្សន៍ ។ សម្តេចបានឱ្យតាំងពីមុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្តម្ល៉េះ ។នៅថ្ងៃទី៩ខែឧសភា ពេលពិភាក្សាតាមទូរស័ព្ទសម្តេចបានប្រាប់ថា គណបក្សបង្កើតមិនបានទេ ព្រោះស្រុកខ្មែរមាន ៥០ ទៅ ៦០ គណបក្ស ។ ដូចនេះបើគណបក្សមួយទូរទស្សន៍មួយគឺទៅមិនរួចទេ ។ ប៉ុន្តែសុំឱ្យគណបក្សនេះបង្កើតជាក្រុមហ៊ុនមួយទៅ ហើយទៅចុះបញ្ជីពាណិជ្ជកម្មឱ្យបានត្រឹមត្រូវ ។ សម្តេចបានបន្តថា " ខ្ញុំក៏បានសួរទៅលោក **ខៀវ កាញារីទ្ធ** (រដ្ឋមន្ត្រីក្រសួងព័ត៌មាន)ទៀតថា អាចចែកមួយចំណែកពីប្រេកង់ទូរទស្សន៍ជាតិមកឱ្យគាត់បង្កើត (គណបក្សប្រឆាំង) ។

សម្តេចក៏បានរំឭកថា ទូតអាមេរិកបានប្រាប់ឯកឧត្តម **ស ខេង** ថា ប្រសិនជារាជរដ្ឋាភិបាលឱ្យគណបក្សប្រឆាំងបង្កើតទូរទស្សន៍ គេនឹងដោះស្រាយភ្លែតតែម្តង យើងឱ្យហើយតែគេមិនព្រមសរសេរសំបុត្រមកតើឱ្យធ្វើម៉េច ? ។

ឆ្លងតាមសកម្មភាពប្រទូសរ៉ាយឥតឈប់ឈរ និងការចូលរួមកិច្ចចរចាជាបន្តបន្ទាប់របស់គណបក្សប្រឆាំង ដោយគ្មានសុឆន្ទៈ និងភាពស្មោះត្រង់ដូច្នេះសម្តេចបានធ្វើការកត់សម្គាល់ថា "គណបក្សប្រឆាំងគ្មានចេតនាដោះស្រាយបញ្ហានោះទេ" ។

➲នៅថ្ងៃទី២៦ខែមិថុនាឆ្នាំ២០១៤ថ្លែងនៅក្នុងទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននៅកោះពេជ្រ សម្តេចតេជោ **ហ៊ុន សែន** បានស្នើឱ្យមេដឹកនាំយោធាថៃបច្ចុប្បន្នគឺឯកឧត្តម ប្រាយុទ្ធ ពិនិត្យមើលហើយលើកលែងការចោទប្រកាន់ដល់ពលរដ្ឋខ្មែរចំនួន ១០ នាក់ដែលត្រូវបានអាជ្ញាធរចាប់ខ្លួនកំពុងជាប់ឃុំនៅពន្ធនាគារខេត្តស្រះកែវ ដោយចោទប្រកាន់ថាពួកគេឆ្លងដែនខុសច្បាប់ ។ សម្តេចតេជោថ្លែងថា សូម្បីតែហត្ថលេខា និងត្រារបស់នាយករដ្ឋមន្ត្រីនៅមានជនខិលខូចលួចក្លែងបន្លំ ចុះទម្រាំប្រជាពលរដ្ឋដែលឆ្លងដែនដោយខុសច្បាប់ ដោយសារមេខ្យល់ធ្វើលិខិតឆ្លងដែនក្លែងក្លាយឱ្យនោះ... ដូច្នេះគ្នាចាញ់បោកគេរឿងធ្វើលិខិតឆ្លងដែនមួយជាន់ហើយត្រូវជាប់ពន្ធនាគារថែមទៀត ។

សម្តេចក៏បានថ្លែងទៀតថា កម្ពុជាបានជួបប្រទះនូវបញ្ហាដ៏ធំប្រៀបដូចជាទឹកជំនន់មួយដែលបក់បោកមកលើយ៉ាងខ្លាំង តែនោះជាជំនន់មនុស្សដែលអាជ្ញាធរថៃបានធ្វើបន្ទាប់ពីរដ្ឋប្រហារ និងអនុវត្តច្បាប់អាជ្ញាសឹក ហើយក៏បានបង្កើតឡើងនូវស្ថានភាពមួយដែលយើងនឹងស្មានមិនដល់ ។ គិតត្រឹមថ្ងៃទី ២៣ មិថុនា ឆ្នាំ ២០១៤ ពលករមានចំនួនជាង ២៤ ម៉ឺននាក់ហើយ ហើយក៏ប្រហែលជាកើនឡើងដល់ជាង ២៥ម៉ឺននាក់ ដែលជាចំនួនមួយដ៏ច្រើនដែលយើងទទួលបន្ទុកដោះស្រាយភ្លាមៗនៅនឹងកន្លែង ដោយមិនរង់ចាំលិខិតស្នាមអ្វីទាំងអស់ ។ នេះបង្ហាញឱ្យឃើញពីការទទួលខុសត្រូវនៃស្ថាប័នថ្នាក់ជាតិ ជាពិសេស គឺអាជ្ញាធរនៅតាមបណ្តោយព្រំដែនកម្ពុជា- ថៃ ដែលក្នុងនោះ ខេត្តបន្ទាយមានជ័យ ជាខេត្តដែលត្រូវទទួលបន្ទុកធ្ងន់ធ្ងរជាងគេ ។ ពលកររបស់យើងត្រូវបានភាគីថៃសម្រុកដឹកមកដោយមិនបានជូនដំណឹងជាមុនដល់ភាគីកម្ពុជាឡើយ ។ ដូច្នេះសម្រាប់ការដោះស្រាយរបស់យើងគឺត្រូវយកចិត្តទុកដាក់ដោះស្រាយនូវបញ្ហាជនរួមជាតិរបស់យើង បើទោះបីគាត់បានឆ្លងកាត់ទៅធ្វើការ ខុសច្បាប់ក៏ដោយ ។

ក្នុងឋានៈជាសាច់ឈាមរបស់យើង យើងត្រូវទទួលបន្ទុកដោះស្រាយបញ្ហានេះជាមួយប្រតិបត្តិការដ៏ឆាប់រហ័សដោយមធ្យោបាយសរុប វិធានការសរុប យើងដោះស្រាយបញ្ហានេះបានតាំងពីដើមដល់ចប់ ដែលនេះជាបទពិសោធន៍នៃការងារដឹកនាំការដោះស្រាយកត្តាថៃដន្យ គឺបង្ហាញពីសមត្ថភាពនៃមន្ត្រីរបស់យើងក្នុងការដោះស្រាយបញ្ហា ។

សម្ដេចតេជោ **ហ៊ុន សែន** ក៏បានអំពាវនាវឱ្យប្រជាជនយើងត្រូវខិតខំរកការងារធ្វើក្នុងស្រុក ព្រោះថា នៅក្នុងប្រទេសយើងពិតមែន កម្រៃដែលទទួលបានមានចំនួនតិចជាងនៅក្នុងប្រទេសថៃ ប៉ុន្តែបើប្រៀបធៀបអំពីការចំណាយដែលពលករត្រូវបង់ថ្លៃតាមរយៈការធ្វើការខុសច្បាប់ក្នុងប្រទេសគេឃើញថា ធ្វើការនៅក្នុងប្រទេសយើងមានសុវត្ថិភាព ។ ឯប្រាក់ចំណូលបើកាត់កងទូទាត់រវាងប្រាក់ចំណាយក៏មិនខុសគ្នាប៉ុន្មានដែរ ។ ម្យ៉ាងទៀតនៅលើទឹកដីយើង យើងមានសិទ្ធិសេរីភាពគ្រប់បែបយ៉ាង តែបើទៅធ្វើការងារខុសច្បាប់នៅប្រទេសគេ គេអាចចោទយើងអំពីអ្វីក៏បានដែរ ។ ដូច្នេះ ព័ត៌មានស្ដីពីទីផ្សារការងារត្រូវតែជាប្រធានបទដ៏សំខាន់មួយ ហើយក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ត្រូវធ្វើកិច្ចការងារនេះតាមរយៈនៃការចូលរួមសហការពីផ្នែកពាក់ព័ន្ធនានា ។ សម្ដេចតេជោ **ហ៊ុន សែន** បានមានប្រសាសន៍បន្តថា មានអ្នកលើកឡើងថា លោក **ហ៊ុន សែន** បរាជ័យក្នុងការដោះស្រាយបញ្ហាការងារបានជាមានពលករទៅក្រៅប្រទេស ។ ខ្ញុំសូមទទួលយក ។ ប៉ុន្តែសូមអ្នកគិតឱ្យបានច្បាស់ថា តើទីផ្សារការងារក្នុងប្រទេសយើងមានប៉ុន្មាន ហើយទាក់ទិននឹងពលករចេញទៅធ្វើការងារនៅក្រៅប្រទេសនេះ តើមានតែកម្ពុជាទេឬ? នៅក្នុងបណ្ដាប្រទេសអាស៊ាន ហ្វីលីពីន គឺជាប្រទេសដែលធំជាងគេខាងនាំចេញពលករទៅទីផ្សារហុងកុង ។ ឥណ្ឌូនេស៊ីក៏បញ្ជូនពលករទៅក្រៅប្រទេសដែរ ឯប្រទេសថៃក៏បញ្ជូនពលករទៅក្រៅប្រទេសដូចគ្នា គឺមជ្ឈិមបូព៌ា និងកោះតៃវ៉ាន់ ដែលមានប្រាក់ឈ្នួលខ្ពស់ជាង ។ នេះជាមូលហេតុដែលធ្វើឱ្យប្រទេសថៃប្រឈមនឹងកង្វះពលកម្ម ។ នៅក្នុងចំណោមបណ្ដាប្រទេសអាស៊ាន ប្រទេសដែលមិនបញ្ជូនពលករចេញ ប៉ុន្តែបែរជារកពលករមកធ្វើការមានតែម៉ាឡេស៊ី សិង្ហបុរី និងប្រ៊ុយណេប៉ុណ្ណោះ ។

សម្ដេចនាយករដ្ឋមន្ត្រីបានគូសបញ្ជាក់ថា ឥឡូវនេះ ការបញ្ជូនពលករត្រឡប់មកវិញ គឺយើងត្រូវប្រែក្លាយការលំបាកនេះទៅជាកាលានុវត្តភាពថ្មីវិញ ។ ការបញ្ជូនមកក្នុងគ្រាដំបូងពិតជាមានកំហុសពីផ្នែកភាគីថៃ រាប់ទាំងការបំពានសិទ្ធិ ។ ប៉ុន្តែនៅពេលដែលមានអន្តរាគមន៍ភ្លាមៗពីស្ថានទូតយើងនៅបាងកក និងក្រសួងការបរទេសយើងនៅភ្នំពេញ និងផ្នែកពាក់ព័ន្ធដទៃទៀតក៏បានសម្រួលជាបន្តបន្ទាប់ចំពោះការគោរពសិទ្ធិក្នុងការបញ្ជូនពលករកម្ពុជាមកវិញ ។ សម្ដេចតេជោក៏បានបង្ហាញអំពីលិខិតរបស់ឯកឧត្តម ប្រាយុទ្ធ ច័ន្ទអូចា ដែលផ្ញើមកសម្ដេចចំនួន ២ លើក គឺលិខិតមួយចុះថ្ងៃទី ១២ ខែមិថុនា និងមួយទៀតចុះថ្ងៃទី ១៨ ខែមិថុនា ដោយបានធ្វើការបកស្រាយអំពីការបញ្ជូនពលករកម្ពុជាមកវិញព្រោះគេទាមទារនូវភាពម៉ត់ចត់ដើម្បីកុំឱ្យក្រុមជួញដូរមនុស្ស យកពលករទៅធ្វើការខុសច្បាប់ ។ ឯកឧត្តម ប្រាយុទ្ធ បានសន្យាក្នុងលិខិតនោះថា ថៃពុំមានបំណងប្រើប្រាស់កម្លាំង ឬចេញបទបញ្ជាដើម្បីបណ្ដេញពលករអន្តោប្រវេសន៍ចេញពីប្រទេសនោះទេ ប៉ុន្តែអាជ្ញាធរថៃកំពុងស្វែងរកកិច្ចសហប្រតិបត្តិការពីក្រុមហ៊ុនពាណិជ្ជកម្មទាំងអស់ ដើម្បីប្រមូលបញ្ជីឈ្មោះពលករបរទេសរបស់ក្រុមហ៊ុន ពួកគេទាំងបានចុះបញ្ជីត្រឹមត្រូវ ទាំងមិនទាន់បានចុះបញ្ជី ។ ចំពោះពលករមិនទាន់បានចុះបញ្ជីនឹងត្រូវដាក់ក្នុង ដំណើរការស្របច្បាប់មួយ ដើម្បីធ្វើឱ្យប្រាកដថា ពួកគេអាចបន្តរស់នៅក្នុងប្រទេសថៃដោយស្របច្បាប់ ។ គោលបំណងរបស់អាជ្ញាធរថៃ គឺពង្រឹងការអនុវត្តច្បាប់ទាំងឡាយដែលមានស្រាប់រួចហើយចំពោះពលករអន្តោប្រវេសន៍ទាំងអស់ដើម្បីឱ្យប្រាកដថា ពួកគេនឹងទទួលបាននូវការគាំពារ ក៏ដូចជាសិទ្ធិ និងសុខុមាលភាពរបស់ពួកគេត្រូវបានការពារក្នុងពេលកំពុងធ្វើការក្នុងប្រទេសថៃ ។ សម្ដេចតេជោ **ហ៊ុន សែន** បានសម្ដែងការគាំទ្រចំពោះសកម្មភាពដែលក្រុមប្រឹក្សាសន្តិភាព និងសណ្ដាប់ធ្នាប់ជាតិថៃត្រូវចាត់វិធានការដើម្បីធានាថាសិទ្ធិ និងសុខុមាលភាពរបស់ពលករអន្តោប្រវេសន៍នឹងត្រូវបានការពារនៅក្នុងប្រទេសថៃ ។/




**សូមគោរពឯកឧត្តម លោកជំទាវ និងប្រិយមិត្តអ្នកអានជាទីគោរព**

**សូមចូលមក Facebook Page : Pracheachun Magazine-ទស្សនាវដ្តីប្រជាជន**

**ហើយចុច Like និង Share ដើម្បីទទួលបានព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ព្រមទាំងផ្ដល់ទស្សនៈ ឬ មតិផ្សេងៗ**

# កិច្ចប្រជុំ APA បានប្រព្រឹត្តទៅដោយជោគជ័យនៅរាជធានីភ្នំពេញ




*ឯកឧត្តម **ខួន ញឹល** អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំគណៈកម្មាធិការចំពោះកិច្ចរបស់សភាតំបន់អាស៊ី ដែលហៅកាត់ថា APA ស្ដីពីបទប្បញ្ញត្តិហិរញ្ញវត្ថុ និងការគ្រប់គ្រងបុគ្គលិកសម្រាប់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់សភាក្នុងតំបន់អាស៊ី និងថតរូបអនុស្សាវរីយ៍*

កាលពីព្រឹកថ្ងៃទី២៥ខែមិថុនាឆ្នាំ២០១៤ កិច្ចប្រជុំគណៈកម្មាធិការចំពោះកិច្ចរបស់សភាតំបន់អាស៊ី ដែលហៅកាត់ថា APA ស្ដីពីបទប្បញ្ញត្តិហិរញ្ញវត្ថុ និងការគ្រប់គ្រងបុគ្គលិក សម្រាប់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ របស់សភាក្នុងតំបន់អាស៊ី ដែលសភាកម្ពុជាទទួលធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំនោះ បានបញ្ចប់ប្រកបដោយជោគជ័យ បន្ទាប់ពីបានដំណើរការអស់រយៈពេលពីរថ្ងៃរួចមក នៅសណ្ឋាគារអ៊ិនធ័រកង់ទីណង់តាល់ រាជធានីភ្នំពេញ ។

គណៈប្រតិភូព្រឹទ្ធសភា រដ្ឋសភា ដែលមានការចូលរួមពីអ្នកតំណាងរាស្ត្រចំនួន ៤៧ រូប មកពីប្រទេសចំនួន ១០ រួមមាន ប្រទេសបារ៉ែន ប៊ូតង់ កម្ពុជា អ៊ីរ៉ង់ ហ្សកដានី ឡាវ ម៉ាឌីវ រុស្ស៊ី ប៉ាគីស្ថាន និងអារ៉ាប៊ីសាអូឌីត រួមទាំងប្រទេសជាអ្នកសង្កេតការណ៍ មានចិន ឥណ្ឌូណេស៊ី និងកូរ៉េខាងជើងផងនោះ បានមកជួបជុំគ្នាក្នុងកិច្ចប្រជុំនេះក្រោមអធិបតីភាព ឯកឧត្តម **ខួន ញឹល** អនុប្រធានទី ១ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានសភាតំបន់អាស៊ី ។

មានប្រសាសន៍នៅក្នុងពិធីបើកកិច្ចប្រជុំនេះ ឯកឧត្តម **ខួន ញឹល** បានគូសបញ្ជាក់ថា ប្រធានបទនៃកិច្ចប្រជុំគណៈកម្មាធិការចំពោះ កិច្ចនាពេលនេះ ពិតជាសមស្របទៅនឹងដំណើរការនៃការវិវត្តជាលំដាប់របស់សភាតំបន់អាស៊ី ដើម្បីសម្រេចសេចក្ដីប្រាថ្នារួមរបស់យើងក្នុងការប្រែក្លាយ APA ឱ្យទៅជាសភាអាស៊ីនាពេលអនាគត ។

ឯកឧត្តម **ប៉ែន ថាវី** ប្រធានគណៈកម្មការទី ១ រដ្ឋសភាបានមានប្រសាសន៍នៅក្នុងសន្និសីទកាសែតក្រោយបញ្ចប់កិច្ចប្រជុំថា ការរៀបចំទទួលធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំគណៈកម្មាធិការចំពោះកិច្ចដែលទាក់ទងទៅនឹងលក្ខន្តិកៈ ឯកសារពាក់ព័ន្ធរបស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ និងបុគ្គលិកនិងហិរញ្ញវត្ថុរបស់សភានៃតំបន់អាស៊ី APA ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ នេះជាកិត្តិយសដ៏ធំមួយសម្រាប់ប្រទេសជាតិយើង ។ ឯកឧត្តមបានបញ្ជាក់ថា កិច្ចប្រជុំបានពិភាក្សាអំពីថា តើយើងចំណាយទៅលើបុគ្គលិកយ៉ាងដូចម្ដេច ចំណាយទៅលើអគ្គលេខាធិការយ៉ាងដូចម្ដេច ។ ប៉ុន្តែប្រការដែលសំខាន់នោះគឺការប្រជុំនាពេលនេះបានព្រមព្រៀងគ្នាទៅលើការពិភាក្សាអំពីច្បាប់ទម្លាប់ដែលមាននៅក្នុងសភាអាស៊ីដើម្បីយកទៅអនុវត្តនៅក្នុងអគ្គលេខាធិការដ្ឋានរបស់សភាអាស៊ី (APA) ហើយការងារនេះយើងនឹងលើកទៅអង្គប្រជុំធំរបស់ APA ដែលនឹងរៀបចំឡើងនៅប្រទេសប៉ាគីស្ថានបន្តទៀត ។



*សមាជិក សមាជិកា ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការចំពោះកិច្ចរបស់សភាតំបន់អាស៊ី ដែលហៅកាត់ថា APA*

គួរបញ្ជាក់ថា ក្នុងសម័យប្រជុំពេញអង្គនៃសភាតំបន់អាស៊ីលើកទី ៦ នៅទីក្រុងអ៊ីស្លាម៉ាបាដ ប្រទេសប៉ាគីស្ថានកាលពីខែធ្នូឆ្នាំ ២០១៣ កន្លងទៅ សភាកម្ពុជាបានស្ម័គ្រចិត្តទទួលធ្វើជាម្ចាស់ផ្ទះរៀបចំសម័យប្រជុំពេញអង្គលើកទី ៨ នាឆ្នាំ២០១៥ ខាងមុខ ហើយកម្ពុជាប្ដេជ្ញាចិត្តនឹងបន្តជំរុញបន្ថែមទៀត ដើម្បីសម្រេចបានចក្ខុវិស័យរបស់ APA ក្នុងការប្រែក្លាយខ្លួនឱ្យទៅជាសភាអាស៊ីនោះ ។/

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៤ នៅគេហដ្ឋានស្ថិតក្នុងភូមិត្រពាំងស្វាយ ឃុំបល្ល័ង្ក ខេត្តកំពង់ធំ ឯកឧត្តមបណ្ឌិត **ខួន ញឹល** អនុប្រធានទី ១ រដ្ឋសភា សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តកំពង់ធំ បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំការងារ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី ជាសមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាខេត្តកំពង់ធំ លោក លោកស្រីជាសមាជិក សមាជិកាអចិន្ត្រៃយ៍គណបក្សស្រុកបារាយណ៍ ព្រមទាំងឯកឧត្តមជាសមាជិករដ្ឋសភាមណ្ឌលកំពង់ធំជាច្រើនរូប ។ ខ្លឹមសារនៃកិច្ចប្រជុំបានផ្តោតជាសំខាន់លើការដោះស្រាយបញ្ចប់ការប្តូរទីតាំង និងការសាងសង់អគារទីស្នាក់ការគណៈកម្មាធិការគណបក្សឃុំទ្រៀល ស្ថិតក្នុងស្រុកបារាយណ៍ រួមជាមួយនឹងការចង្អុលចុះនូវការងារមួយចំនួនសម្រាប់គណបក្សខេត្តយកទៅអនុវត្តបន្ត ។ ក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត **ខួន ញឹល** បានចូលបច្ច័យចំនួន ១ លានរៀលដល់បុណ្យសពមន្ត្រីស្នាក់ការគណបក្សខេត្ត និងបច្ច័យ ១ លានរៀលទៀតដល់បុណ្យសពនៅឃុំចើងដើង ស្រុកបារាយណ៍ ដែលជាសកម្មជនរបស់ឯកឧត្តមបណ្ឌិត **ខួន ញឹល** ។





ថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ២០១៤ ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការសមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឯកឧត្តម **ត្រាំ អ៊ីវតឹក** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសមាជិករាជរដ្ឋាភិបាលជាច្រើនរូបទៀត បានអញ្ជើញចុះពិនិត្យសកម្មភាពសាងសង់ស្ពានមេគង្គស្ទឹងត្រែង ការសាងសង់ផ្លូវ ទំនប់វារីអគ្គិសនីសេសានក្រោមពីរ នៅខេត្តស្ទឹងត្រែង។



*ថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០១៤ នៅទីស្នាក់ការគណៈកម្មាធិការគណបក្សខេត្តរតនគិរី បានរៀបចំពិធីបុណ្យផ្កាសាមគ្គី ដែលផ្តួចផ្តើមដោយឯកឧត្តម* ***ម៉ូ ឈន*** *សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តរតនគិរី ដើម្បីប្រមូលថវិកាជួយដល់ជនចាស់ជរា មន្ត្រីរាជការចូលនិវត្តិន៍ បាត់បង់សម្បទាវិជ្ជាជីវៈ ក្នុងឱកាសពិធីរំលឹកអនុស្សាវរីយ៍លើកទី ៦៣ ថ្ងៃកំណើតគណបក្សប្រជាជនកម្ពុជានៅ ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៤ ខាងមុខនេះ ដោយប្រមូលបានថវិកាចំនួន ១៩ លានរៀល និង ១២០០$។*

*បន្ទាប់មកនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤ ឯកឧត្តម* ***ម៉ូ ឈន*** *បានបើកកិច្ចប្រជុំផ្ទៃក្នុងជាមួយប្រធានក្រុមការងារថ្នាក់ខេត្តចុះជួយស្រុកទាំង ៩ ខេត្តរតនគិរី ដើម្បីបូកសរុបលទ្ធផលការងារ លើកទិសដៅអនុវត្តការងារ និងការត្រៀមរៀបចំពិធីរំលឹកខួបអនុស្សាវរយ៏លើកទី ៦៣ ថ្ងៃកំណើតគណបក្សប្រជាជនកម្ពុជា ។ ឆ្លៀតឱកាសនោះ ឯកឧត្តម* ***ម៉ូ ឈន*** *បានប្រគល់ជូនថវិកាចំនួន ១លានរៀលដល់ស្រុកនីមួយៗដើម្បីត្រៀមរៀបចំពិធីរំលឹកខួបអនុស្សាវរីយ៍ ។*






ថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០១៤ នៅសាលប្រជុំបក្សខេត្តស្វាយរៀង លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច សមាជិកាគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តស្វាយរៀង បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបការអនុវត្តភារកិច្ច របស់ក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តស្វាយរៀង និងលើកទិសដៅភារកិច្ចសំខាន់ៗសម្រាប់អនុវត្តន៍ដំណាក់កាលទី៦លើកទី៤ ដែលមានសមាជិកសមាជិកា និងមន្ត្រីក្រុមការងារសរុបជិត១០០០នាក់។លោកជំទាវ **ម៉ែន សំអន** បានមានប្រសាសន៍ជំរុញមន្ត្រីក្រុមការងារត្រូវបន្តចុះពង្រឹងមូលដ្ឋាន ដើម្បីយល់ដឹងពីសុខទុក្ខផ្ទាល់ និងផ្តល់នូវអត្ថប្រយោជន៍ពិតៗជូនប្រជាពលរដ្ឋគ្រប់ថ្នាក់មូលដ្ឋានទាំងអស់ក្នុងទឹកដីខេត្តស្វាយរៀង ពិសេស ដោះស្រាយឲ្យទាន់ពេលវេលាពីតម្រូវការរបស់ពួកគាត់ ពិសេសរដូវវស្សាឆ្នាំនេះ លើការងារបង្កបង្កើតនផលតែម្តង។ លោកជំទាវក៏បានផ្តល់នូវការលើកទឹកចិត្តដល់មន្ត្រីក្រុមការងារថ្នាក់មូលដ្ឋាន ការងារថ្នាក់កណ្តាល ក៏ដូចជាប្រធានក្រុមការងារចុះជួយតាមស្រុកទាំងអស់ទូទាំងខេត្តស្វាយរៀងដែលបានយកចិត្តទុកដាក់អនុវត្តន៍តាមស្មារតីទទួលខុសត្រូវ ទាំងកម្លាំងកាយចិត្ត និងធនធានទ្រព្យសម្បត្តិ ជួយគាំទ្រយ៉ាងសកម្មគ្រប់សកម្មភាពតាមបណ្តាមូលដ្ឋាននានាទូទាំងខេត្ត រួមចំណែកឲ្យខេត្តនៅតែទទួលជ័យជម្នះគ្រប់ភារកិច្ចជាបន្តបន្ទាប់។

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ក្នុងខែមិថុនានេះដែរឯកឧត្ដម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រឆាំងគ្រឿងញៀន សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា បានអញ្ជើញពិនិត្យសភាពការណ៍ពលករខ្មែរដែលថៃបញ្ជូនត្រឡប់មកវិញនៅខេត្តបន្ទាយមានជ័យ បាត់ដំបង និងខេត្តប៉ៃលិន។



*ថ្មីៗនេះ ឯកឧត្ដម **ជា ចាន់តូ** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា បានអញ្ជើញជួបសំណេះសំណាលជាមួយមន្ត្រីដឹកនាំមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាសាខាខេត្តរតនគិរី។ ឯកឧត្ដមបានពិនិត្យអគារថ្មីរបស់ធនាគារជាតិនៃកម្ពុជាសាខាខេត្តរតនគិរី។*




ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៤ ឯកឧត្ដម **ចម ប្រសិទ្ធិ** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឯកឧត្ដម **ចាន់ សុផល** អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ឯកឧត្ដមឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា លោកប្រធានតំណាងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនប្រចាំនៅកម្ពុជា(JICA) បានចូលរួមបើកការដ្ឋានសាងសង់គម្រោងពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅខេត្តបាត់ដំបង ។



*ថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០១៤ ឯកឧត្ដម **វង សូត** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងលោកជំទាវ បាននាំយកថវិការបស់សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភាជាតិ និងលោកជំទាវ និងឯកឧត្ដមផ្ទាល់ចំនួនមួយម៉ឺនដុល្លារ ប្រគេនព្រះសង្ឃសម្រាប់សាងសង់ព្រះវិហារវត្តឧត្ដមសាមគ្គីត្រោចខោល ហៅវត្តត្រោចខោល ស្ថិតក្នុងភូមិត្រោចខោល ឃុំត្រពាំងផ្លុង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ។*



# លទ្ធផលមួយចំនួននៅវិស័យសេដ្ឋកិច្ច

**ចំណូលពន្ធដាររយៈពេល ៥ ខែឆ្នាំ ២០១៤ :**

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបញ្ជាក់ថា នៅក្នុងខែឧសភា ឆ្នាំ ២០១៤ នេះ ពន្ធដាររកបានចំណូលពន្ធប្រមាណ ៣៦៤,៧៤ ពាន់លានរៀល គឺប្រមាណ ៩១,២ លានដុល្លារអាមេរិក ។ ចំណូលខែឧសភានេះ បើប្រៀបធៀបនឹងចំណូលខែឧសភា ឆ្នាំ ២០១៣ គឺមានកំណើនដល់ទៅ ២៥,៤% ដែលក្នុងនោះ ថវិការដ្ឋមានកំណើនស្មើនឹង ១៤,៦% ។

ដោយឡែកសរុបរយៈពេល ៥ ខែនៃឆ្នាំ ២០១៤ នេះ ពន្ធដាររកចំណូលបានសរុប ស្មើនឹង ៤៥,៧៧% នៃ គោលដៅកំណត់ក្នុងច្បាប់ថវិកា (គឺប្រមូលបានប្រមាណជាង ៤៧៧ លានដុល្លារ) ក្នុងនោះថវិការដ្ឋសម្រេចបាន ៤៨,៤% និងថវិកាថ្នាក់ក្រោមជាតិសម្រេចបាន ២៩,១% ។ បើប្រៀបធៀបនឹងរយៈពេលដូចគ្នា (៥ ខែ) នៃឆ្នាំ ២០១៣ ចំណូល ៥ ខែនៃឆ្នាំ ២០១៤ មានកំណើនស្មើនឹង ១២,៥% ក្នុងនោះថវិការដ្ឋកើនឡើង ស្មើនឹង ១៤,៦% ។

បើតាមការវិភាគប្រភេទពន្ធឃើញថា ចំណូលក្នុងឆ្នាំនេះមានការកើនឡើងគ្រប់ប្រភេទពន្ធ ក្នុងនោះប្រភេទពន្ធសំខាន់ៗដែលមានការកើនឡើងមានដូចជាពន្ធលើប្រាក់បៀវត្សមានការកើនឡើងប្រមាណ ១៩,២% ពន្ធលើប្រាក់ចំណេញកើនឡើង ១៩,៨% អាករលើតម្លៃបន្ថែមកើនឡើង ៥,៩% និងអាករពិសេសកើនឡើង ៤,៥% ។

ទន្ទឹមនេះបើពិនិត្យតាមវិស័យក៏ឃើញថាចំណូលក្នុងឆ្នាំនេះមានការកើនឡើងស្ទើរគ្រប់សកម្មភាព ក្នុងនោះ ផ្នែកសេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ២០% ផ្នែកស្ថាបត្យកម្ម និងសំណង់កើនឡើង ៦១,៧% ផលិតភេសជ្ជៈ កើនឡើង ១៥,៨% ផ្នែកផលិតសម្លៀកបំពាក់កើន ៩៧,៨% ផ្នែកសណ្ឋាគារផ្ទះសំណាក់កើនឡើង ៤១,៩% ផ្នែកផលិតថ្នាំជក់កើនឡើង ១៥,៩% លក់ភេសជ្ជៈកើនឡើង ៤៩,៤% ផលិតម្ហូបអាហារកើនឡើង ៩៣,១% ផ្នែកលក់សំភារៈការិយាល័យកើនឡើង ៤៤,៩% ផ្នែកដឹកជញ្ជូននិងទេសចរណ៍កើនឡើង ១៨,៨% អាកាសយានដ្ឋាន និងកំពង់ផែកើនឡើង ១២,៣% និងផ្នែកលក់គ្រឿងយន្តកើនឡើង ៤៥,៨% និងផ្នែកលក់គ្រឿងសំណង់ក៏កើនខ្លាំងដែរ ។

**ពាណិជ្ជកម្មកម្ពុជា-អាមេរិក រយៈពេល ៤ ខែឆ្នាំ ២០១៤**

ការិយាល័យស្ថិតិពាណិជ្ជកម្មអាមេរិកអះអាងថា ទំហំពាណិជ្ជកម្មកម្ពុជា និងអាមេរិក គិតពីខែមករា ដល់ខែមេសាកន្លងទៅនេះ មានតម្លៃសរុបប្រមាណ ១ ០៩៩,៦ លានដុល្លារ គឺមានការកើនឡើងប្រមាណ ៨៦ លានដុល្លារ គិតជាភាគរយគឺមានការកើនឡើងប្រមាណ ៨% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១៣ ដែលមានទឹកប្រាក់ចំនួនប្រមាណ ១ ០១៦,៦ លានដុល្លារ ។

នៅក្នុងរយៈពេល ៤ ខែនេះ ការនាំចេញរបស់កម្ពុជាទៅកាន់អាមេរិកមានចំនួនកើនឡើងប្រមាណ ៧១,៣ លានដុល្លារ គឺកើនឡើង ៧,៦៦% ខណៈដែលកម្ពុជាទទួលទំនិញពីអាមេរិកនៅក្នុងរយៈពេលដដែល កើនឡើងប្រមាណ ១១,៧ លានដុល្លារ ឬប្រមាណ ១៣,៦០% ។ ទំនិញដែលនាំចេញទៅអាមេរិកមានតម្លៃប្រមាណ ១០០១,៩ លានដុល្លារ ខណៈដែលក្នុងរយៈពេលដូចគ្នានៅឆ្នាំ ២០១៣ មានតម្លៃត្រឹមតែ ៩៣០,៦ លានដុល្លារតែប៉ុណ្ណោះ ។ ឯទំនិញដែលនាំចូលពីអាមេរិកមានតម្លៃសរុប ៩៧,៧ លានដុល្លារ ធៀបនឹង ៤ ខែដើមឆ្នាំ ២០១៣ មានតម្លៃប្រមាណ ៨៦ លានដុល្លារ ។

គួររំឭកដែរថា ទំនិញដែលកម្ពុជានាំចេញទៅកាន់អាមេរិក គឺនៅតែជាផលិតផលវាយនភ័ណ្ឌ ដែលមានដូចជាសម្លៀកបំពាក់ ។ ក្រៅពីនោះ គឺមានទំនិញកសិកម្ម ដូចជា អង្ករ ម្រេច ជាដើម ។ ដោយឡែកទំនិញដែលកម្ពុជានាំចូលពីអាមេរិកវិញនោះ គឺមានផលិតផលអគ្គិសនី គ្រឿងយន្ត រថយន្ត ផលិតផលបរិក្ខារពេទ្យជាដើម ។ មកដល់ពេលនេះអាមេរិកគឺនៅតែជាទីផ្សារធំជាងគេនៃការនាំចេញទំនិញរបស់ប្រទេសកម្ពុជា ក្រៅពីនោះ គឺមានសហគមន៍អឺរ៉ុប ប្រទេសនៅអាស៊ាន ចិន ជប៉ុន កាណាដា ។

**មីក្រូហិរញ្ញវត្ថុត្រីមាសទី ១ ឆ្នាំ ២០១៤**

អគ្គនាយកត្រួតពិនិត្យធនាគារជាតិនៃកម្ពុជាបានបញ្ជាក់ថា នៅត្រីមាសទី ១ ឆ្នាំ ២០១៤ ឥណទានសរុបរបស់វិស័យមីក្រូហិរញ្ញវត្ថុបានកើនឡើង ៥១,៦៦% ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ ២០១៣ គឺពី ៣ ៩៨៤ ពាន់លានរៀលដល់ចំនួន ៦ ០៤៣ ពាន់លានរៀលដែលបានផ្តល់ដល់អតិថិជនសរុបចំនួន ១ ៥៥៤ ៤២៤ នាក់ ។ រីឯប្រាក់បញ្ញើវិញបានកើនឡើង ចំនួន ៥៦,១៨% គឺពីចំនួន ១ ៣៥៦ ពាន់លានរៀល ដល់ ២ ១១៩ ពាន់លានរៀល បើធៀបនឹងរយៈពេលដូចគ្នានៃត្រីមាសទី ១ ឆ្នាំ ២០១៣ ។

វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាកំពុងមានការរីកចម្រើនគួរឱ្យកត់សម្គាល់ និងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាហិរញ្ញវត្ថុជូនប្រជាជនរហូតដល់ជនបទ ។ ការរីកចម្រើននេះបានឆ្លុះបញ្ចាំងតាមរយៈការពង្រីកបណ្តាញប្រតិបត្តិការគ្របដណ្តប់ទូទាំងប្រទេស ដែលក្នុងនោះមានការិយាល័យប្រតិបត្តិការថ្នាក់ស្រុកមានចំនួន ១ ៩៩៧ ថ្នាក់ឃុំចំនួន ១៤ ៩៧៥ និងថ្នាក់ភូមិមានចំនួន ៨៦ ៤៦៤ ។ ចំណែកឯបញ្ញើវិញបានកើនឡើងចំនួន ៥៦,១៨% គឺពី ១ ៣៥៦ ពាន់លានរៀល ដល់ ២ ១១៩ ពាន់លានរៀល បើធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ ២០១៣ ។

**ពាណិជ្ជកម្មកម្ពុជា-ម៉ាឡេស៊ី រយៈពេល ៤ ខែឆ្នាំ ២០១៤**

អគ្គនាយកសភាពាណិជ្ជកម្មកម្ពុជាបានឱ្យដឹងថា ទំហំពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសកម្ពុជា ម៉ាឡេស៊ី ចាប់ពីខែមករា ដល់ខែមេសា ឆ្នាំ

តទៅទំព័រទី ២៦

# វិស័យពាណិជ្ជកម្មកំពុងជំរុញការធ្វើកំណែទម្រង់ផ្ទៃក្នុង

## ✵ តម្លៃនៃការនាំចេញ-ចូល ត្រីមាសទីមួយដើមឆ្នាំ ២០១៤ កើន ១៥%



*សកម្មភាពលើកដាក់ទំនិញនាំចេញ-នាំចូល នៅកំពង់ផែស្វយ័តខេត្តព្រះសីហនុ*



*សកម្មភាពលើកដាក់ទំនិញនាំចេញ-នាំចូល នៅកំពង់ផែរាជធានីភ្នំពេញ ស្ថិតក្នុងស្រុកកៀនស្វាយ ខេត្តកណ្ដាល*

រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី ៥ ដឹកនាំដោយសម្ដេចអគ្គមហាសេនាបតីតេជោ**ហ៊ុន សែន**ដែលបាន ប្រសូតចេញពីឆន្ទៈប្រជាពលរដ្ឋធ្វើការបោះឆ្នោតកាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣ បានចេញដំណើរលើមូលដ្ឋានដែលសេដ្ឋកិច្ចជាតិកំពុងបង្ហាញនូវភាពរឹងមាំឆ្ពោះទៅសម្រេចគោលដៅកំណើនសេដ្ឋកិច្ច ៧% ប្រកបដោយចីរភាព។

រាជរដ្ឋាភិបាលកំពុងបន្តអនុវត្តយ៉ាងសកម្មនូវកម្មវិធីកំណែទម្រង់ស៊ីជម្រៅ ដើម្បីប្រែក្លាយប្រទេសកម្ពុជាពីប្រទេសដែលមានចំណូលទាបទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងរយៈពេលដ៏ខ្លីខាងមុខ និងបន្តប្រែក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ ២០៣០ ហើយនឹងទៅជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ ២០៥០ នេះជាគោលដៅនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីប្រជាជាតិកម្ពុជា។

ដើម្បីសម្រេចបាននូវគោលដៅប្រកបដោយមហិច្ឆតានេះ គឺត្រូវពឹងផ្អែកមួយផ្នែកធំទៅលើការលើកកម្ពស់សមត្ថភាពរបស់ប្រជាជនយើង តាមរយៈការអភិវឌ្ឍចំណេះដឹង និងជំនាញវិជ្ជាជីវៈប្រកបដោយគុណភាពខ្ពស់ និងរត់ឱ្យទាន់សភាពការណ៍រីកចម្រើនរបស់ទីផ្សារក្នុងតំបន់ និងពិភពលោក ក្នុងនោះវិស័យពាណិជ្ជកម្មពិតជាមានតួនាទីដ៏សំខាន់ក្នុងការរួមចំណែកដល់ដំណើរការជំរុញកំណើនសេដ្ឋកិច្ច និងការប្រកួតប្រជែងរបស់កម្ពុជា។

ឯកឧត្តម **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបានឱ្យដឹងថា ក្រសួងកំពុងធ្វើកំណែទម្រង់ផ្ទៃក្នុងដើម្បីត្រៀមខ្លួនសម្រាប់ការបើកចំហពាណិជ្ជកម្មឆ្លងដែនក្នុងគ្រាដែលសមាហរណកម្មសេដ្ឋកិច្ចអាស៊ាននៅឆ្នាំ ២០១៥ នឹងមកដល់។

ការធ្វើកំណែទម្រង់ដើម្បីកាត់បន្ថយការិយាធិបតេយ្យ ឯកឧត្តម **ស៊ុន ចាន់ថុល** ថ្លែងថា នាយកដ្ឋានថ្មីមួយកំពុងត្រូវបានបង្កើតឡើង និងមានការរៀបចំជាច្រើនផ្សេងទៀតនៅក្នុងក្រសួង សំដៅគាំទ្រពាណិជ្ជកម្មនៅកម្ពុជា ។ ប្រព័ន្ធសូហ្វវែររបស់ក្រសួងត្រូវបានធ្វើកំណែទម្រង់ដើម្បីភាពងាយស្រួលសម្រាប់អ្នកនាំចេញ ។ នាយកដ្ឋានថ្មីនេះ



*ប្រជាកសិករកម្ពុជាប្រើប្រាស់ម៉ាស៊ីនច្រូតកាត់ប្រមូលផលស្រូវ*



*កម្មការិនីនៃរោងចក្រកាត់ដេរសម្លៀកបំពាក់មួយកន្លែងក្នុងរាជធានីភ្នំពេញ*



*ផ្សារធំថ្មី នៅរាជធានីភ្នំពេញ*



*ផ្សារទំនើប អ៊ីអន នៅរាជធានីភ្នំពេញ*

នឹងត្រូវបង្កើតឡើងដើម្បីប្រមូលផ្តុំរាល់សេវាដែលផ្តល់ឱ្យវិស័យឯកជន រួមមាន ការចុះបញ្ជីក្រុមហ៊ុន ការទទួលបានវិញ្ញាបនបត្រ និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសជាដើម ។ តាមរបាយការណ៍ពីក្រសួងពាណិជ្ជកម្មបានបង្ហាញថា ដោយសារតែកំណែទម្រង់ស៊ីជម្រៅរបស់ក្រសួង អាជីវកម្មថ្មីប្រមាណ ១០៦៦ បានចុះបញ្ជីគិតមកត្រឹមខែមីនា គឺកើនឡើង៧៦% ។ក្នុងនោះការចុះបញ្ជីអាជីវកម្មបរទេសកើន៦៦% ពី ២៩៤ ដល់ ៤៨៨ ខណៈការចុះបញ្ជីអាជីវកម្មក្នុងស្រុកកើនឡើង ៨៥% ពី ៣១៤ ដល់ ៥៧៨ ។ លោក កែន វឌ្ឍា អ្នកនាំពាក្យក្រសួងពាណិជ្ជកម្មបានថ្លែងថា ក្រសួងមិនបានមើលឃើញវិនិយោគិន ឬអាជីវករណាមានការព្រួយបារម្ភក្នុងការចាប់ផ្តើម ឬពង្រីកអាជីវកម្មរបស់ខ្លួននៅដើមឆ្នាំនេះទេ ទោះបីជាយើងមានស្ថានភាពនយោបាយស្មុគស្មាញខ្លះក៏ដោយ ។ គេឃើញថា កម្ពុជាយើងទទួលបានការកើនឡើងនៃអាជីវកម្មបរទេស និងក្នុងស្រុកយ៉ាងខ្លាំង ខណៈអាជីវកម្មមួយចំនួនបានពង្រីក ។ លោកបានលើកឡើងទៀតថា វាមិនមានន័យថាពួកគេមិនមានការបារម្ភនោះទេ ពួកគេបារម្ភ ប៉ុន្តែវិនិយោគិន និងពាណិជ្ជករជាច្រើនកំពុងសម្លឹងមើលទៅរកចំណុចល្អៗជាច្រើននៅក្នុងប្រទេសកម្ពុជាដូចជាយើងមានស្ថានភាពល្អផ្នែកម៉ាក្រូសេដ្ឋកិច្ច បរិយាកាសវិនិយោគល្អ ហើយពួកគេមិនគ្រាន់តែមើលឃើញនៅក្នុងរយៈពេលខ្លីប៉ុណ្ណោះទេ ប៉ុន្តែបានមើលឃើញក្នុងរយៈពេលវែងផងដែរ ។ ការកើនឡើងនេះបញ្ជាក់ថា កម្ពុជាកំពុងមានដំណើរការយ៉ាងល្អប្រសើរ ។ ការកើនឡើងនៃអាជីវកម្មថ្មីបណ្តាលមកពីការកែទម្រង់មួយចំនួនក្នុងក្រសួង ដូចជាដំណើរការនៃការចុះបញ្ជីដែលបទប្បញ្ញត្តិមួយចំនួនត្រូវបានផ្លាស់ប្តូរដើម្បីឱ្យការចុះបញ្ជីកាន់តែរហ័ស ។ បរិយាកាសអាជីវកម្មរបស់កម្ពុជាមានស្ថិរភាព វិនិយោគិនភាគច្រើនបានយល់យ៉ាងច្បាស់ពីប្រទេសរបស់យើង ដូច្នេះពួកគេមិនភ័យខ្លាចក្នុងការចាក់បញ្ចូលប្រាក់សម្រាប់អាជីវកម្ម ឬការវិនិយោគនោះទេ ។ តាមរបាយការណ៍ថ្មីពីធនាគារអភិវឌ្ឍន៍អាស៊ី ADB ដែលចេញផ្សាយកាលពីដើមខែមេសា បង្ហាញថា ការកែទម្រង់របស់រដ្ឋាភិបាល ដែលបានដាក់ចេញកាលពីខែមីនា ឆ្នាំ ២០១៤ ដើម្បីជួយសម្រួលដល់ពាណិជ្ជកម្មក្នុងស្រុក និងពាណិជ្ជកម្មក្រៅប្រទេស និងនីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្ម បានបន្ថែមលើគោលនយោបាយអភិវឌ្ឍន៍របស់រដ្ឋាភិបាលក្នុងការកំណត់ការអភិវឌ្ឍវិស័យឯកជន ដែលជាគោលដៅដ៏សំខាន់មួយ ។ អ្នកនាំពាក្យក្រសួងពាណិជ្ជកម្មបញ្ជាក់ថា ក្រសួងកំពុងព្យាយាមបន្ថែមទៀតក្នុងការជំរុញឱ្យមានអន្តរទំនាក់ទំនងរវាងឯកជន និងរដ្ឋាភិបាល ដើម្បីរកឱ្យឃើញបញ្ហាពិតប្រាកដសម្រាប់ការផ្លាស់ប្តូរ ហើយក្រសួងពាណិជ្ជកម្មនៅតែសហការគ្នាយ៉ាងជិតស្និទ្ធជាមួយវិស័យឯកជន ដើម្បីកែលម្អបន្ថែមទៀតនូវបរិយាកាសអាជីវកម្មរបស់យើង សំដៅទាក់ទាញពាណិជ្ជកម្មថ្មីៗឱ្យបានកាន់តែច្រើនសម្រាប់សេដ្ឋកិច្ច ។ របាយការណ៍ក្រសួងពាណិជ្ជកម្មបានឱ្យដឹងថា ក្រុមហ៊ុនចុះបញ្ជីជាច្រើនមកពីប្រទេសជប៉ុន ចិន កូរ៉េខាងត្បូង ម៉ាឡេស៊ី និងវៀតណាម ភាគច្រើនខាងផលិតកម្មរោងចក្រកាត់ដេរស្បែកជើងកសិកម្មកសិ-ឧស្សាហកម្មទេសចរណ៍ និងការកែច្នៃអាហារ ។

តាមរយៈការកែទម្រង់នេះ ទំហំពាណិជ្ជកម្មនាំចេញ នាំចូលសរុបរបស់កម្ពុជានៅត្រីមាសទីមួយឆ្នាំ ២០១៤ នេះកើនឡើង ១៥ %បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដោយសារតែភាពរឹងមាំនៃសេដ្ឋកិច្ច និងកំណើនលំហូរទុនវិនិយោគពីក្រៅប្រទេស ។ ទោះបីជាស្ថានភាពនយោបាយនៅក្នុងប្រទេសមានភាពរកាំរកូសបន្តិចក៏ដោយ ក៏ការធ្វើពាណិជ្ជកម្មរបស់កម្ពុជានៅក្នុងត្រីមាសទីមួយឆ្នាំនេះនៅតែទទួលបានកំណើនខ្ពស់គួរឱ្យកត់សម្គាល់បើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ។ កំណើននេះ បណ្តាលមកពីស្ថានភាពសេដ្ឋកិច្ចរបស់កម្ពុជាកាន់តែល្អប្រសើរ និងកំណើនលំហូរទុនវិនិយោគពីបរទេសពិសេសតាមរយៈការជំរុញគោលនយោបាយពិពិធកម្មសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ។ យោងតាមទិន្នន័យពីក្រសួងពាណិជ្ជកម្មបានបង្ហាញថា ទំហំពាណិជ្ជកម្មនាំចេញនាំចូលសរុបរបស់កម្ពុជានៅត្រីមាសទីមួយ

ឆ្នាំ២០១៤នេះ មានទឹកប្រាក់ប្រមាណ៤,៤៦ពាន់លានដុល្លារអាមេរិក បានកើនឡើង ១៥% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដែលកាលនោះមានប្រមាណ ៣,៨៨ ពាន់លានដុល្លារអាមេរិក។ ទិន្នន័យដដែលបង្ហាញទៀតថា ការនាំចេញរបស់កម្ពុជាចន្លោះពីខែមករាដល់ខែមីនា ឆ្នាំ២០១៤ មានទំហំទឹកប្រាក់ប្រមាណ ១,៩៩ ពាន់លានដុល្លារមេរិក បានកើនឡើង ១៩% ពីចំនួន ១,៦៧ ពាន់លានដុល្លារអាមេរិក។ ដោយឡែកទំហំទឹកប្រាក់នៃការនាំចូលវិញបានកើនឡើង ១២% គឺពីចំនួន ២,២១ ពាន់លានដុល្លារអាមេរិក រហូតទៅដល់ចំនួន ២,៤៧ ពាន់លានដុល្លារអាមេរិក។ ផលិតផលសំខាន់ៗដែលកម្ពុជាបានធ្វើការនាំចេញភាគច្រើនជាផលិតផលសម្លៀកបំពាក់ ស្បែកជើង ផលិតផលកសិកម្ម រួមមាន អង្ករ ដំឡូងមី ពោត ម្រេច គ្រាប់កាហ្វេ សណ្តែកសៀង សណ្តែកដី គ្រាប់ល្ង ជ័រកៅស៊ូក្រែប ឈើកែច្នៃ សត្វរស់ ផលនេសាទ និងស្ករ។ ចំណែកឯផលិតផលសំខាន់ៗដែលកម្ពុជានាំចូលវិញ ភាគច្រើនជាវត្ថុធាតុដើមកាត់ដេរ គ្រឿងសំណង់ យានជំនិះ ប្រេងឥន្ធនៈ ម្ហូបអាហារ ភេសជ្ជៈ ឱសថ បរិក្ខារពេទ្យ គ្រឿង សំអាង និងសារធាតុគីមី។ ប្រភពដដែលបានអោយដឹងទៀតថា កំណើននៃទំហំពាណិជ្ជកម្មនាំចេញនាំចូល របស់យើងមានការកើនឡើងនេះ ដោយសារតែកំណើនតម្រូវការបញ្ជាទិញពីខាងក្រៅ គួបផ្សំជាមួយនឹងសមត្ថភាពផលិតកម្មក្នុងស្រុកដែលកំពុងមានការរីកចម្រើន។ ពិសេសការជំរុញគោលនយោបាយពិពិធកម្មនាំចេញរបស់រដ្ឋាភិបាល និងការរឹតបន្តឹងចំណងមិត្តភាពរវាងភាគីកម្ពុជា ជាមួយប្រទេសដៃគូពាណិជ្ជកម្មក្នុងតំបន់ និងជុំវិញពិភពលោកដែលធ្វើឱ្យការដោះដូរពាណិជ្ជកម្មរបស់កម្ពុជាទទួលបានកំណើនខ្ពស់នៅដំណាច់ឆ្នាំនេះ។ ដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជារួមមាន សហរដ្ឋអាមេរិក សហគមន៍អឺរ៉ុប ចិន ជប៉ុន កូរ៉េខាងត្បូង កាណាដា ថៃ វៀតណាម និងម៉ាឡេស៊ី។

ចំពោះទំនាក់ទំនងធុរកិច្ចកម្ពុជា ថៃ លោកស្រី ជីវ៉ាន់ វង្សមង្គល អគ្គទីប្រឹក្សាពាណិជ្ជកម្មប្រចាំស្ថានទូតថៃបានថ្លែងក្នុងសន្និសីទសារព័ត៌មានស្តីពីការរៀបចំពិព័រណ៍ពាណិជ្ជកម្មប្រចាំឆ្នាំ ២០១៤ នៅកម្ពុជាថា ដោយសារប្រទេសថៃមានបញ្ហាវិបត្តិនយោបាយ នាំឱ្យអ្នករកស៊ីបង្វែមករកស៊ីនៅស្រុកខ្មែរច្រើន ព្រោះតែពួកគេមើលឃើញស្រុកខ្មែរមានសន្តិសុខល្អ ហើយបញ្ហានយោបាយក៏គ្មានរឿងអ្វីដែលយូរអង្វែងដែរ។ លោកស្រីបន្ថែមថា ក្រុមហ៊ុនដែលមកវិនិយោគនៅកម្ពុជា ជាប្រភេទរោងចក្រកាត់ដេរ ដែលមាននៅភ្នំពេញខ្លះ កោះកុងខ្លះ និងបន្ទាយមានជ័យខ្លះ។ ប្រភេទទី ២ គឺក្រុមហ៊ុនធ្វើវិនិយោគលើម៉ាស៊ីនកិនស្រូវ និងទី៣គឺជាប្រភេទសហគ្រាសធុនតូចនិងមធ្យម ។គួរបញ្ជាក់ផងដែរថា ទំហំពាណិជ្ជកម្មរវាងកម្ពុជា និងថៃ ក្នុងត្រីមាសទី ១ ឆ្នាំ ២០១៤ នេះ មានកំណើន ១៨ % ស្មើនឹងទំហំទឹកប្រាក់ ៨៥៥ លានដុល្លារអាមេរិក



មុខទំនិញនាំចូល គ្រឿងអេឡិចត្រូនិចបានដាក់លក់នៅតាមហាងនានា


សកម្មភាពមមាញឹករបស់អាជីវករនៅតាមទីផ្សារនានា ក្នុងរាជធានីភ្នំពេញ

បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ ២០១៣ ។ ដោយឡែក ពាណិជ្ជកម្មកម្ពុជា អាមេរិក តាមទិន្នន័យចុងក្រោយបង្ហាញថា ការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចអាមេរិក បានជំរុញឱ្យការនាំចូលពីកម្ពុជា បានកើនឡើង ១១ % ក្នុងអំឡុងត្រីមាសទី ១ នៅឆ្នាំនេះ។ ការនាំចូលរបស់អាមេរិកពីកម្ពុជាមានតម្លៃសរុប ៧៧១ លានដុល្លារនៅចុងខែមីនា កើនឡើងពី ៦៩៤ លានដុល្លារក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ លទ្ធផលនេះបានធ្វើឱ្យកម្ពុជាស្ទុះឡើងដល់ចំណាត់ថ្នាក់ទី ៥៨ នៅលើបញ្ជីនៃបណ្តាប្រទេសដែលនាំចូលទៅអាមេរិក។/


ផ្សារទំនើបសុវណ្ណានៅរាជធានីភ្នំពេញ

# សមិទ្ធផលនៃវិស័យអប់រំក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រឆ្នាំ ២០០៩-២០១៣

## • ទិសដៅជាអាទិភាពបន្ត គឺការលើកកម្ពស់គុណភាព

*នៅឆ្នាំ ២០១៤ នេះ ក្រសួងអប់រំ យុវជន និងកីឡា បានបញ្ចប់ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ៥ ឆ្នាំ លើកទី ៣ គឺ ២០០៩-២០១៣ ប្រកបដោយជោគជ័យ និងកំពុងចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៤-២០១៨ លើកទី ៤ ដែលឆ្លើយតបទៅនឹងអាទិភាពអប់រំនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ដោយផ្អែកលើទស្សនទាននិងចក្ខុវិស័យវែងឆ្ងាយនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាល ។ តាមរបាយការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា បានឱ្យដឹងថា វិស័យអប់រំនៅក្នុងឆ្នាំសិក្សា ២០១២-២០១៣ កន្លងទៅនេះ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ទាំងបរិមាណ និងគុណភាព រួមមាន ការរីកដុះដាលយ៉ាងខ្លាំងនៃសាលារៀនចំណេះទូទៅ គ្រឹះស្ថានឧត្តមសិក្សា និងចំនួនសិស្ស និស្សិតចុះឈ្មោះចូលរៀននៅគ្រប់ភូមិសិក្សាទាំងផ្នែកសាធារណៈ និងផ្នែកឯកជន ដែលនេះគឺជាមូលដ្ឋានគ្រឹះដ៏ចាំបាច់សម្រាប់ឈានទៅពង្រឹងគុណភាពអប់រំឱ្យកាន់តែប្រសើរឡើងថែមទៀត ។*

នៅក្នុងសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំកន្លងមក និងលើកទិសដៅសម្រាប់ឆ្នាំបន្ត ដែលបានប្រព្រឹត្តទៅកាលពីខែមីនាកន្លងទៅបានបង្ហាញថា នៅក្នុងឆ្នាំសិក្សា២០១២-២០១៣ វិស័យអប់រំទទួលលទ្ធផលជាវិជ្ជមានជាច្រើនគួរឱ្យកត់សម្គាល់ បើប្រៀបធៀបទៅនឹងចំណុចដៅនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ ។ ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំកសាងអគារសិក្សាជាច្រើននៅគ្រប់ច្រកល្ហកនៅទូទាំងប្រទេស ជាពិសេសនៅតាមតំបន់ព្រំដែន និងតំបន់ជួបការលំបាក ក្នុងគោលដៅបង្កិតសាលារៀនឱ្យនៅជិតលំនៅស្ថានរបស់ប្រជាជន ស្របតាមអនុសាសន៍ដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។ ជាលទ្ធផល នៅទូទាំងប្រទេសមានសាលាមត្តេយ្យសិក្សាចំនួន ៥ ៨០៧ សាលាបឋមសិក្សាចំនួន ៧ ២៣៦ អនុវិទ្យាល័យចំនួន ១ ២៧៩ និងវិទ្យាល័យចំនួន ៥៣១ ដែលក្នុងនោះ មានអគារចំនួន ៣ ៧០៥ ខ្នង ស្មើនឹង ១៩ ៣១៩ បន្ទប់ គិតត្រឹមថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០១៣ ដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ។



អគារនៃទីស្តីការក្រសួងអប់រំ យុវជន និងកីឡា

បច្ចុប្បន្ន អត្រាពិតនៃការសិក្សារបស់កុមារនៅបឋមសិក្សាសាធារណៈ និងឯកជន បានកើនដល់ ៩៨,២% ( ស្រី ៩៨,៥% ) និងមានសិស្សនិស្សិតនៅគ្រប់ភូមិសិក្សាប្រមាណ ៣ លាន ៥ សែននាក់ ។ តាមចំនួននេះអាចនិយាយបានថា ក្នុងចំនួនពលរដ្ឋកម្ពុជា ៤ នាក់ មានម្នាក់កំពុងអង្គុយសិក្សា ។ បុគ្គលិកអប់រំនៅទូទាំងប្រទេសមាន ១១២ ៧០៤ នាក់ ស្រី ៤១,៤៨% ។ ជាមួយគ្នានេះ គ្រឹះស្ថានឧត្តមសិក្សាមាន ១០៥ ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សារដ្ឋមាន ៣៩ និងឯកជនមាន ៦៦ ដែលមានទីតាំងស្ថិតនៅតាមរាជធានី ខេត្ត ១៩ ។ និស្សិតចាប់ពីថ្នាក់បរិញ្ញាបត្ររង ដល់បណ្ឌិតមានចំនួន ២៧១ ៥០៣ នាក់ នារីមាន ៣៨% ។

ក្នុងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពអប់រំ ក្រសួងអប់រំ យុវជន និងកីឡា បានកែលម្អកម្មវិធីសិក្សា និងផ្តល់សៀវភៅសិក្សា



សាកលវិទ្យាល័យភូមិន្ទភ្នំពេញ



សិស្ស និស្សិត កំពុងសិក្សាស្រាវជ្រាវឯកសារក្នុងបណ្ណាល័យ



*សាកលវិទ្យាល័យឯកជន zaman ក្នុងរាជធានីភ្នំពេញ*


*សាកលវិទ្យាល័យឯកជន ក្នុងខេត្តសៀមរាប*

សម្ភារៈបច្ចេកទេស ដើម្បីបម្រើឱ្យការរៀន ការបង្រៀន និងការស្រាវជ្រាវនៅតាមគ្រឹះស្ថានសិក្សា និងបានយកចិត្តទុកដាក់ដល់ការងារតម្រង់ទិសវិជ្ជាជីវៈនៅតាមវិទ្យាល័យ ចំណេះទូទៅ និងបច្ចេកទេស ។

ទន្ទឹមនេះ ក្រសួងបានធ្វើវិក្រឹតការគ្រូបង្រៀនជាប្រចាំដើម្បីលើកកម្ពស់សមត្ថភាពគ្រូដែលជាអ្នកផ្ដល់ការអប់រំដល់យុវជនជំនាន់ក្រោយឱ្យកាន់តែមានចំណេះដឹង បំណិន និងសីលធម៌ខ្ពស់ ស្របតាមចតុស្ដម្ភនៃគោលការណ៍អប់រំ គឺរៀនដើម្បីមានចំណេះដឹង រៀនដើម្បីមានចំណេះធ្វើ រៀនដើម្បីក្លាយជាពលរដ្ឋល្អ និងរៀនដើម្បីចេះរស់នៅជាមួយគ្នា ព្រមទាំងបណ្ដុះបណ្ដាលមន្ត្រីគ្រប់គ្រងគ្រប់កម្រិត ដើម្បីលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃអភិបាលកិច្ចល្អនៅក្នុងវិស័យអប់រំ ។ ដោយឡែក យន្តការធានាគុណភាពអប់រំ ត្រូវបានរៀបចំ និងកំពុងអនុវត្តជាជំហានៗ ដើម្បីពិនិត្យ និងវាយតម្លៃលើការងារសិក្សា និងការងារគ្រប់គ្រងនៅតាមគ្រឹះស្ថានសិក្សាទូទាំងប្រទេស ។

ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ស្ដីពីការអប់រំ ក្រសួងអប់រំ យុវជន និងកីឡា បាន និងកំពុងធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានដែលមានស្រាប់ និងកសាងលិខិតបទដ្ឋានបន្ថែមចាំបាច់ ព្រមទាំងរៀបចំគោលនយោបាយនានា សំដៅឆ្លើយតប និងឆ្ពោះទៅធ្វើកំណែទម្រង់ស៊ីជម្រៅការបណ្ដុះបណ្ដាលធនធានមនុស្ស នៅក្នុងបរិបទនៃសង្គមពុទ្ធិ ។ ជាក់ស្ដែងនៅឆ្នាំកន្លងទៅ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយអប់រំបច្ចេកទេសសម្រាប់សាលាបឋមសិក្សា មធ្យមសិក្សា គោលនយោបាយស្ដីពីធនធានមនុស្ស ក្នុងវិស័យអប់រំ គោលនយោបាយស្ដីពីគ្រូបង្រៀន និងសេចក្ដីណែនាំការអនុវត្តច្រកចេញចូលតែមួយ ។ល ។

ទន្ទឹមនេះ ក្រសួងបាន និងកំពុងកសាងគោលនយោបាយ និងផែនការអភិវឌ្ឍន៍មួយចំនួនទៀត ដូចជា គោលនយោបាយស្ដីពីការអភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅ ក្របខណ្ឌ ធានាគុណភាពអប់រំ គោលនយោបាយស្ដីពីអាហារូបករណ៍ ឧបត្ថម្ភធន និងឥណទានសិក្សាគោលនយោបាយស្ដីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា ការពិនិត្យឡើងវិញនូវមុខងារវិស័យអប់រំ ។ល ។

ចំពោះការងារយុវជន ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញការលើកកម្ពស់សកម្មភាព និងសមត្ថភាពយុវជន ដោយសហការជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធរបស់រដ្ឋ ឯកជន អង្គការសង្គមស៊ីវិល និងអង្គការអន្តរជាតិ ដើម្បីបង្កឱកាសបង្កើនការអប់រំជំនាញ និងអប់រំបច្ចេកទេស ជាពិសេសដល់យុវជនក្រីក្រ យុវជនពិការ យុវជនជនជាតិដើមភាគតិច និងយុវជនងាយរងគ្រោះ តាមរយៈការអភិវឌ្ឍសមត្ថភាពមជ្ឈមណ្ឌលធនធាន មជ្ឈមណ្ឌលសិក្សា សហគមន៍ មជ្ឈមណ្ឌលយុវជន និងបានបញ្ជ្រាបការអប់រំបំណិនជីវិតស្ដីពីមេរោគអេដស៍ ជំងឺអេដស៍ អំពើហិង្សា គ្រឿងញៀន សុខភាពផ្លូវភេទ សុវត្ថិភាពចរាចរណ៍ ការប្រើប្រាស់គ្រឿងស្រវឹង ។ល ។

ក្រសួងបានពង្រឹង និងពង្រីកក្រុមប្រឹក្សាកុមារ និងយុវជននៅតាមគ្រឹះស្ថានសិក្សាគ្រប់កម្រិត ពង្រីកសកម្មភាពចលនាកាយរឹទ្ធជាតិកម្ពុជា ក្រុមយុវជនស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា នៅតាមសាលារៀន សមាគមនិស្សិតនៅតាមគ្រឹះស្ថានឧត្ដមសិក្សា និងរៀបចំក្រុមយុវជនស្ម័គ្រចិត្តនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិឱ្យបានល្អថែមទៀត ។ក្រសួងក៏កំពុងរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា សម្រាប់ជំរុញការ


*និស្សិតដែលមកទទួលសញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាបត្ររង ដល់ថ្នាក់បណ្ឌិត*

កសាងសមត្ថភាពយុវជនឱ្យឆ្លើយតបបានទៅនឹងការរីកចម្រើនរបស់សង្គមជាតិផងដែរ ។

ជាមួយគ្នានេះ ការងារអប់រំកាយ និងកីឡា ក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ដែរ ។ ការគាំទ្រលើវិស័យនេះកាន់តែមានកំណើនឡើង ដោយសារមហាជនមានការយល់ដឹង និងចាប់អារម្មណ៍លើការថែរក្សាសុខភាព តាមរយៈការហាត់ប្រាណ និងការលេងកីឡា ។ វិស័យអប់រំកាយ និងកីឡា ជាសមាសភាគមួយដ៏សំខាន់ក្នុង ចំណោមសមាសភាគទាំង ៥ នៃការអប់រំ សម្រាប់ពង្រឹងកាយសម្បទា និងសុខភាពអ្នកសិក្សាដែលមិនអាចខ្វះមួយណាបានឡើយ ។ ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវកម្មវិធីសិក្សាអប់រំកាយ និងកីឡា សម្រាប់សាលារៀនបឋមសិក្សា ដែលជាថ្នាលគ្រឹះសម្រាប់អភិវឌ្ឍកាយសម្បទា គំនិត ប្រាជ្ញា និងស្មារតីរបស់កុមារ ។ ដើម្បីលើកកម្ពស់គុណភាពនិងប្រសិទ្ធភាព នៃការងារនេះ ក្រសួងអប់រំ យុវជននិង កីឡា កំពុងជំរុញការរៀបចំគោលនយោបាយជាតិស្តីពីការអភិវឌ្ឍការអប់រំកាយ និងកីឡា ។

ជាមួយនឹងការរីកចម្រើនទាំងនេះ ក្រសួងអប់រំ យុវជន និងកីឡា ក៏នៅមានបញ្ហាប្រឈមជាច្រើនទៀតដែលត្រូវពុះពារបន្តដោះស្រាយ ដូចជាបញ្ហាកង្វះគ្រូមត្តេយ្យសិក្សារដ្ឋ កង្វះគ្រូមធ្យមសិក្សាទុតិយភូមិ និងមធ្យមសិក្សាបឋមភូមិតាមមុខវិជ្ជាឯកទេសមួយចំនួននៅតាមវិទ្យាល័យ និងអនុវិទ្យាល័យដែលបង្កើតថ្មី ពិសេសនៅតំបន់ជួបការលំបាកកង្វះគ្រូឯកទេសផ្នែកភាសាបរទេសនៅបឋមសិក្សា គ្រូឯកទេសសម្រាប់អនុវត្តមុខវិជ្ជាអប់រំបច្ចេកទេស និងបំណិនជីវិត កង្វះគ្រូ និងបណ្ណារក្សនៅតំបន់ដាច់ស្រយាល និងសម្រាប់ការងារអប់រំក្រៅប្រព័ន្ធ ។ ក្រៅពីនេះក៏នៅមានកង្វះការបំប៉នជំនាញទន់មិនទាន់ដែលឆ្លើយតបទៅនឹងតម្រូវការរបស់យុវជន កង្វះព័ត៌មាន និងសមត្ថភាពជំនាញក្នុងការស្វែងរកការងារ និងការបង្កើតមុខរបររបស់យុវជនជាដើម ។



ការប្រកួតកីឡារបស់សិស្សានុសិស្សនៃសាលាបឋមសិក្សាជីបាជ្រោល ក្នុងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង




សិស្សានុសិស្សនៃសាលាបឋមសិក្សាសំព័រ ក្នុងព្រះរាជាណាចក្រកម្ពុជា



សិស្សកម្រិតមត្តេយ្យសិក្សា

ជាមួយនឹងការចាប់ផ្តើមអនុវត្តនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលនីតិកាលទី ៥ វិស័យអប់រំក៏កំពុងឈានចូលរបត់ថ្មីផងដែរ ។ ក្នុងគោលបំណងលើកកម្ពស់គុណភាពវិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវវិធានការមួយចំនួន ដើម្បីធ្វើកំណែទម្រង់វិស័យអប់រំដោយឈរលើមូលដ្ឋាននៃយុទ្ធ-សាស្ត្រចតុកោណនិងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៤-២០១៨ គឺការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការពង្រឹងការគ្រប់គ្រងបុគ្គលិក ការពង្រឹងការប្រឡងគ្រប់ប្រភេទ ការបង្កើតធនាគារខួរក្បាលវិស័យអប់រំ កំណែទម្រង់ឧត្តមសិក្សា ការបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវា អប់រំនៅគ្រប់កម្រិតសិក្សា ការអភិវឌ្ឍសម្រាប់យុវជននូវជំនាញបច្ចេកទេសនិងជំនាញទន់និងកែទម្រង់ការអប់រំកាយ និងកីឡា ។ នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨ ក៏បានផ្តោតការយកចិត្តទុកដាក់ខ្ពស់ផងដែរលើការពង្រីកការអប់រំកុមារតូច ការបង្កើនលទ្ធភាពទទួលបានការអប់រំនៅកម្រិតមធ្យមសិក្សា និងក្រោយមធ្យមសិក្សាប្រកបដោយគុណភាព ព្រមទាំងការពង្រីកការងារអប់រំក្រៅប្រព័ន្ធ និងការអប់រំបច្ចេកទេស ។/

# ទេពអប្សរា និងកាយវិការសំពះ

បុព្វបុរសខ្មែរក៏ឱ្យនាងរាំរបាំផ្សេងៗដែរ មានរបាំទេពមនោរម្យ របាំមុនីមេខលាជាដើម ។

ប្រទេសមួយចំនួនដែលទទួលឥទ្ធិពលវប្បធម៌សិល្បៈពីប្រទេសកម្ពុជា ក៏បានទទួលយករបាំខ្មែរជាច្រើនដែរ។ ចំពោះរបាំអប្សរា





*របាំអប្សរា និងចម្លាក់អប្សរានៅលើជញ្ជាំងប្រាសាទអង្គរវត្ត ខេត្តសៀមរាប*

ទំនៀមទម្លាប់ប្រពៃណីខ្មែរបានប្រកាន់យករបបមាតាធិបតេយ្យ ហើយតែងមានជំនឿថាស្ត្រីគឺជាអ្នកនាំមកនូវសិរីមង្គល ។ ចំណែកនាងទេពសុទ្ធតែជាស្ត្រីបរិសុទ្ធ នាងជាអ្នកតំណាងសុំក្ដីប្រោសប្រណីពីអាទិទេព ឬវត្ថុស័ក្ដិសិទ្ធ ហើយពាំនាំពរពីស្ថានសួគ៌មកវិញនូវសេចក្ដីសុខចម្រើន ក្សេមក្សាន្តជូនប្រជារាស្ត្រ និងប្រទេសជាតិ ។

នាងអប្សរា ត្រូវបានតំណាងឱ្យវប្បធម៌ខ្មែរ ឬជាមាតានៃប្រទេសកម្ពុជា ព្រោះកម្ពុជាកើតពីការចងសម្ព័ន្ធមេត្រីភាពរវាងឥសីកម្ពុស្វយម្ភូវ និងនាងអប្សរមេរា ។

នាងអប្សរទាំងឡាយរាំដោយសទ្ធាជ្រះថ្លាឧទ្ទិសដល់អាទិទេពក្នុងព្រហ្មញ្ញសាសនា ។ ក្រោយមក ព្រះមហាក្សត្រកម្ពុជាបែរមកកាន់ព្រះពុទ្ធសាសនា នាងក៏នៅតែមានតួនាទីរាំថ្វាយព្រះពុទ្ធជាអម្ចាស់ដដែល ។ តាមសេចក្ដីដំណាលក្នុងគម្ពីរព្រាហ្មណ៍ថា នាងជាស្រីសួគ៌មួយពួកដែលកើតមានដោយសាការកូរសមុទ្រទឹកដោះដើម្បីរកទឹកអម្រឹត ។ ក្នុងចលនាកូរសមុទ្រនោះ ក៏លេចចេញពីផ្ទៃសមុទ្រនូវសត្វចម្លែកអស្ចារ្យជាច្រើនបន្តបន្ទាប់ ដូចជាដំរីឰរាវ័តដែលព្រះឥន្ទ្រយកធ្វើជាជំនិះ ។ បន្ទាប់មកចេញតួទេពអប្សរជាច្រើនរាំពត់ពេនខ្លួននៅលើអាកាស ។ នាងជាទេវៈតំណាងសិល្បៈរាំជូនពរ និងក្ដីស្វាគមន៍។ បន្ទាប់មកក៏លេចចេញនាងស្រ៊ីជាទេវៈនៃសោភ័ណ រួចហើយលេចចេញនាងលក្ស្មីជាទេវៈតំណាងឱ្យទ្រព្យសម្បត្តិ ហើយនៅទីបញ្ចប់គឺជាទឹកអម្រឹតដែលជាកម្មវត្ថុ ។

ពាក្យអប្សរា(សំ)មានន័យដូចគ្នានឹងពាក្យអច្ឆរា (បា ) គឺជាស្រីសួគ៌មានសម្បុរស្រស់ថ្លាផូរផង់ ។ រូបនាងត្រូវបានបុព្វបុរសខ្មែរឆ្លាក់លើផ្ទាំងសិលានៃប្រាសាទជាច្រើន ពិសេសប្រាសាទអង្គរវត្តដែលមានរូបរាប់ពាន់ មានសណ្ឋានខុសប្លែកគ្នា ។ ម៉្យាងទៀតគេមិនអាចបន្លំបានឡើយ ។ មានមជ្ឈដ្ឋានបរទេសខ្លះបំភ្លៃរិះគន់ ដោយអគតិថា អប្សរាជាស្ត្រីពិសពុលគួរឱ្យខ្លាចរអា គេបានសើចចំអកចំពោះរូបគំនូរ ចម្លាក់ឈើ ឬចម្លាក់ថ្មដែលបង្ហាញក្បាច់រាំនៃនាងអប្សរា ។ ប៉ុន្តែក្បាច់រាំអប្សរាត្រូវបានបង្ហាញជូនពិភពលោកទាំងមូល ហើយការយល់ច្រឡំក៏បានសាបសូន្យអស់ ព្រោះអប្សរាបានបរិយាយប្រាប់តាមរយៈក្បាច់រាំ បញ្ជាក់ពីភាពបរិសុទ្ធដោយស្មោះអស់ពីចិត្ត ពោលគឺមុននឹងវិលត្រឡប់ទៅកាន់ឋានសួគ៌វិញ នាងបានបង្ហាញក្បាច់សំពះលា ប្រើតែកាយវិការលើកដៃប្រណមនិងលើកបន្ទូលប៉ុណ្ណោះ ដោយមិនបានប្រើដៃបង្គុំដៃសំពះ និងដៃខមាទោសឡើយ ។

ចំពោះប្រពៃណីសំពះរបស់ប្រជារាស្ត្រខ្មែរក៏បានទទួលការអប់រំបន្តពីបុព្វបុរសរបស់ខ្លួនដែលមានក្បួនខ្នាតដូចតទៅ : ១-ដៃបន្ទូល "លើកដៃបន្ទូលបួងសួង" គឺកំណត់យក

មេដៃទាំងពីរផ្ដុំដាក់ត្រឹមប្រជុំចិញ្ចើមឡើងទៅលើមានន័យថានេះជាការអធិដ្ឋានបួងសួងសំបូងសំរូង ប្រកាសប្ដឹងចំពោះវត្ថុស័ក្តិសិទ្ធអារុក្ខអារក្សអ្នកតា ទេវតា ឥន្ទ្រ ព្រហ្ម ពិសេសរំលឹកដល់គុណព្រះរតនត្រៃ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។ ២-ដៃបង្គំ " លើកដៃថ្វាយបង្គំ " គឺចំពោះលោកអ្នកមានគុណលើរូបយើង ។ កំណត់យកមេដៃទាំងពីរផ្ដុំដាក់លើចុងច្រមុះឡើងទៅត្រឹមប្រជុំចិញ្ចើម ។ ដៃបង្គំនេះមានន័យចំពោះអ្នកមានគុណអ្នកផ្ដល់កំណើតអ្នកបីបាច់រក្សា អ្នកផ្ដល់ចំណេះដឹងអាណាព្យាបាល មាតាបិតា គ្រូបាធ្យាយ ព្រះសង្ឃ ព្រះមហាក្សត្រ ។ ៣-ដៃសំពះ " សំពះសាធុ ពន " សំពះ ឬ ពននេះ គឺកំណត់យកមេដៃផ្ដុំគ្នាត្រឹមចន្លោះចង្កាឡើងទៅត្រឹមចុងច្រមុះ ។ មានន័យថា ការគោរពទំនាក់ទំនងប្រាស្រ័យការទាំងឡាយ ចៅហ្វាយនាយ អ្នកមានបណ្ដាស័ក្ដិខ្ពស់ជាង ឬវ័យចំណាស់ជាងខ្លួន ។ ការសំពះនេះ គេសង្កេតឃើញជាទូទៅកិច្ចស្វាគមន៍ជម្រាបសួរជម្រាបលាគ្នា ។ ៤-ដៃខមាទោស "សុំទទួលខុស " របៀបសំពះនេះគេច្រើនយកមេដៃទាំងពីរផ្ដុំគ្នាហើយលើកដៃដាក់ផ្ទប់ត្រឹមដើមទ្រូងលើកឡើងទៅត្រឹមក្រោមចង្កា ។ កាយវិការនេះ បញ្ជាក់ពីការទទួលស្គាល់នូវកំហុសខ្លួនឯង រួមជាមួយការសម្ដែងនូវការស្វាគមន៍ផងដែរ ។ ៥- ដៃប្រណម្យ "បវមខ្នាត" កាយវិការនេះ មិនរាប់បញ្ចូលទៅនឹងនៃការគោរពសំពះទាំង ៤ ខាងលើទេ ។ របៀបសំពះ នេះត្រូវផ្ដុំមេដៃទាំងពីរដាក់ចំចុងដង្ហើម ។ លក្ខណៈនេះ គឺជាការសង្រួមចិត្តប្រមូលអារម្មណ៍ស្ងឹងស្ងាត់ សមាធិដោយអារម្មណ៍មិនខ្វល់ខ្វាយ និងគ្មានសៅហ្មងអ្វីឡើយ ។ បវមខ្នាតនេះ គេសង្កេតឃើញរូបចម្លាក់ស្ត្រីម្នាក់លុតជង្គង់ ហើយលើកដៃប្រណម្យ ដែលខ្មែរយើងតែងហៅថា " ទេពប្រណម្យ " ។

ហេតុដូច្នេះហើយបានជាមុននឹងបញ្ចប់ យើងឃើញនាងទេពអប្សរាទាំងអស់អង្គុយចុះលុតជង្គង់ ប្រើកាយវិការលើកដៃប្រណម្យ ប្រមូលអារម្មណ៍ផ្ដោតចិត្ត រួចហើយទើបលើកដៃបន្ទួលជម្រាបទៅកាន់ទេវៈ ដែលនៅស្ថានសួគ៌ បន្ទាប់មកទើបនាងហោះកាត់ពពកខ្ពស់ទៅឆ្ងាយវិលទៅកាន់ស្ថានបរមសុខវិញ ។

"របាំអប្សរា"ជារបាំអមតៈជារបាំអច្ឆរិយៈកើតពីកោសល្យញាណរបស់បុព្វបុរសខ្មែរពិត ៗ ។

ខ្លឹមសារពិត តែងបង្ហាញនូវសញ្ញាពិតចំពោះការពិត ។

"ដកស្រង់ពីសៀវភៅរបាំអប្សរា"



ខ្នាតសំពះ



ចម្លាក់សំពះនៅជញ្ជាំងប្រាសាទបាយ័ន



តមកពីទំព័រទី ១៨

២០១៤ នេះ មានចំនួនទឹកប្រាក់ប្រមាណ ១០០,៦ លានដុល្លារអាមេរិក ។

គួររំលឹកថាទំហំពាណិជ្ជកម្មកម្ពុជា-ម៉ាឡេស៊ី ឆ្នាំ ២០១២ មានទឹកប្រាក់ ៣៧៦,១ លានដុល្លារ ដោយកើនឡើង ១៧,៣ % បើប្រៀបទៅនឹងឆ្នាំ ២០១១ ។ នៅក្នុងឆ្នាំ ២០១៣ កំណើននៃទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរបានកើនឡើង ១៣,៨ % ស្មើនឹងទឹកប្រាក់ ៤២៩,៥៤ លានដុល្លារ ។

ការវិនិយោគទុនរបស់ម៉ាឡេស៊ីនៅក្នុងប្រទេសកម្ពុជាមានចំនួន២,៦២ ពាន់លានដុល្លារ ។ម៉ាឡេស៊ីគឺជាអ្នកវិនិយោគទុនធំបំផុតទី៣នៅក្នុងប្រទេសកម្ពុជា ។

**គម្រោងវិនិយោគវិស័យសំណង់ និងអចលនវត្ថុ រយៈពេល ៤ ខែ :**

ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ បានឱ្យដឹងថា ការអនុម័តលើគម្រោងវិនិយោគសាងសង់ និងអចលនទ្រព្យក្នុងរយៈពេល ៤ ខែដើមឆ្នាំនេះ មានការកើនឡើងខ្លាំង ដែលមានតម្លៃសរុបឡើងដល់ ១,៤ ពាន់លានដុល្លារ កើនឡើងប្រហែល ៣០០% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ។

គួររំឭកថា ការអនុម័តលើគម្រោងវិនិយោគសាងសង់ និងអចលនទ្រព្យឆ្នាំ ២០១២ មានតម្លៃ ២,៨ ពាន់លានដុល្លារ ។/

# អត្ថប្រយោជន៍ផ្លែល្ពៅចំពោះសុខភាព



*ផ្លែល្ពៅផ្តល់សារសំខាន់ដល់សុខភាពមនុស្ស*



ល្ពៅជារុក្ខជាតិប្រភេទវល្លិវារលើដី ដើមលូតវែង ស្លឹករឹងរាងមូល ចំណែកផ្ការីកធំៗមានព៌ណលឿង។ ចំណែកផ្លែមានទំហំ និងទម្ងន់ប្រែប្រួលខ្លាំងទៅតាមពូជ រីឯគ្រាប់ល្ពៅរាងពងក្រពើ មានជ្រុងព៌ណស ឬលឿងព្រឿងៗ។ គេនិយមដាំដើមល្ពៅលើដីចម្ការ ឬដីមាត់ទន្លេសម្រាប់ធ្វើជាបន្លែ ។ គ្រាប់ល្ពៅប្រើជាថ្នាំបញ្ចុះតេនញ៉ា ដោយប្រើគ្រាប់ល្ពៅបកសំបកចេញរួចថ្លឹងចំនួន ១០០ ក្រាម សម្រាប់មនុស្សពេញវ័យបុកឱ្យម៉ត់ល្អ រួចលាយជាមួយទឹកស្ករ ឬទឹកឃ្មុំចំនួន ៥០ ទៅ ១០០ ក្រាម លាយឱ្យសព្វទុកផឹកមុនពេលបាយ ១ ម៉ោង ។ក្រោយផឹករួចបីម៉ោង គេផឹកថ្នាំបញ្ចុះប្រភេទអំបិល SULFATE DE MAGNESIUM ហើយពេលជុះត្រូវជុះដាក់កន្ថោរដែលមានទឹកក្តៅឧណ្ហៗ។ កម្រិតប្រើសាច់គ្រាប់ល្ពៅគឺក្មេងអាយុ ៣ ទៅ ៤ ឆ្នាំ ប្រើ ៣០ ក្រាម អាយុ ៥ ទៅ ៧ ឆ្នាំ ប្រើ ៥០ ក្រាម អាយុ ៧ ទៅ ១០ ឆ្នាំ ប្រើ ៧៥ ក្រាម។

ក្រៅពីគ្រាប់ផ្លែល្ពៅមានសាច់ពណ៌ក្រហមស្រស់ ផ្លែល្ពៅជាអាហារមួយក្នុងចំណោមអាហារជួយបំពេញថែមជាតិដែកបង្កើតឈាម ពិសេសសម្រាប់ស្ត្រីមានផ្ទៃពោះ។ តាមការស្រាវជ្រាវរបស់ពួកអ្នកវិទ្យាសាស្ត្រចិន ល្ពៅផ្ទុកយ៉ាងច្រើននូវប្រូតេអ៊ីន ការ៉ូតែន វីតាមីនអាមីណូអាស៊ីតកាល់ស្យូម ដែក...។ បរិមាណវីតាមីនសេក្នុងល្ពៅខ្ចីច្រើនជាងក្នុងល្ពៅទុំ។ ក៏ប៉ុន្តែក្នុងល្ពៅទុំ បរិមាណកាល់ស្យូមដែកការ៉ូតែនបែរជាខ្ពស់ជាងក្នុងល្ពៅខ្ចី សារជាតិបំប៉ននេះមានប្រសិទ្ធភាពក្នុងការទប់ស្កាត់ជំងឺហឺត ។ទស្សនៈនៃវេជ្ជសាស្ត្របុរាណចាត់ទុក ថាល្ពៅមានលក្ខណៈត្រជាក់ រសជាតិផ្អែម មានឥទ្ធិពលកម្ចាត់រលាក ប៉ូវក្រពះ ព្យាបាលរាករូស ហឺត...។

តាមការស្រាវជ្រាវថ្មីៗនេះ បង្ហាញថា ល្ពៅសម្បូរបរិមាណជាតិដែក និងស័ង្កសី ហើយស័ង្កសីមានឥទ្ធិពលផ្ទាល់ទៅដល់សមត្ថកិច្ចរបស់កោសិកាក្រហមឯជាតិដែកជាធាតុមូលដ្ឋានបង្កើតអេម៉ូក្លូប៊ីនជួយបំពេញបរិមាណឈាមឱ្យសរីរាង្គ។/



# គុណប្រយោជន៍នៃសាច់មាន់ខ្មៅ

តាមក្បួនចម្អិនម្ហូបចិន "មាន់ខ្មៅ" ត្រូវបានគេចាត់ទុកថាជាសាច់បក្សីដ៏ប្រពៃសម្រាប់ប៉ូវសុខភាព។ ពូជមាន់ខ្មៅ ឬមាន់រោមសូត្រ គេជឿថាជាសាច់សត្វដែលអាចប៉ូវកម្លាំង និងការពាររោគផ្សេងៗ ។

"មាន់ខ្មៅ" មិនមែនជាបក្សីរោមខ្មៅព្រិកឡើយ។ ផ្ទុយទៅវិញវាជាពូជសត្វមាន់ដែលមានរោមសក្បុសតែម្តង នៅពីក្រោមរោមសដូចសំឡីនោះគឺជាសាច់ និងស្បែកពណ៌ខ្មៅ ។ ជាងនេះទៅទៀតសូម្បីតែឆ្អឹង និងគ្រឿង ក្នុងរបស់វាក៏មានពណ៌ខ្មៅដូចគ្នាដែរ។



*សាច់មាន់ខ្មៅ ត្រូវបានគេចាត់ទុកថាជាសាច់បក្សីដ៏ប្រពៃសម្រាប់ប៉ូវសុខភាព*

តាមការពិតទៅមានពូជមាន់ខ្មៅជាច្រើនប្រភេទក្នុងពិភពលោក ជាពិសេសនៅបណ្តាប្រទេសអាស៊ី ប៉ុន្តែ មាន់ខ្មៅដែលល្អជាងគេ និងពេញនិយមក្នុងការទទួលទាននោះ គឺមានតែមាន់រោមសូត្រនេះទេ។ មាន់រោមសូត្រ ជាពូជសត្វមាន់ដែលមានរូបរាងស្រស់ស្អាត ដោយសារតែរោមដ៏ទន់ល្មើយដូចសរសៃសូត្រសក្បុស។ នៅបណ្តា ប្រទេសអឺរ៉ុបពូជមាន់ខ្មៅនេះត្រូវបានគេទិញយកទៅចិញ្ចឹមលម្អផ្ទះ ប៉ុន្តែនៅប្រទេសចិនវិញត្រូវបានគេយកទៅចម្អិនជាស៊ុបប៉ូវកម្លាំងដែលមានរសជាតិផ្អែមពីធម្មជាតិ។

"មាន់ខ្មៅ"ជាបក្សីមានស្លាបតែហើរមិនរួចនេះ ត្រូវបានគេរកឃើញថាមានគុណប្រយោជន៍ដល់សុខភាពតាំងពីសតវត្សរ៍ទី ៧ មកម្ល៉េះ ។ជាទូទៅស៊ុបមាន់ខ្មៅតែងត្រូវបានគេចម្អិនឱ្យនារីកូនខ្ចីទើបឆ្លងទន្លេរួចថ្មីថ្មោង ដើម្បីបង្កើនកម្លាំងកំហែង ។ស៊ុបមាន់ខ្មៅ ត្រូវបានគេជឿថាជាអាហារដែលផ្តល់ថាមពល ជំនួយឈាម សួត និងក្រពះ។ សាច់មាន់ខ្មៅគេកម្រនឹងអាំង ដុត ចៀន ឬឆាណាស់។

ប្រជាជនចិនច្រើនតែចម្អិនវាទាំងមូលដោយចំហុយ ឬស្ងោរជាមួយថ្នាំចិនសៃ និងមើមឃិនស៊ិន ដើម្បីទាញយកជាតិប៉ូវឱ្យបានច្រើនពីអាហារនេះ ។ អ្នកដែលនិយមទទួលទានសាច់មាន់ខ្មៅ តែងតែសរសើរពីរសជាតិសាច់ បក្សីនេះថាឆ្ងាញ់ ផុយ និងផ្អែមជាងសាច់មាន់លក់តាមផ្សារទូទៅ។

យោងតាមការសិក្សាផ្នែកហ្សែននៅប្រទេសចិន ដែលចុះផ្សាយកាលពីឆ្នាំ ២០១១ បានរកឃើញថា សាច់ មាន់ខ្មៅនេះសម្បូរទៅដោយសារធាតុម្យ៉ាងឈ្មោះថា កាណូស៊ីន (carnosine) ដែលជំនួយដល់ការបង្កើនសាច់ដុំ ជួយឱ្យសាច់ចាំ ពន្យឺតការវិវឌ្ឍទៅរកភាពចាស់ និងកាត់បន្ថយអត្រាប្រឈមនឹងជំងឺទឹកនោមផ្អែមជាដើម។/

បទសម្ភាសន៍

# គណបក្សប្រជាជនកម្ពុជា ជាក្តីសង្ឃឹម ជាបង្អែក និងជាទីទុកចិត្តតែមួយគត់របស់ប្រជាជនកម្ពុជា

*អស់រយៈពេល ៦៣ ឆ្នាំហើយដែលគណបក្សប្រជាជនកម្ពុជា បានបដិសន្ធិឡើង និងបានផ្សាភ្ជាប់សកម្មភាពរបស់ខ្លួនជាមួយជីវភាពនយោបាយ សង្គមកម្ពុជា ដោយឆ្លងកាត់ដំណាក់កាលលំបាកស្មុគស្មាញ និងការងាយស្រួលជាច្រើន ហើយគ្រប់សកម្មភាពទាំងនេះ សុទ្ធតែមានការចូលរួមគាំទ្រយ៉ាងក្លៀវក្លាពីសំណាក់ប្រជាជនកម្ពុជាទូទាំងប្រទេស ។ ពេលនេះ ប្រជាជនយើងបានចូលរួមសប្បាយរីករាយអបអរសាទរខួបអនុស្សាវរីយ៍លើកទី ៦៣ (២៨ មិថុនា ១៩៥១ -២៨ មិថុនា ២០១៤) ក្នុងបរិយាកាសដែលយើងក៏កំពុងតែសម្តែងនូវសមានចិត្តដ៏ឧត្តុង្គឧត្តម និងមិនងាករេក្នុងការគាំទ្រការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ទាំងក្នុងដំណាក់កាលបច្ចុប្បន្ន និងតទៅអនាគតទៀត ។ គណបក្សប្រជាជនកម្ពុជា ជាបង្អែកតែមួយគត់ ជាទីកក់ក្តៅ និងជាទីសង្ឃឹមរបស់ប្រជាជនកម្ពុជា ។ ក្នុងបទសម្ភាសន៍ជាមួយទស្សនាវដ្តីប្រជាជននាពេលនេះ បងប្អូនប្រជាជនយើងបានបង្ហាញនូវទស្សនៈផ្ទាល់ខ្លួនដូចខាងក្រោម :*



*ព្រះគ្រូប្រាសាទវង្សីសាសនធរោ **ឡាច លាង** ព្រះអនុគណៈក្រុងសៀមរាបបានមានសង្ឃដីកាថា : "តាមអាត្មាមើលឃើញ ដោយជាក់ស្តែងគណបក្សប្រជាជនកម្ពុជាបានជួយដឹកនាំសង្គ្រោះប្រជាជនឱ្យរួចផុតពីរបបប្រល័យពូជសាសន៍ដឹកនាំប្រទេសជាតិឱ្យរួចផុតពីសង្គ្រាម នាំមកនូវសុខសន្តិភាព សាមគ្គីភាព និងឯកភាពផ្ទៃក្នុងរឹងមាំ ។ សាសនាក៏មានការរីកចម្រើនខ្លាំងណាស់ មិនថាតែព្រះពុទ្ធសាសនាទេ សាសនាដទៃទៀតក៏មានការរីកលូតលាស់ដូចៗគ្នាទាំងអស់ ។ ប្រជាជនមានសិទ្ធិ មានជំនឿលើសាសនា មានសិទ្ធិសេរីភាពសព្វបែបយ៉ាង ។ ពុទ្ធសាសនិក ក៏ដូចជាអ្នកកាន់សាសនាដទៃបានកសាងវត្តអារាម ទីសក្ការបូជានានាគ្រប់ទីកន្លែង ។ គណបក្សប្រជាជនដឹកនាំប្រទេសធ្វើឱ្យមានការរីកចម្រើនលើគ្រប់វិស័យទាំងអស់ ទាំងអាណាចក្រ និងពុទ្ធចក្រ ហើយវិស័យទាំងពីរនេះរីកចម្រើនទន្ទឹមគ្នា ។ បើរីកចម្រើនតែពុទ្ធចក្រ ឯអាណាចក្រដើរថយក្រោយ ឬក៏រីកចម្រើនតែអាណាចក្រ ឯពុទ្ធចក្រមិនទៅមុខ នោះក៏មិនមានន័យថារីកចម្រើនដែរ ។ អាត្មាគាំទ្រគណបក្សប្រជាជនកម្ពុជាគ្រប់ពេលវេលាទាំងអស់ ពីព្រោះគណបក្សមួយនេះតំណាងឱ្យការរីកចម្រើន តំណាងឱ្យសុខសន្តិភាព វឌ្ឍនភាពជាតិ និងសាមគ្គីភាព ឯកភាពជាតិ" ។*



លោក **អ៊ុក សំអុន** អាយុ ៣៥ ឆ្នាំ ធ្វើការនៅរោងចក្រផលិតស្ករស នៅឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ បានមានប្រសាសន៍ថា : "បច្ចុប្បន្ននេះនៅភូមិឃុំរបស់ខ្ញុំ បើប្រៀបធៀបទៅនឹងអតីតកាលគឺវាខុសដាច់គ្នាស្រឡះ ។ ពីមុនឃុំអមលាំង គឺជាសមរភូមិ ប្រយុទ្ធគ្នាយ៉ាងក្តៅគគុករវាងកងទ័ពរាជរដ្ឋាភិបាលជាមួយក្រុមខ្មែរក្រហម ។ ប៉ុន្តែ បន្ទាប់ពីមានការអនុវត្តន៏គោលនយោបាយឈ្នះ ឈ្នះ របស់សម្តេចតេជោ **ហ៊ុន សែន** ក្នុងឆ្នាំ ១៩៩៨ អមលាំងបានប្រែក្លាយទៅជាតំបន់ដែលមានស្ថិរភាពសុវត្ថិភាពទាំងស្រុង ហើយចាប់ផ្តើមមានការអភិវឌ្ឍជាបណ្តើររហូតដល់សព្វថ្ងៃ ។ អតីតតំបន់ភ្នក់ភ្លើងសង្គ្រាមទទួលបានភាពរីកចម្រើនយ៉ាងច្រើន ដូចជា មានសាលារៀន មណ្ឌលសុខភាព ផ្សារ ភ្លើង អគ្គិសនីប្រើប្រាស់ ២៤ ម៉ោង ស្ពាន និងផ្លូវក្រាលកៅស៊ូកំពុងស្ថាបនា ។ សមិទ្ធផលទាំងនេះបានកើតចេញពីស្នាដៃ និងកិច្ចខិតខំប្រឹងប្រែងរបស់គណបក្សប្រជាជនកម្ពុជា ដែលមានសម្តេចអគ្គមហាទាំងបីជាប្រមុខដឹកនាំដ៏ឈ្លាសវៃ ។ បច្ចុប្បន្ននេះទៀតសោត សមាជិកសហភាពសហព័ន្ធយុវជនកម្ពុជាក៏បានចូលរួមយ៉ាងសកម្មធ្វើការងារជូនសង្គមយ៉ាងច្រើននៅក្នុងឃុំអមលាំងនេះដែរ" ។



*អ្នកស្រី **ហួន ស្រីមុំ** អាយុ ៣០ ឆ្នាំ រស់នៅភូមិលេខ ១ សង្កាត់លេខ ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ បានឱ្យដឹងថា : "ខ្ញុំសប្បាយរីករាយខ្លាំងណាស់ជាមួយនឹងការអភិវឌ្ឍទាំងឡាយដែលនាងខ្ញុំបានឃើញដោយផ្ទាល់ភ្នែក ទាំងនៅទីប្រជុំជន និងជនបទជាពិសេស គឺនៅសង្កាត់លេខ ១ ក្រុងព្រះសីហនុនេះតែម្តង ។ គណបក្សប្រជាជនកម្ពុជាដឹកនាំប្រទេស ៣៥ឆ្នាំ ហើយឆ្លងកាត់ពីបាតដៃទទេរហូតដល់មានការរីកចម្រើនដូចថ្ងៃនេះ តើយើងទៅរកឯណាទៀត? គណបក្សប្រជាជនឱ្យតែពេលគាត់សន្យា គឺគាត់ធ្វើឱ្យហើយ ពោលគឺគាត់មិនសន្យាចោល មិនសន្យាខ្យល់នោះទេ ។ ជាការកត់សម្គាល់មួយទៀត ខ្ញុំមើលឃើញថា គណបក្សប្រជាជនកម្ពុជាខិតខំខ្លាំងណាស់ឱ្យមានការសាមគ្គីជាតិ ឯកភាពគ្នា ប្រជាជនចេះស្រឡាញ់គ្នា ជឿទុកចិត្តគ្នា ។ ប៉ុន្តែផ្ទុយទៅវិញមួយរយៈពេលក្រោយនេះខ្ញុំឃើញគណបក្សប្រឆាំងបែរជាឃោសនាបំបែកបំបាក់សាមគ្គីជាតិ បំផុសឱ្យមានការរើសអើងពន្យុះអ្នកក្រឱ្យស្អប់អ្នកមាន បែងចែកវណ្ណៈសង្គមទៀតហើយ ។ ខ្ញុំប្រឆាំងដាច់ខាតនូវគំនិតអាក្រក់បែបនេះ ។ ទង្វើបែបនេះអាចធ្វើឱ្យយើងបែងចែកបានហើយ គណបក្សណាល្អ គណបក្សណាអាក្រក់ ។ នាងខ្ញុំសូមសន្យាថា មិនបោះបង់ចោលអ្វីដែលមាននៅក្នុងដៃស្រាប់ឃើញនឹងភ្នែកច្បាស់ហើយ ទៅស្រវាយកខ្យល់នោះទេ" ។*



លោក **គីម ប៊ុណ្ណា** ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តសៀមរាបបានមានប្រសាសន៍ថា : "ក្រោម ការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជាសព្វថ្ងៃពិតជាត្រឹមត្រូវ ហើយមានតែគណបក្សប្រជាជនកម្ពុជាមួយគត់ ដែល អាចដឹកនាំប្រទេសជាតិកម្ពុជាទៅរកត្រើយសុខសន្តិភាពសម្បូររុងរឿងនិងសុភមង្គលបាន ។គណបក្សបានប្រកាន់ខ្ជាប់នូវគោលបំណងនិងឧត្តមគតិរបស់ខ្លួនគឺឈរ-នៅខាងប្រជាជន រួមសុខទុក្ខជាមួយប្រជាជន ហ៊ានធ្វើពលិកម្មឥតរួញរា ជាមួយប្រជាជន ។ បន្ទាប់ពីមហាជ័យជម្នះជាប្រវត្តិសាស្ត្រលើរបបប្រល័យពូជសាសន៍ប៉ុលពតនាថ្ងៃ ៧ មករា ១៩៧៩ គណបក្សប្រជាជនបានដឹកនាំប្រទេសឆ្លងកាត់ការលំបាកច្រើនរាប់មិនអស់ សម្រេចបានស្នាដៃធំៗជាច្រើនជូនជាតិ និង ប្រជាជន ។ គណបក្សការពារបានរដ្ឋធម្មនុញ្ញ ការពារបាននិរន្តភាពរបស់រដ្ឋ និងជីវភា-

ពសេដ្ឋកិច្ច សង្គមរបស់ប្រជាជន ហើយប្រឆាំងរាល់សកម្មភាពប្រទូសរាយដែលធ្វើឱ្យប៉ះពាល់ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្ដាប់ធ្នាប់សង្គម ដោយឈរលើមូលដ្ឋានអនុវត្តយ៉ាងត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញនៃច្បាប់ជាធរមាន" ។



*យុវជន **ព្រាប បញ្ញាវុធ** អាយុ ២៦ ឆ្នាំ មុខរបរជាកម្មករក្រុមហ៊ុនស្រាបៀរអង្គរ រស់នៅសង្កាត់លេខ ១ ក្រុងព្រះសីហនុបានឱ្យដឹងថា : "ខ្ញុំជាយុវជនម្នាក់ ប៉ុន្តែខ្ញុំមានការចាប់អារម្មណ៍ខ្លាំងទៅលើគណបក្សនយោបាយនានា ហើយខ្ញុំបានកត់សម្គាល់ដោយក្ដីពេញចិត្ត ដោយការគាំទ្រខ្លាំងក្លា រឹងមាំឥតងាករេ ចំពោះការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ។ អ្នកដែលជួយសង្គ្រោះជាតិ គឺគណបក្សប្រជាជនកម្ពុជា ។ អ្នកដែលជួយឱ្យមានសុខសន្តិភាព មានការអភិវឌ្ឍ និងមានសុភមង្គល គឺគណបក្សប្រជាជនកម្ពុជា ។ បន្ទាប់ពីរកបានសន្តិភាពពេញលេញហើយ ប្រទេសជាតិមានការអភិវឌ្ឍលើគ្រប់វិស័យ រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនឱ្យថយចុះជាលំដាប់ ។ ជាក់ស្ដែងវិស័យហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ស្ពានធំៗ បានផ្សារភ្ជាប់ពីទីក្រុងទៅជនបទដាច់ស្រយាលគ្រប់ច្រកល្ហកនៃប្រទេស ក៏មានផ្លូវដែក កំពង់ផែធំៗ អាកាសយានដ្ឋានអន្តរជាតិ ។ ខ្ញុំមិនយល់ទាល់តែសោះថា ហេតុអ្វីបានជាពួកអគតិខ្លះមើលមិនឃើញពីសមិទ្ធផលទាំងនេះ ហើយបែរជាវាយប្រហារដោយសម្ដីគ្រោតគ្រាតបំផុតមកលើគណបក្សប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជាទៅវិញ ។ ទោះយ៉ាងណាខ្ញុំគាំទ្រដាច់ខាតការដឹកនាំដ៏ត្រឹមត្រូវរបស់គណបក្សប្រជាជនកម្ពុជា" ។*



លោក **ញឿយ តិម** ជនជាតិព្នង អាយុ ៤២ ឆ្នាំ ជាមេភូមិពូឡេះ ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី បានឱ្យដឹងថា : "ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជានិងរាជរដ្ឋាភិបាលកម្ពុជានិងមានសម្ដេចទាំងបីជាមេដឹកនាំដ៏ឆ្នើមបានធ្វើឱ្យភូមិឃុំរបស់ខ្ញុំមានការប្រែប្រួលនិងអភិវឌ្ឍន៍ច្រើនណាស់ ។ពីដើមភូមិជនជាតិបែបនេះមិនដែលស្គាល់អភិវឌ្ឍន៍យ៉ាងម៉េចទេសូម្បីតែពាក្យអភិវឌ្ឍន៍នេះក៏មិនដែលឮដែរ ។ ប៉ុន្តែបច្ចុប្បន្ននៅក្នុងភូមិមានបណ្ដាញអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ ប្រព័ន្ធផ្លូវថ្នល់ក៏ល្អប្រសើរសម្រាប់ធ្វើចរាចរទៅកាន់ទីផ្សារបានយ៉ាងងាយស្រួល ។ មានមណ្ឌលសុខភាពថែទាំជំងឺជូនប្រជាជន ។ ចំណុចលេចធ្លោមួយទៀតដែលខ្ញុំកត់សម្គាល់ គឺក្នុងការប្រកបរបរកសិកម្ម បងប្អូនប្រកបរបរធ្វើស្រែចម្ការ ដំណាំដាំដុះអចិន្ត្រៃយ៍ គឺមិនធ្វើក្នុងលក្ខណៈពនេចរដូចពីមុនទៀតទេ ។ គ្រួសារខ្លះមានលទ្ធភាពដាំកៅស៊ូជាលក្ខណៈគ្រួសារ បង្កើនបានជីវភាពរស់នៅប្រែក្លាយផ្ទះតូចទៅជាផ្ទះធំ មានលទ្ធភាពទិញរថយន្ត ទិញម៉ូតូ ប្រើប្រាស់ដូចគេឯង" ។



*ប្អូនស្រី **សួន ម៉ូនីកា** អាយុ ១៧ឆ្នាំ ជាសិស្ស មានទីលំនៅភូមិអូរអណ្ដូងទី ១ សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ បានបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនថា : "ខ្ញុំជាយុវជន ជាសិស្សមានក្ដីស្រឡាញ់ និងជឿជាក់ខ្លាំងណាស់ទៅលើការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ។ ខ្ញុំបានសម្រេចចិត្តចូលជាសមាជិកគណបក្សនៅឆ្នាំ ២០១៣ គឺមិនមែនដោយចៃដន្យឡើយ ខ្ញុំបានមើលឃើញ និងគិតគូរម៉ត់ចត់ ហើយជឿជាក់ច្បាស់ក្នុងចិត្តថា មានតែគណបក្សប្រជាជនកម្ពុជាមួយគត់ ដែលមានភាពចាស់ទុំខាងនយោបាយ ហើយសម្ដេចទាំងបីជាថ្នាក់ដឹកនាំ ប្រៀបបីដូចជាជីតាជាអ៊ំ ដ៏មានព្រហ្មវិហារធម៌ ដែលលោកតែងតែអាណិតស្រឡាញ់ប្រជាជន គាំទ្រយុវជន បង្កលក្ខណៈឱ្យបានចូលរៀនសូត្រ និងមានការងារធ្វើតាមបណ្ដារោងចក្រសហគ្រាស និងក្រុមហ៊ុននានាបង្កើនជីវភាពរស់នៅយ៉ាងសុខស្រួល ។ ជាធម្មតាទេវាតែងតែមានភាពអវិជ្ជមានខ្លះនៅក្នុងដំណើរការរីកចម្រើន ប៉ុន្តែយើងអាចកែលម្អជាបណ្ដើរៗ ។ ក្នុងនាមខ្ញុំជាយុវជនម្នាក់ ខ្ញុំក៏សូមឱ្យយុវជនមួយចំនួនដែលភ្លេចភ្លាំងជឿតាមការឃោសនាអកុសលបោកប្រាស់របស់អ្នកនយោបាយឱ្យឈប់ជឿ ។ ព្រោះយើងជាយុវជនត្រូវការតែការពិត ហើយមិនត្រូវស្រមើស្រមៃនូវអ្វីដែលយើងមិនបានឃើញ ហើយមិនសង្ឃឹមថាកើតមានទៀតផង" ។*



លោកយាយ **នុប ទូច** អាយុ ៧៨ ឆ្នាំ មានទីលំនៅនៅភូមិផ្លូវក្របី ឃុំអន្លង់វិល ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ បានរំលឹកពីប្រវត្តិរបស់គាត់ឡើងវិញថា :" ខ្ញុំបានធ្លាក់ជាស្ត្រីមេម៉ាយនៅចុងឆ្នាំ១៩៧៨ ដោយសារប៉ុលពតយកប្ដីទៅសម្លាប់ ។ ដោយសារគុណបុណ្យថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ ខ្ញុំក៏បានមករស់នៅជាមួយកូនចំនួន ៦នាក់ ។ ជាភ័ព្វសំណាង កូនប្រុសរបស់ខ្ញុំ ៤នាក់ បានស្ម័គ្រចិត្តចេញទៅបម្រើជាតិ ដើម្បីការពារការវិលត្រឡប់មកវិញនៃរបបប្រល័យពូជសាសន៍ ។ ខ្ញុំបានរស់រានមានជីវិតដល់សព្វថ្ងៃជាមួយកូនៗមកដល់ពេលនេះគឺដោយសារគុណបុណ្យរបស់គណបក្សប្រជាជនកម្ពុជាដែលដឹកនាំដោយសម្ដេច **ហ៊ុន សែន** សម្ដេច **ហេង សំរិន** និងសម្ដេច **ជា ស៊ីម** ។ ខ្ញុំនិងកូនៗទាំងអស់ត្រូវតែដឹងគុណចំពោះគណបក្សប្រជាជនកម្ពុជា ។ ខ្ញុំមិនបោះឆ្នោតឱ្យគណបក្សណាផ្សេងៗក្រៅពីគណបក្សប្រជាជនទេ ។ ខ្ញុំមិនផ្សងព្រេងទេ ព្រោះខ្លាចធ្លាក់ទៅក្នុងគ្រោះមហន្តរាយម្ដងទៀតដូចក្នុងរបបប្រល័យពូជសាសន៍ប៉ុល ពត" ។



ប្អូនប្រុស **កែវ សុភ័ក្រា** អាយុ ២២ឆ្នាំ ជាសិស្ស រស់នៅសង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញបាន និយាយឱ្យដឹងដែរថា: " ខ្ញុំនៅវ័យក្មេងក៏ពិតមែន ប៉ុន្តែខ្ញុំតែងសិក្សាស្វែងយល់ពីអ្វីដែលកើតមានក្នុងសង្គមកម្ពុជា ជាពិសេសក្រោយពេលដែលរបបប៉ុលពតឡើងកាន់អំណាចនៅឆ្នាំ ១៩៧៥ ។ យុវជនយើងនៅក្មេងងាយគេពង្វក់បាន ហេតុនេះតែងក្លាយទៅជាឧបករណ៍របស់អ្នកនយោបាយ ។ នៅក្នុងសង្គ្រាមឆ្នាំ១៩៧០-៧៥ យុវជនត្រូវគេពន្យុះឱ្យកាន់អាវុធ ដើម្បីប្រយុទ្ធបង្ហូរឈាមគ្នា ។ ក្នុងរបបប៉ុលពតយុវជនត្រូវគេពង្វក់ឱ្យសម្លាប់ពុក ម៉ែ បងប្អូនខ្លួនឯង និងប្រជាជន ដោយឥតញញើតដៃ ។ ទម្រាំតែយើងឈានមកដល់ដំណាក់កាលប៉ុណ្ណេះគឺត្រូវឆ្លងកាត់ការលំបាកច្រើនណាស់ ។ហេតុនេះយុវជនយើងមិនត្រូវចាញ់បោកនរណាទៀតទេ ។គេពន្យុះយើងឱ្យសម្លាប់គ្នា

ឱ្យគុំកួនគ្នា ពេលឃាមចាប់ផ្ដើមហូរគេ រត់ចោលស្រុកទៅបាត់ ។ ហេតុនេះ យើងត្រូវសិក្សាឱ្យច្បាស់ពីអតីតកាល កំណត់ឱ្យច្បាស់ពីទីតាំងដែលយើងត្រូវឈរក្នុងបច្ចុប្បន្នកាល ហើយសម្លឹងឆ្ពោះទៅមុខដោយកំណត់គោលដៅឱ្យច្បាស់ ។ តើគណបក្សនយោបាយមួយណា ដែលធ្លាប់ កម្សត់ត្រាំត្រែងជាមួយយាយតាយើង ពុកម៉ែយើង និងរូបយើង? មានតែគណបក្សប្រជាជនកម្ពុជាមួយគត់ ។ ដូច្នេះ មិនចាំបាច់សង្ស័យទេ បើគ្មានគណបក្សប្រជាជនដឹកនាំទេ ហើយយើងប្រគល់វាសនទៅឱ្យពួកក្បាលមិនជាប់ជើងមិន ជាប់ដីវិញនោះ វាសនាយើងគឺវិលទៅរកអតីតកាលប្រកបដោយសោកនាដកម្មទៀតហើយ" ។



លោក **ថាំង សុលី** អាយុ ៦៥ ឆ្នាំ រស់នៅភូមិផ្សារ ឃុំអន្លង់ត្នោត ស្រុកក្រគរ ខេត្តពោធិ៍សាត់ បានមានប្រសាសន៍ថា : "ខ្ញុំសូមចូលរួមសម្ដែងការអបអរសាទរចំពោះខួបកំណើតរបស់គណបក្សប្រជាជនកម្ពុជា ។ ខ្ញុំជាសមាជិកសកម្មម្នាក់របស់គណបក្សតាំងពីឆ្នាំ ១៩៧៩ មករហូតដល់ថ្ងៃនេះ ខ្ញុំគ្មានការរារែកចិត្ត គ្មានសង្ស័យពីការដឹកនាំដ៏ត្រឹមត្រូវ និងប្រកបដោយភាពឈ្លាសវៃរបស់សម្ដេចអគ្គមហាទាំបីឡើយ ។ មានគេមកឃោសនាវាយប្រហារអញ្ចេះ អញ្ចុះសព្វបែបសព្វយ៉ាងហើយ ប៉ុន្ដែជំហររឹងមាំរបស់ខ្ញុំចំពោះគណបក្សប្រជាជនគឺមិនទ្រេតទ្រោតឡើយ ។ គេមកឃោសនាតែពីរឿងភូតកុហក អត់ដែលបានឃើញធ្វើអ្វីឱ្យប្រជាជនទុកធ្វើជាអនុស្សាវរីយ៍មួយសោះ ។ មកភរហើយទៅបាត់ ដល់ប្រជាជនអត់ជឿចោទថា ប្រជាជនល្ងង់ លុះដល់ប្រជាជនបដិសេធមិនឱ្យចូលភូមិឃុំរបស់គេចោទថាគេប្រើហឹង្សាថាគេផ្ដាច់ការ ។គណបក្សធុននេះសូមចៀសឱ្យឆ្ងាយពីភូមិស្រុករបស់ខ្ញុំ ។ប្រជាជននៅភូមិខ្ញុំមិនស្វាគមន៍ទេ ។យើងកំពុងតែរស់នៅយ៉ាងសុខសាន្ដជាមួយគណបក្សប្រជាជនកម្ពុជា ។ ខ្ញុំទទួលស្គាល់ថាមានភាពអសកម្ម មានចន្លោះប្រហោង មានអំពើពុករលួយ ប៉ុន្ដែគណបក្សប្រជាជន និងរាជរដ្ឋាភិបាលកំពុងដោះស្រាយយ៉ាងម៉ឺងម៉ាត់បំផុត ។ ខ្ញុំជឿជាក់លើគណបក្សប្រជាជនកម្ពុជា គ្មានគណបក្សណាអាចមកជំនួសគណបក្សប្រជាជនដែលជារបស់ប្រជាជន និងជាទីជឿទុកចិត្តរបស់ប្រជាជនបានឡើយ ។



លោកស្រី **សួន ផល្លីដា** អាយុ ៣៣ ឆ្នាំ ជាប្រជាពលរដ្ឋរស់នៅក្នុងទីរួមខេត្តកំពត មានចំណាប់អារម្មណ៍ថា : គណបក្សប្រជាជនកម្ពុជា គឺជាគណបក្សតែមួយគត់ដែលមានវ័យចំណាស់ជាងគេ មានបទពិសោធន៍យ៉ាងច្រើន ហើយថ្នាក់ដឹកនាំរបស់គណបក្សសុទ្ធតែជាអ្នកចាស់ទុំខាងនយោបាយ ជាអ្នកដឹកនាំមានស្នាដៃឆ្នើម គ្មាននរណាអាចប្រៀបផ្ទឹមបានឡើយ ។ គណបក្សតែងតែផ្សារភ្ជាប់ជាមួយប្រជាជន និងគិតគូរពីសុខទុកចរបស់ប្រជាជនដូចជាការជួយសង្គ្រោះប្រជាជនឱ្យរួចផុតពីរបបប្រល័យពូជសាសន៍ ការស្វះស្វែងបង្កើតឱ្យមាននូវសុខសន្ដិភាព សេរីភាព និងការអភិវឌ្ឍគ្រប់វិស័យ ។ខ្ញុំនៅតែបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា ដើម្បីបានសម្ដេចទាំងបីបន្ដដឹកនាំប្រទេសជាតិទៅថ្ងៃមុខទៀត ។សមេតចតេជោ **ហ៊ុន សែន** ជាមេដឹកនាំឈ្លាសវៃ មានចក្ខុវិស័យវែងឆ្ងាយ និងជាមេដឹកនាំដ៏ឆ្នើមគ្មាននរណាអាចប្រៀបប្រដូចបានទេ" ។



លោក **ម៉ៅ សៀប** អាយុ ៤៨ ឆ្នាំ ជាបុគ្គលិករោងពុម្ពអរិយធម៌ ផ្នែកទីផ្សារ បច្ចុប្បន្នរស់នៅស្រុកពញាឮ ខេត្តកណ្ដាល បានមើល ឃើញថា ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ប្រទេសជាតិ និងប្រជាជនទទួលបានសមិទ្ធផលថ្មីៗជាច្រើនលើគ្រប់វិស័យ ។ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្ដេចអគ្គមហាសេនាបតីតេជា ហ៊ុន សែន បានអនុវត្តបញ្ចប់ដោយជោគជ័យនូវ កម្មវិធីនយោបាយ និងយុទ្ធសាស្ដ្រចតុកោណដំណាក់កាលទី ២ នៅក្នុងនីតិកាលទី ៤ នៃរដ្ឋសភា ដែលធ្វើឱ្យប្រទេសជាតិទទួលបាន សុខសន្ដិភាព ស្ថិរភាព សន្តិសុខ សណ្ដាប់ធ្នាប់សង្គម ប្រជាធិបតេយ្យ ការអភិវឌ្ឍ និងអធិបតេយ្យជាតិ ។ កាលពីជំនាន់មុន ប្រជា- ជនកម្ពុជា និងគ្រួសារខ្ញុំរស់នៅមិនដែលបានទទួលសេចក៏តសុខសប្បាយដូចបច្ចុប្បន្ននេះទេ ។កាលក្នុងរបបប៉ុលពតគឺវាបំផ្លាញខ្ទេចខ្ទីសូម្បីតែអាយុជីវិតប្រជាជនយើងក៏វាសម្លាប់ស្ទើរតែដាច់ពូជ ។ប៉ុន្ដែបចចុប្បន្ននេះដោយសារសម្ដេចតេជោ **ហ៊ុន សែន** ស្រុក ភូមិខ្ញុំមានការរីកចម្រើន ។ ខ្ញុំធ្លាប់បានឃើញតាមទូរទស្សន៍ គឺសម្ដេចមានសន្ដានចិត្តល្អ ចុះជួបជាមួយប្រជាជនជានិច្ច ហើយសម្ដេចបានយកចិត្តទុកដាក់ដល់ជីវភាពរស់នៅ របស់បងប្អូនជនដោយមិនប្រកាន់អ្វីទាំងអស់ ។ ខ្ញុំនៅតែបន្ដគាំទ្រការដឹកនាំរបស់សម្ដេចទាំងបី ព្រោះបានដឹកនាំប្រសទសជាតិ និងប្រជាជនជួបតែសុខសន្ដិភាព និងការអភិវឌ្ឍ ។



ប្អូនស្រី **រ័ត្ន គន្ធា** អាយុ ១៧ ឆ្នាំ រស់នៅក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ បច្ចុប្បន្នជាសិស្សវិទ្យាល័យ **ជា ស៊ីម** បឹងកេងកង បានបញ្ជាក់ថា "ទោះបីជាខ្ញុំកើតមិនទាន់របបខ្មែរក្រហម ដែលបានកាប់សម្លាប់ប្រជាជនយ៉ាងព្រៃផ្សៃក៏ដោយតែបច្ចុប្បន្ន ខ្ញុំរស់នៅដោយសុខសានណាក្រោមការីកនាំរបស់គណបក្សប្រជាជនកម្ពុជា ដែលមានសម្ដេចទាំង ៣ ជាប្រមុខពិសេស សម្ដេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ដ្រីនៃព្រះរាជាណាចក្រកម្ពុជា ។ សម្ដេចតេជោ បានដឹកនាំប្រទេសឱ្យមានការរីកចម្រើនពីមួយឆ្នាំ ទៅមួយឆ្នាំ ពីមួយអាណត្តិទៅមួយអាណត្តិ ធ្វើឱ្យប្រជាជនរស់នៅប្រកបដោយភាពសុខសាន្តធ្វើឱ្យប្រទេសជាតិមានការរីកចម្រើន ជាពិសេសទៅទៀតនោះគឺបានធ្វើឱ្យប្រទេសកម្ពុជាយើងមានមុខមានមាត់ស្មើភាព ស្មើសិទ្ធិដូចបណ្ដាប្រទេសនានាលើពិភពលោក" ។



លោក **ឈុត ចន្ថា** អាយុ ៣១ ឆ្នាំ ជាបុគ្គលិកក្រុមហ៊ុនឯកជន បច្ចុប្បន្នរស់នៅក្នុងសង្កាត់ទួលសង្កែ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ បានមានទស្សនៈយល់ឃើញថា គណបក្សប្រជាជនកម្ពុជាធ្វើអ្វីៗគ្រប់យ៉ាងដើម្បីការពាររដ្ឋធម្មនុញ្ញ ការពារលទ្ធិប្រជាធិបតេយ្យ ហើយក៏មិនអនុញ្ញាតឱ្យកម្លាំងនយោបាយណា ឬមជ្ឈដ្ឋានអគតិណាមកបំផ្លាញដំណើរការរីកចម្រើនរបស់ជាតិ និងរាល់សមិទ្ធផលដែលប្រជាជនសម្រេចបានយ៉ាងលំបាកលំបិននោះបានឡើយ ព្រោះបច្ចុប្បន្ន យើងបាន និងកំពុងសេនៅក្នុងសុខសន្ដិភាព និងការរីកចម្រើន ។ហេតុនេះ ខ្ញុំនៅតែបន្ដគាំទ្រការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ដែលជានិច្ចកាលគណបក្សប្រជាជនកម្ពុជាជាគណបក្សតែមួយគត់ដែលផ្ដល់នូវក្ដីសង្ឃឹមសម្រាប់អនាគតប្រទេសជាតិ និងប្រជាជន ។



## ចម្រៀងអបអរសាទរខួបទី ៦៣
## ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា

- បក្សប្រជាជន រឹងមាំជានិច្ច    បំពេញភារកិច្ច បម្រើខេមរា
  គោរពកាន់ខ្ជាប់ តាមច្បាប់រដ្ឋា    ធម្មនុញ្ញថ្លៃថ្លា ជាច្បាប់កំពូល ។

(ពោល) :

គណបក្សប្រជាជនកម្ពុជាប្ដេជ្ញាការពារ    រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
ដើម្បីសន្តិភាព ស្ថិរភាព    ប្រជាធិបតេយ្យ និងអភិវឌ្ឍន៍ ។

- បក្សកាន់ចង្កូត ប្រសូតពីរាស្ដ្រ    ជោគជ័យត្រចះ ឃើញច្បាស់យុត្តិធម៌
  រាស្ដ្រអបអរបក្ស បោះឆ្នោតគាំទ្រ    ដឹកនាំនគរ អនាគតថ្លៃថ្លា ។
- រដ្ឋសភាឧត្តម ស្ថាប័នតំណាង    ខិតខំកសាង ច្បាប់គ្រងរដ្ឋា
  រដ្ឋាភិបាលរឹងមាំ កសាងការពារ    ដឹកនាំកម្ពុជា តាមច្បាប់ឥតល្មៀង ។
- ជ័យជម្នះថ្មី ល្បីសព្វទិសា    ជ្រើសក្រុមប្រឹក្សា រាជធានី ខេត្ត ខណ្ឌ ស្រុក ក្រុង
  ប្រជាសាទរ គាំទ្រក្លាខ្លាំង    រួបរួមកម្លាំង កសាងទឹកដី ។
- ប្រជាធិបតេយ្យ អាស្រ័យលើច្បាប់    ការពារគោរព ជ្រោងលើកតម្កើង
  ជាតិនិងសាសនា ព្រះមហាក្សត្រយើង    កម្ពុជាថ្កុំថ្កើង ឡើងខ្ពស់ត្រដែត ។

(ពោល) :

បញ្ញាប្រាជ្ញបុណ្យ សម្ដេចទាំងបី    ពោធិសាល ចក្រី តេជោឧត្តម
មគ្គុទ្ទេសក៏ឈ្លាសវៃ ជំហររឹងមាំ    ពុះពារដឹកនាំ នគរបានសុខ
គណបក្សប្រជាជន និងការអភិវឌ្ឍ ។

- បក្សប្រជាជន គោលការណ៍គ្រប់គ្រង    បានកែទម្រង់ ស្ទង់ព្យាករណ៍ស្រេច
  ប្រាំឆ្នាំបន្ត កកើនសេដ្ឋកិច្ច    សម្រាំងសម្រេច កែស៊ីជម្រៅ ។
- បក្សប្រជាជន អត់ធន់ថែមទៀត    បង្កើនគុណភាព សមត្ថភាពឱ្យជ្រៅ
  បូកបទពិសោធន៍ ស្រូតដើរឱ្យត្រូវ    តម្រង់តម្រូវ លើផ្លូវចតុកោណ ។
- បក្សប្រជាជន និងវិនិយោគ    បរទេសចូលមក ក្នុងស្រុកក៏មាន
  ដើម្បីជីវភាព រៀបជាជំហាន    ប្រជាជនមាន ការងារគ្រប់ដៃ ។

(ពោល) :

បក្សប្រជាជន សេដ្ឋកិច្ចបៃតង    កសិកម្មបំព្រង ផលផងពេញផ្ទៃ
ទេសចរណ៍វប្បធម៌ អង្គរល្បាញល្បី    ឧស្សាហកម្មកើនថ្មី ចីរភាពបរិស្ថាន ។

- បក្សប្រជាជន បន្តអនុវត្ត    ចតុកោណល្អផុត ដំណាក់ទីបី
  ផ្ដល់សេវាល្អ គុណភាពប្រពៃ    រីកគ្រប់វិស័យ សង្គមរុងរឿង ។

(ពោល) :

ជយោ ! គណបក្សប្រជាជនកម្ពុជា    ជយោ ! សន្តិភាព
ជយោ ! ព្រះរាជាណាចក្រកម្ពុជាដ៏រុងរឿង

- ហុកសិបបីឆ្នាំ បក្សប្រជាជន    បុព្វហេតុសែនធ្ងន់ រំដោះទឹកដី
  សាងសន្តិភាព នាំសិទ្ធិសេរី    សាងសង្គមថ្មី សុខសាន្តរៀងអើយ ។/




### ពន្លត់ភ្លើង

៣ថ្ងៃហើយ ដែលនាងសាអែមសម្រាលបានកូនប្រុសតូចច្រឡឹងមួយ តែមានសម្បុរខ្មៅព្រិក ។ ចំណែកចឹកសាំជាឪពុក សាច់សដូចសំឡី សែនមួហ្មងក្នុងចិត្តកើតក្ដីសង្ស័យទើបគំហកសួរ :

- អេហ៎ ... អាប៉េអាទូចនេះជាកូនអ្នកណា អ្ហ៎ាស ?
- មានអ្នកណាទៀត គឺអាហ៊ាឯងហ្នឹងហើយ !
- មិនជឿ ! អួមិនជឿឡេ ! បើកូនអួម៉េចមិនសដូចអួ?
- អើ អាហ៊ាឯងសមែនហើយ តែមកពីអាហ៊ាឯងមានទម្លាប់អាក្រក់ ទើបកូនខ្មៅអ៊ីចឹង។
- អ្ហ៎ាស ... អួទម្លាប់អាក្រក់យ៉ាងម៉េចខ្លះ ?
- អើ... គឺឱ្យតែដល់ពេលហ្នឹង តាំងស្ទុះទៅពន្លត់ចង្កៀង ដឹងហើយនៅ?
- ខៅប៉េ ខុសពីអួសោះ ! ។

### សួរភ្លោម ឆ្លើយភ្លែត

នាល្ងាចមួយ ពេលបានជួបគ្នាជាចៃដន្យ នាងម៉ក់ សួរនាងម៉ាច :

- គ្នាមិនយល់ទាល់តែសោះ ហេតុអីឯងយកប្ដីចាស់ម្ល៉េះ?
- លុយចាស់ លុយថ្មី ក៏ជាលុយចាយបានដូចគ្នា ឬក៏ពេលចាយលុយ និងទទួលលុយ ឯងរើសរកលុយណាថ្មីច្រើងទើបបោះពុម្ព? ។

### ភ្លេចឈ្មោះ

ថ្ងៃមួយលោកតាម៉ែនបានហៅយុវជនជុតនៅផ្ទះក្បែរទៅហូបបាយនៅផ្ទះគាត់ ក្នុងឱកាសខួបអាពាហ៍ពិពាហ៍គំរប់ ៦០ឆ្នាំ របស់ប្ដីប្រពន្ធគាត់ ។ ពេលបាយទឹករួចរាល់ យាយម៉ក់ក្រោកឈរនិយាយ :

- បងសម្លាញ់ អូនទៅឆុងតែមកជូនណ៎ា !
- បាទ អរគុណ អូនសម្លាញ់ !

លុះលោកយាយម៉ក់ចេញផុត នាយជុតនិយាយខ្សឹបៗជាមួយតាម៉ែន :

- ខ្ញុំសុំសរសើរ លោកអ៊ំដោយស្មោះ រៀបការជាមួយអ៊ំស្រី ៦០ឆ្នាំហើយ នៅតែរក្សាទឹកដមស្នេហា ផ្អែមល្ហែមដូចកាលនៅកំលោះក្រមុំ។ មិនថាពេលណាជាពេលណាទេ ខ្ញុំតែងឮលោកអ៊ំប្រើពាក្យផ្អែមល្ហែមហៅ អ៊ំស្រី "អូនសម្លាញ់" ឯអ៊ំស្រី ឆ្លើយវិញ "ចា៎ះ បងសម្លាញ់" ឬក៏ថា "ព្រលឹងមាសបង" ជាដើម។ ស្នេហារបៀបនេះ ពិតជាមិនងាយរកបានទេ។

លោកតាម៉ែនខ្សឹបតបវិញ :

- មិនមែនពួកអ៊ំចង់ប្រើពាក្យទាំងហ្នឹង ហៅប្ដីប្រពន្ធចាស់ៗរបស់ខ្លួន ដូចកាលទើបរៀបការថ្មីថ្មោងទេ តាមពិត គឺមកពីអ៊ំទាំងពីរនាក់ ភ្លេចឈ្មោះគ្នាយូរមកហើយ ។/

បោះពុម្ពដោយ រោងពុម្ព **អរិយធម៌** ផ្ទះលេខ ៩២, ផ្លូវលេខ ៥៩៤, សង្កាត់បឹងកក់ II ខណ្ឌទួលគោក-ភ្នំពេញ
H/P : 012 935 822 / Tel : 023 885 188 / Fax : 023 885 189 E-mail : ariyathoar@yahoo.com / ariyathoar@online.com.kh

# អ្នកឧបត្ថម្ភ ទស្សនាវដ្ដី ប្រជាជន លេខ ១៥៧

| | | | | | |
|---|---|---|---|---|---|
| ១- | ឯ.ឧ | **កែ** | **គឹមយ៉ាន** | *សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ប្រធានក្រុមការងារចុះខេត្តបន្ទាយមានជ័យ* | ១០០ ដុល្លារ |
| ២- | ឯ.ឧ | **ចម** | **ប្រសិទ្ធ** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងលោកជំទាវ* | ២០០ ដុល្លារ |
| ៣- | ឯ.ឧ | **មិន** | **ឃិន** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា និងលោកជំទាវ* ***ខួន ឆួន*** | ១០០ ដុល្លារ |
| ៤- | ឯ.ឧ | **ត្រាំ** | **អ៊ីវតឹក** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងសាធារណការ និងដឹកជញ្ជូន* | ១០០ ដុល្លារ |
| ៥- | ឯ.ឧ | **ថោង** | **ខុន** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងទេសចរណ៍* | ១០០ ដុល្លារ |
| ៦- | ឯ.ឧ | **លន់** | **លឹមថៃ** | *ប្រធានគណៈកម្មាធិការគណបក្សខេត្តកំពង់ចាម* | ១០០ ដុល្លារ |
| ៧- | ឯ.ឧ | **ជៀង** | **អំ** | *ប្រធានគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង* | ១០០ ដុល្លារ |
| ៨- | ឯ.ឧ | **ខូយ** | **សុខា** | *អនុប្រធានគណៈកម្មាធិការគណបក្សខេត្តពោធិសាត់* | ១០០ ដុល្លារ |
| ៩- | ឯ.ឧ | **អ៊ូស្មាន** | **ហាស្សាន់** | *ប្រធានគណៈចលនាសាសនិកឥស្លាមនៃគណបក្សប្រជាជនកម្ពុជា* | ១០០ ដុល្លារ |
| ១០- | ឯ.ឧ | **សរ** | **ចាំរ៉ុង** | *ប្រធានគណៈកម្មាធិការគណបក្សខេត្តក្រចេះ* | ១០០ ដុល្លារ |
| ១១- | ឯ.ឧ | **ផា** | **សុជាតិវង្ស** | *ប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ* | ១០០ ដុល្លារ |
| ១២- | ឯ.ឧ | **ឈិត** | **សុខុន** | *អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ* | ១០០ ដុល្លារ |
| ១៣- | ឯ.ឧ | **ម៉ម** | **ប៊ុននាង** | *សមាជិកព្រឹទ្ធសភា* | ១០០ ដុល្លារ |
| ១៤- | ឯ.ឧ | **ប្រាក់** | **ចំរើន** | *សមាជិកព្រឹទ្ធសភា* | ១០០ ដុល្លារ |
| ១៥- | ឯ.ឧ | **គង់** | **វិបុល** | *ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋាន នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ* | ១០០ ដុល្លារ |
| ១៦- | ឯ.ឧ | **អ៊ឹន** | **វីរជាតិ** | *រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី* | ១០០ ដុល្លារ |
| ១៧- | ឯ.ឧ | **យូ** | **តិរម្យ** | *សមាជិកក្រុមការងារចុះខេត្តកំពង់ស្ពឺ ប្រធានក្រុមការងារចុះស្រុកឱរ៉ាល់* | ១០០ ដុល្លារ |
| ១៨- | គណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | | | | ១០០ ដុល្លារ |
| ១៩- | គណៈកម្មាធិការគណបក្សខេត្តសៀមរាប | | | | ១០០ ដុល្លារ |
| ២០- | គណៈកម្មាធិការគណបក្សខេត្តបន្ទាយមានជ័យ | | | | ៥០ ដុល្លារ |
| ២១- | គណៈកម្មាធិការគណបក្សក្រសួងកិច្ចការនារី | | | | ៥០ ដុល្លារ |
| ២២- | ឯ.ឧ | **លឹម** | **គានហោ** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក* | ២០០.០០០ ៛ |
| ២៣- | ឯ.ឧ | **ម៉ម** | **ប៊ុនហេង** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងសុខាភិបាល* | ៥០ ដុល្លារ |
| ២៤- | ឯ.ឧ | **ថា** | **យ៉ាវ** | *អនុប្រធានគណៈកម្មាធិការគណបក្សធនាគារជាតិនៃកម្ពុជា* | ២១៣.៤៧០៛ |
| ២៥- | ឯ.ឧ | **ជូ** | **យិនស៊ីម** | *រដ្ឋលេខាធិការក្រសួងសុខាភិបាល* | ៥០ ដុល្លារ |
| ២៦- | ឯ.ឧ | **អ៊ឹក** | **ប្រាថ្នា** | *រដ្ឋលេខាធិការក្រសួងព័ត៌មាន* | ២០០.០០០ ៛ |
| ២៧- | ឯ.ឧ | **ប៉ាវ** | **ហាមផាន** | *អនុប្រធានគណៈកម្មាធិការគណបក្សខេត្តរតនគិរី* | ៥០ ដុល្លារ |
| ២៨- | ឯ.ឧ | **សូ** | **ជុងហួរ** | *ប្រធានក្រុមប្រឹក្សាខេត្តព្រះសីហនុ* | ៥០ ដុល្លារ |
| ២៩- | ឯ.ឧ | **ចាយ** | **បូរិន្ទ** | *អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម* | ៥០ ដុល្លារ |
| ៣០- | ឯ.ឧ | **នរៈ** | **រតនៈវឌ្ឍនោ** | *រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា* | ២០០.០០០ ៛ |
| ៣១- | ឯ.ឧ | **ឃួន** | **រ៉ានីន** | *រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា* | ៥០ ដុល្លារ |
| ៣២- | ឯ.ឧ | **ប៊ុន** | **លឹមហេង** | *អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី* | ២០០.០០០៛ |
| ៣៣- | ឯ.ឧ | **សេង** | **ទៀង** | *ជំនួយការផ្ទាល់សម្ដេចអគ្គមហាសេនាបតីតេជោ* ***ហ៊ុន សែន*** | ២០០.០០០៛ |
| ៣៤- | ឧកញ៉ា | **ម៉ក់** | **គឹមហុង** | *ប្រធានអគ្គនាយកចំការកៅស៊ូជប់* | ២០០.០០០៛ |
| ៣៥- | ឯ.ឧ | **ម៉ៅ** | **ប៊ុនណារិន** | *សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា* | ១០០.០០០៛ |
| ៣៦- | ឯ.ឧ | **ម៉ែន** | **ស៊ីផាន់** | *សមាជិកព្រឹទ្ធសភា* | ១០០.០០០៛ |
| ៣៧- | ឯ.ឧ | **សុន** | **គន្ធរ** | *រដ្ឋមន្ត្រីប្រតិភូអមសម្ដេចនាយករដ្ឋមន្ត្រី* | ១០០.០០០៛ |
| ៣៨- | ឯ.ឧ | **ប៉ាន** | **ប៊ុនធឿន** | *រដ្ឋលេខាធិការក្រសួងផែនការ* | ១០០.០០០៛ |
| ៣៩- | លោកជំទាវ | **ស៊ឹង** | **ស៊ីយុត** | | ១០០.០០០៛ |
| ៤០- | ឯ.ឧ | **គឹម** | **ឆា** | *ប្រធានក្រុមប្រឹក្សាខេត្តស្វាយរៀង* | ១០០.០០០៛ |
| ៤១- | ឯ.ឧ | **គាំម** | **កុសល** | *ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី* ***ហេង សំរិន*** | ១០០.០០០៛ |
| ៤២- | ឯ.ឧ | **ប៊ិច** | **សុវណ្ណ** | | ១០០.០០០៛ |
| ៤៣- | ឯ.ឧបណ្ឌិត | **មាស** | **ប៊ូ** | *អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍* | ១០០.០០០៛ |
| ៤៤- | លោកជំទាវ | **និត្យ** | **ច័ន្ទតារីន** | *អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់* | ១០០.០០០៛ |
| ៤៥- | ឯ.ឧ | **ធា** | **ច័ន្ទលីដា** | *ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី* ***ហេង សំរិន*** | ១០០.០០០៛ |
| ៤៦- | ឯ.ឧ | **ម៉ែន** | **វិបុល** | *ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង* | ១០០.០០០៛ |
| ៤៧- | ឯ.ឧ | **ជួន** | **ថេរ៉ាវ៉ាត** | *ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី ហេង សំរិន* | ១០០.០០០៛ |
| ៤៨- | ឯ.ឧ | **ម៉ៅ** | **ឡាំង** | *ទីប្រឹក្សាឯកឧត្ដម* ***ខួន សុទ្ធារ៉ា*** *អនុប្រធានទី ១ រដ្ឋសភា* | ១០០.០០០៛ |
| ៤៩- | ឯ.ឧ | **ឆាយ** | **ឫទ្ធិសែន** | *អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនគរូបនីយកម្ម និងសំណង់* | ១០០.០០០៛ |
| ៥០- | ឯ.ឧ | **អ៊ឹន** | **ឆាលី** | *សមាជិកគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណបក្សខេត្តកោះកុង* | ១០០.០០០៛ |
| ៥១- | លោក | **អោម** | **ចន** | *ប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិនៃអគ្គនាយកដ្ឋានពន្ធដារ* | ១០០.០០០៛ |
| ៥២- | លោក | **សាំ** | **ពិសិដ្ឋ** | *ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ* | ១០០.០០០៛ |
| ៥៣- | លោក | **សុខ** | **វិសាលសម្បត្តិ** | *អនុប្រធានក្រុមការងារចុះជួយឃុំព្រៃដើមថ្នឹង និងឃុំព្នៅ១ ស្រុកស៊ីធរកណ្ដាល ប្រធានក្រុមហ៊ុនសម្បត្តិមហាសាល* | ១០០.០០០៛ |
| ៥៤- | លោកជំទាវ | **ខេង** | **សំវ៉ាដា** | *រដ្ឋលេខាធិការក្រសួងកិច្ចការនារី* | ៥០.០០០៛ |
| ៥៥- | ឯ.ឧ | **សាយ** | **បូរិន** | *ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី* ***ហេង សំរិន*** | ៥០.០០០៛ |
| ៥៦- | ឯ.ឧ | **សេង** | **គឹមសាន** | *ជំនួយការសម្ដេចអគ្គមហាធម្មពោធិសាល* ***ជា ស៊ីម*** | ៥០.០០០៛ |
| ៥៧- | ឯ.ឧ | **ពត** | **ចាន់នី** | *សមាជិកក្រុមការងារចុះជួយខេត្តកំពង់ចាម* | ៥០.០០០៛ |
| ៥៨- | ឯ.ឧ | **ហេង** | **វណ្ណា** | *សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ* | ៥០.០០០៛ |
| ៥៩- | លោកជំទាវ | **សឿ** | **ច័ន្ទថា** | | ៥០.០០០៛ |
| ៦០- | លោក | **ជា** | **វុទ្ធី** | *សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ* | ៥០.០០០៛ |
| ៦១- | លោក | **ហួត** | **ពៅ** | *ប្រធាននាយកដ្ឋាននីតិវិធីនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា* | ៥០.០០០៛ |

# អ្នកឧបត្ថម្ភ ទស្សនាវដ្តី ប្រជាជន លេខ ១៥៧

| | | | | | |
|---|---|---|---|---|---|
| ៦២- | កញ្ញា | ផាង | និតហ្វើរី | មន្ត្រីក្រសួងទេសចរណ៍ | ៥០.០០០៛ |
| ៦៣- | លោក | ទ៉ោ | ម៉េងថ្នន | អភិបាលក្រុងប៉ោយប៉ែត | ៥០.០០០៛ |
| ៦៤- | លោក | អ៊ុំ | រាត្រី | ប្រធានគណៈកម្មាធិការគណបក្សក្រុងសេរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៦៥- | លោក | កែវ | សែន | ប្រធានគណៈកម្មាធិការគណបក្សស្រុកអូរជ្រៅ | ៥០.០០០៛ |
| ៦៦- | លោក | សួន | សុធី | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៦៧- | លោក | គាត | ហ៊ុល | ប្រធានគណៈកម្មាធិការគណបក្សសង្កាត់ផ្សារកណ្ដាល ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៦៨- | លោក | ចាប | ឌីណា | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ខណ្ឌដូនពេញ | ៥០.០០០៛ |
| ៦៩- | ឯ.ឧ | វេង | សាខុន | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ៤០.០០០៛ |
| ៧០- | លោក | លី | សារី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ប្រធានមន្ទីររៀបចំដែនដី ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៧១- | លោក | គឹម | សុវណ្ណ | ប្រធានមន្ទីរសាធារណការ ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៧២- | គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជា ប្រចាំគណៈកម្មាធិការសម្របសម្រួលខ្មែរកម្ពុជាក្រោម | | | | ៤០.០០០៛ |
| ៧៣- | ឯ.ឧ | ស៊ិន | វុទ្ធី | សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ៣០.០០០៛ |
| ៧៤- | ឯ.ឧ | ឈុំ | វណ្ណារិទ្ធ | អភិបាលរងខេត្តបន្ទាយមានជ័យ | ៣០.០០០៛ |
| ៧៥- | លោក | ម៉ៅ | សុខលីម | អនុប្រធានមជ្ឈមណ្ឌលជាតិវេជ្ជសាស្ត្របូរាណក្រសួងសុខាភិបាល សមាជិកក្រុមការងារចុះខេត្តតាកែវ | ៣០.០០០៛ |
| ៧៦- | លោក | ចាន់ | ស៊ុំណាត | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ៣០.០០០៛ |
| ៧៧- | លោក | ឃុ | ពៅ | អភិបាលស្រុកស្វាយចេក | ៣០.០០០៛ |
| ៧៨- | លោក | ទេព | វិសិដ្ឋ | អនុប្រធានគណៈត្រួតពិនិត្យគណបក្សខេត្តព្រះសីហនុ | ៣០.០០០៛ |
| ៧៩- | កញ្ញា | កែវ | សុជាតា | អនុប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា | ២៥.០០០៛ |
| ៨០- | ឯ.ឧ | ចុង | ផែត | អភិបាលរងខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៨១- | ឯ.ឧ | ទេស | ចំនួគីរី | សមាជិកក្រុមប្រឹក្សាខេត្តសៀមរាប | ២០.០០០៛ |
| ៨២- | លោក | ឈា | ប៊ុនរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ២០.០០០៛ |
| ៨៣- | លោក | ម៉ៅ | ហាក់ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ២០.០០០៛ |
| ៨៤- | លោក | លឹម | វីរក្ស | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ២០.០០០៛ |
| ៨៥- | លោក | លឹម | ថេង | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ២០.០០០៛ |
| ៨៦- | លោក | ឃ្លោក | សំអាង | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម | ២០.០០០៛ |
| ៨៧- | លោក | ជា | គឹមលីន | ប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា | ២០.០០០៛ |
| ៨៨- | លោក | ទូច | សារ៉េត | ប្រធានការិយាល័យគណនេយ្យកសិកម្ម ខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៨៩- | លោក | ហ្វាង | ថ្វិន | ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | ២០.០០០៛ |
| ៩០- | លោក | ម៉ី | វុឌ្ឍា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ២០.០០០៛ |
| ៩១- | លោក | អ៊ុក | គឹមអាន | មន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ២០.០០០៛ |
| ៩២- | លោក | គួច | ចាន់និត្យ | អាជីវករ ខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៩៣- | លោក | អ៊ុក | ទូច | ប្រជាជនភូមិអូររអិល ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន | ២០.០០០៛ |
| ៩៤- | លោក | លី | សារុន | មន្ត្រីក្រសួងហិរញ្ញវត្ថុ | ១៥.០០០៛ |
| ៩៥- | លោក | អ៊ុច | សាវ៉ន | អនុប្រធានមន្ទីរកសិកម្ម ខេត្តបន្ទាយមានជ័យ | ១៥.០០០៛ |
| ៩៦- | ឯ.ឧ | សេង | សុមុនី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា | ១០.០០០៛ |
| ៩៧- | ឯ.ឧ | ប៊ុញ | សច្ចៈ | អគ្គនាយកកិច្ចការបច្ចេកទេសនៃក្រសួងធនធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩៨- | លោក | ម៉ី | លីហ្វួត | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម | ១០.០០០៛ |
| ៩៩- | លោក | ជួន | វណ្ណរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០០- | លោក | ម៉ម | ប្រួស | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០១- | លោក | សៅ | សម្ផស្ស | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០២- | លោក | ឈុន | ប៊ុនឈឿន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៣- | លោក | ថេង | ប៊ុនតេង | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៤- | លោក | ស្វាយ | សុគន្ធី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៥- | លោក | សុខ | ចំណាន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៦- | លោក | សៅ | សម្ភារ | ប្រធានការិយាល័យបណ្ដុះបណ្ដាលនៃនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០៧- | លោក | ទិត | ចរិយា | ប្រធានការិយាល័យគណនេយ្យនាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០៨- | លោក | សែម | សំណាង | ប្រធានការិយាល័យគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនាយកដ្ឋានធារាសាស្ត្រ កសិកម្ម នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០៩- | លោក | សុខ | តារា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១០- | លោក | សុ | ផល្លី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១១- | លោក | ហួត | ឆាន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១២- | លោក | ទឹម | វុដ្ឋារី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១៣- | លោក | ណុប | រៀមណី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១៤- | លោក | សារុន | សម្បត្តិ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១៥- | លោក | សរ | វិចិត្រ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១៦- | លោក | ទូច | សុផល្លា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១៧- | លោក | ជុំ | ឧត្តរ៉ា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១៨- | លោក | ឈ្លាង | ប៊ុយ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១៩- | លោក | យស់ | ធុល | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង | ១០.០០០៛ |
| ១២០- | លោក | ឡុង | ចន្ធា | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង | ១០.០០០៛ |
| ១២១- | លោក | ឡាច | តីរ៉ាត់ | សមាជិកក្រុមការងារចុះស្រុកបាភ្នំ ខេត្តព្រៃវែង | ១០.០០០៛ |
| ១២២- | លោក | ឈាង | សុវណ្ណារ៉ា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ១០.០០០៛ |




**និពន្ធនាយក :**

**លោក តាក ស៊ុនអ៊ី**

**គណៈកម្មការនិពន្ធ**

១. លោក ខៀវ ណារី

២. លោក អ៊ឹម សុន្ទរៈ

៣. លោក វង្ស សារ៉ុផ

៤. លោក ទាវ សារៈមុនី

៥. លោក សុខ សុធន

**លេខានិពន្ធ**

១. លោក ជុំ សម្បត្តិ

២. លោក ម៉ក់ ឈិន

**អ្នកបកប្រែភាសា**

១. លោកស្រី ម៉ែន នារីសោភ័គ

**អ្នកថតរូប**

១. លោក សុផាត វីរៈមុនី

**វិចិត្រករ**

១. លោក ធា សារ៉ុផ



អាស័យដ្ឋាន :

លេខ ២០៣

មហាវិថី ព្រះនរោត្តម

ភ្នំពេញ-កម្ពុជា

ទូរស័ព្ទលេខ :

០២៣ ២១៩ ០៦៥

**Address :**

**No 203 Preah**

**Norodom Bld.**

**Phnom Penh Cambodia**

**Tel : 023 219 065**


# មាតិកា

# Contents




សុន្ទរកថា
សម្ដេចអគ្គមហាពញាចក្រី
**ហេង សំរិន**
ប្រធានរដ្ឋសភា
ប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា
ថ្លែងក្នុងពិធីមីទ្ទិញរំឭក
ខួបអនុស្សាវរីយ៍លើកទី ៦៣
ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា

**៦**



កម្ពុជា និងបង់ក្លាដែស
បាននិងកំពុងអភិវឌ្ឍភាព
ជាដៃគូដ៏រឹងមាំ និងមានផល
ប្រយោជន៍ទៅវិញទៅមក

**១០**



សម្ដេចតេជោ
បញ្ជាក់អំពីជំហរក្នុងការចរចា
ការពង្រឹងនិរន្តរភាពរបស់រដ្ឋ
និងជីវភាពសេដ្ឋកិច្ច សង្គម
• ប្រែក្លាយការលំបាកពីការវិលត្រឡប់
របស់ពលករយើងទៅជាកាលានុវត្តភាពថ្មី

**១២**



កិច្ចប្រជុំ APA បានប្រព្រឹត្តទៅដោយ
ជោគជ័យនៅរាជធានីភ្នំពេញ

**១៥**

**ក្របមុខ**

ទិដ្ឋភាពក្នុងអង្គមីទ្ទិញរំឭក
ខួបអនុស្សាវរីយ៍លើកទី ៦៣
ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា
(២៨.០៦.១៩៥១-២៨.០៦.២០១៤)

វិចារណកថា : ពង្រឹងតួនាទីដឹកនាំរបស់គណបក្ស ផ្សារភ្ជាប់ជាមួយប្រជាជន
ឆ្ពោះទៅរកជោគជ័យថ្មីៗទៀត......................................................................... ៣
Editorial : TTStrengthening CPP's Leadership Role, Bonding with People for Further
Successes.......................................................................................................

- សកម្មភាពសមាជិកព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ................................ ១៦
- លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច.................................................................................... ១៨
- វិស័យពាណិជ្ជកម្មកំពុងជំរុញការធ្វើកំណែទម្រង់ផ្ទៃក្នុង
  - តម្លៃនៃការនាំចេញ-ចូល ត្រីមាសទីមួយដើមឆ្នាំ ២០១៤ កើន ១៥%.................................. ១៩
- សមិទ្ធផលនៃវិស័យអប់រំក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រឆ្នាំ ២០០៩-២០១៣
  - ទិសដៅជាអាទិភាពបន្ត គឺការលើកកម្ពស់គុណភាព.................................................... ២២
- វប្បធម៌ : ទេពអប្សរា និងកាយវិការសំពះ....................................................................... ២៥
- វិទ្យាសាស្ត្រសុខភាព : អត្ថប្រយោជន៍ផ្លែល្ពៅចំពោះសុខភាព
  - គុណប្រយោជន៍នៃសាច់មាន់ខ្មៅ ....................................................... ២៧
- បទសម្ភាសន៍ : គណបក្សប្រជាជនកម្ពុជា ជាក្ដីសង្ឃឹម ជាបង្អែក និងជាទីទុកចិត្តតែមួយគត់
  ប្រជាជនកម្ពុជា ..................................................................................... ២៨
- ចម្រៀង : ចម្រៀងអបអរសាទរខួបទី ៦៣ ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា....... សំណើច ... ៣១

ទស្សនាវដ្តី

# ប្រជាជន

THE PRACHEACHUN MAGAZINE




## អបអរសាទរ ខួបអនុស្សាវរីយ៍លើកទី ៦៣ ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា




ឆ្នាំទី១៤ លេខ ១៥៧ ខែមិថុនា ឆ្នាំ ២០១៤

# ទស្សនាវដ្តីប្រជាជន

## ដែលបានចេញផ្សាយឆ្នាំទី ១៣ ( ២០១៣-២០១៤ )


























ចែកជូនដោយឥតគិតថ្លៃ